


# ទស្សនាវដ្ដី
# មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម



ឆ្នាំទី ១
លេខ ២

ចេញផ្សាយប្រចាំឆមាស
ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ខែកក្កដា - ធ្នូ
ឆ្នាំ ២០២២

# និពន្ធនាយក

ឯកឧត្តមបណ្ឌិត **ផុន កសិកា**

## រៀបចំចងក្រងដោយ

លោក **យិន ពោ**

## ក្រុមត្រួតពិនិត្យ

១-លោកបណ្ឌិត : **យិន យ៉ង់**

២-លោក : **លី តុង**

៣-លោកបណ្ឌិត : **តូច សុធារី**

៤-លោកបណ្ឌិត : **ទុយ យូឃីម**

៥-លោកស្រី : **យាង ធានី**

## រចនាក្រប

ដោយ : លោក **ហ៊ាង សុចិត្រា**

អាសយដ្ឋាន : មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ
(ជាប់បរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២)

គេហទំព័រ (Website) : https://ihss.rac.gov.kh

ហ្វេសប៊ុក(Facebook) : https://web.facebook.com/
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្តនិងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។

រាជបណ្ឌិត្យសភាកម្ពុជាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ ដើម្បីផ្តល់ជាតុចូលជូនរាជរដ្ឋាភិបាលសម្រាប់បម្រើដល់កិច្ចការស្ថាបនា និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះដែរ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម បានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និងបោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។ **ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** ប្រមូលផ្តុំដោយអត្ថបទទាក់ទងទៅនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និងអត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជា អ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និងជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់ សិស្ស និស្សិត អ្នកស្រាវជ្រាវទូទៅ ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

**ប្រធានវិទ្យាស្ថាន**

**បណ្ឌិត ផុន កសិកា**

# មាតិកា

ទំព័រ

១-ផ្ទាំងចម្លាក់ឥន្ទ្រាភិសេកនៅប្រាសាទបាយ័ន.................................................................១

២-ស្ពានបណ្ដែតទឹកសម័យអង្គរទ្រទ្រង់កងទ័ពក្នុងសឹកសង្គ្រាម................................១៧

៣-ហេតុអ្វីត្រូវសិក្សាបុរាណវត្ថុវិទ្យា?.........................................................................២៦

៤-ឡុញ ឡាយ៉ះបទពិសោធន៍ជិត៣០ឆ្នាំជាអ្នកជំនាញកំណាយបុរាណវត្ថុវិទ្យានៅតំបន់អង្គរ....៣៤

៥-ចំណោទបញ្ហា..........................................................................................................៤១

៦-ច្បាប់ និង ឥរិយាបថរបស់មនុស្ស.............................................................................៤៧

៧-ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរ...............................................................................៦២

៨-ទស្សនៈនានាក្នុងការរើសគូស្រករក្នុងអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំង...........៦៦

៩-បច្ចុប្បន្នភាពនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិននៅកម្ពុជា...................................៨៦

១០-ការអប់រំ និង សុខភាព...........................................................................................១០៣

# ផ្ទាំងចម្លាក់ឥន្ទ្រាភិសេកនៅប្រាសាទបាយ័ន

*ដោយ ៖ បណ្ឌិត យង់ ពៅ, បណ្ឌិត ផុន កសិកា, កញ្ញា តាកេត ស័កដា*
*លោក ឡេង សត្យា,លោកស្រី ម៉ិល វាសនា,លោក សួ ប៊ុណ្ណារ៉ាត់*
*និង លោក រឿន ភារុន*

*ប្រាសាទបាយ័ន ស្ថិតនៅចំកណ្ដាលនៃរាជធានីអង្គរ ដែលកសាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ នាចុងសតវត្សទី១២ និងដើមសតវត្សទី១៣។ យើងដឹងហើយថា ប្រាសាទបាយ័នជាប្រាសាទធំ និងល្បីល្បាញមួយក្នុងតំបន់អង្គរ ខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជា ដោយសារជាប្រាសាទធំស្កឹមស្កៃ មានភាពទាក់ទាញពីតួប្រាសាទនិមួយៗមានព្រហ្មមុខ៤ ចំនួន៥៤តួ និងក្បាច់រចនាល្អឯកៗ ក្បាច់រចនាត្រូវបានឆ្លាក់នៅពាសពេញប្រាសាទ តែអ្វីដែលគួរឱ្យស្ញប់ស្ញែងគឺមានចម្លាក់នៅតាមថែវខាងក្រៅនិងថែវខាងក្នុងនៃប្រាសាទបាយ័ន។ នៅរាជ្ជកាលមុនៗ ពិសេសក្នុងរាជព្រះបាទសូរ្យវរ្ម័នទី២ បានកសាងប្រាសាទអង្គរវត្តប្រកបដោយក្បាច់រចនានៅស្ទើរគ្រប់កន្លែង និង ចម្លាក់រឿងរ៉ាវផ្សេងៗនៅថែវទី២ ប៉ុន្តែឆ្លាក់លើថែវតែមួយទេ។ ចំណែកប្រាសាទបាយ័ន គេឆ្លាក់ចម្លាក់រឿងនៅគ្រប់ថែវទាំងក្នុងនិងខាងក្រៅ។*

*ថែវខាងក្រៅនៃប្រាសាទបាយ័ន មានប្រវែងពីជើងទៅត្បូង១៣០ម៉ែត្រ និងពីកើតទៅលិចប្រវែង១៤០ម៉ែត្រ[១]។ ចំណែក ថែវខាងក្នុងនៃប្រាសាទបាយ័នមានប្រវែងពីជើងទៅត្បូង៧៦ម៉ែត្រ និងពីកើតទៅលិចប្រវែង៨៧ម៉ែត្[២]។ ចម្លាក់និមួយៗនៅលើជញ្ជាំងប្រាសាទពិពណ៌នាអំពីដំណើររឿង និងឈុតឆាកនៃរឿងរ៉ាវទេវកថា កិច្ចពិធីសាសនា ព្រឹត្តិការណ៍នានា ដែលទាក់ទងទៅនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រ និងខ្សែរាជវង្ស ជាពិសេស*

---

[១] Roveda, Vittorio., Reliefs of the Bayon, in *Bayon New Perspectives*, Edited by Joyce Clark, River Book, 2007, P. 312

[២] Roveda, Vittorio., Reliefs of the Bayon, in *Bayon New Perspectives*, Edited by Joyce Clark, River Book, 2007, P. 286

មានស្ទើរតែគ្រប់ឈុតគ្រប់ឆាកដែលជាដំណើររឿងនៃព្រះបាទជ័យវរ្ម័នទី៧។

ឈុតមួយនៃចម្លាក់ថែវខាងក្រៅ ជ្រុងខាងលិច ស្លាបខាងជើង រៀបរាប់បង្ហាញអំពីដំណើររឿងនៃកិច្ចពិធី «ឥន្ទ្រាភិសេក» របស់ព្រះបាទជ័យវរ្ម័នទី៧បន្ទាប់ពីទទួលបានជោគជ័យពីការធ្វើសឹកសង្គ្រាម។ «ពិធីឥន្ទ្រាភិសេក» ជាពិធីពិសេសមួយក្នុងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទី៧ ដែលគេឃើញមានភស្តុតាងយ៉ាងច្បាស់ជាចម្លាក់ និងសិលាចារឹកដែលចារនៅពីក្រោមចម្លាក់ដំរី ដែលព្រះមហាក្សត្រទ្រង់គង់ពីលើ។

សិលាចារឹកជាភាសាខ្មែរមួយឃ្លានេះ រកឃើញដោយលោក Jean Commaille នៅឆ្នាំ ១៩១២។ ក្រោយមកទៀត លោក G. Coedes[៣] បានបកប្រែសិលាចារឹកនេះ។ សិលាចារឹករៀបរាប់អំពីសាច់រឿងនៃចម្លាក់នៅពីលើនោះ ប៉ុន្តែអក្សរចារឹកទាំងនោះពិបាកយល់ ព្រោះគេចារលើសាច់ថ្មគ្រើមមិនរលោង។ នៅដើមឃ្លានៃអក្សរចារឹកមានសភាពខូចខាតខ្លាំង (ndara jñâna sa. ür - taigaksa uk chok raikä supur jhe yu - çänti bhuvana phon hoi stac vanodeṣa nå stac thve vrahindrabhiseka) ដែលសេចក្តីប្រែសម្រួលថា«...សុខសាន្តក្នុងព្រះនគរហើយ ទើបស្តេចយាងចេញធ្វើព្រះរាជពិធីឥន្ទ្រាភិសេក[៤]។ ក្រៅពីសិលាចារឹកឥន្ទ្រាភិសេក មានសិលាចារឹកផ្សេងទៀតដែលឆ្លាក់នៅតាមថែវ នៅក្បែរនឹងសិលាចារឹកឥន្ទ្រាភិសេក។ សិលាចារឹកទាំងនោះមាន៖

-សិលាចារឹកទី១៖ ចារនៅលើថែវខាងត្បូង ស្លាបខាងកើតរហូតដល់ចុងស្លាបខាងលិច នៅពីក្រោមកង់ទ័ពដែលមានឯកសណ្ឋានទាហានផ្លូវការដែលវាយប្រហារជាមួយសត្រូវ។

-សិលាចារឹកទី២៖ ចារលើថែវខាងលិច ស្លាបខាងជើង រហូតដល់ចុងខាងត្បូង។

-សិលាចារឹកទី៣៖ ចារនៅខាងស្តាំជាប់នឹងសិលាចារឹកមុន នៅក្រោមចម្លាក់បង្ការធំមួយ។ ការពិពណ៌នាអំពីផ្ទាំងចម្លាក់ឥន្ទ្រាភិសេក៖

ផ្ទាំងចម្លាក់នេះចែកជា២ឋាន (ជាន់) ហើយឋាននិមួយៗមានចម្លាក់ដូចពិពណ៌នាខាងក្រោម៖

ឋានខាងលើ៖

---

[៣] Coedès, G., *BEFEO*, XXXII, 1932, p. 71-81

[៤] សូមអាន ព្រាប ចាន់ម៉ារ៉ា និង ជា សុជាតិ, ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧, ២០១៦,១៨-២០។

ផ្ទាំងចម្លាក់នេះរៀបរាប់អំពីក្បួនដង្ហែរបស់ព្រះមហាក្សត្រ ដែលយើងសន្និដ្ឋានថាមិនមែននរណាក្រៅពី «ព្រះបាទជ័យវរ្ម័នទី៧» ឡើយ។ ការសន្និដ្ឋាននេះ ដោយសំអាងលើសិលាចារឹកឥន្ទ្រាភិសេកដែលរៀបរាប់ខាងលើរួចមកហើយ។ ចម្លាក់រូបមនុស្សដែលបង្ហាញពីតួនាទីរបស់ព្រះមហាក្សត្រឃើញថា មានទំហំធំខុសពីរូបមនុស្សធម្មតា គ្រឿងសម្លៀកបំពាក់ ប្រដាប់និងរំដាប់ជាស្តេច ព្រមទាំងហែហមដោយកេតនភណ្ឌស្តេចជាច្រើនទៀតដូចជាក្លស់ ផ្ចិត ស៊ែ[៥](ផ្ចិតបក់មានដងវែង) និង មនុស្សម្នាដែលជាកងទ័ពហែទាំងមុខនិងក្រោយ។

ផ្ទាំងចម្លាក់នេះបង្ហាញពីការចេញដំណើររបស់ព្រះមហាក្សត្រ ដោយទ្រង់ឈរលើដំរីយ៉ាងក្លាហាន ដោយទ្រង់មានគ្រងអាវក្រោះពីលើអាវដៃខ្លី និងគ្រងមកុដកំពូលបី[6]។ ព្រះហស្តឆ្វេងទ្រង់កាន់ធ្នូ ហើយព្រះហស្តស្តាំទ្រង់ចង្អុលទៅមុខជាលក្ខណៈបញ្ជាកងទ័ព (រូបលេខ១ និងលេខ២)។ នៅខាងក្រោយដំរីរបស់ព្រះអង្គ គេឃើញសំណង់ជាច្រើនដែលមានការតុបតែងលម្អយ៉ាងស្អាត។ លក្ខណៈនៃសំណង់នេះ ប្រហែលជាព្រះពន្លា ឬព្រះបរមរាជវាំងផងក៏មិនដឹង។ ទន្ទឹមនឹងនេះ នៅជុំវិញព្រះទីនាំងដំរីរបស់ព្រះអង្គ មានហែហមដោយមនុស្សជាច្រើន ដែលមានអ្នកកាន់ផ្ចិត ក្លស់ និងសម្ភារៈជាច្រើនទៀត និងមានកងទ័ពប្រដាប់ដោយគ្រឿងសព្វាវុធផ្សេងៗមានដូចជា ព្រួញ ស្នា លំពែង ដាវ ផ្គាក់ ខែលជាដើម។

ផ្ទាំងចម្លាក់នេះត្រូវមើលពីស្តាំទៅឆ្វេង (ពីជើងទៅត្បូង)។ នៅខាងដើមផ្ទាំងចម្លាក់មានកងទ័ពថ្មើរជើងនាំមុខគេ ដែកាន់ទង់ជ័យវែងៗខ្ពស់ទៅលើ(រូបលេខ៣)។ បន្ទាប់មកមានក្រុមមួយ[៧](អត្ថបទខ្លះហៅក្រុមនេះថា ក្រុមដូរតន្ត្រី) វាយគង ផ្លុំស្នែង វាយស្គរ។ ក្រុមនេះមានអ្នកវាយគងតែម្នាក់ទេ មានអ្នកសែងគងចំនួន២នាក់ អ្នកផ្លុំស្នែងចំនួន២នាក់ និងអ្នកវាយស្គរ

---

[៥] ប្រដាប់ធ្វើដោយសំណុំសក់កន្ទុយសេះមានដង សម្រាប់កាន់វាយវាត់កម្ចាត់សុខុមសត្វមានស្វាប មាន មូស, រុយជាដើម (វចនានុក្រមខ្មែរ)។

[6] លោក Vittorio Roveda (Reliefs of the Bayon, in Bayon New Perspectives, p. 315) ឱ្យសម្មតិកម្មថា រូបនេះគឺជាគ្មាននរណាក្រៅពីព្រះបាទជ័យវរ្ម័នឡើយ ប៉ុន្តែ ចំឡែកដែលជាធម្មតាព្រះអង្គចងសក់កំប៉ោយដាក់ទៅក្រោយ។

[៧] ស្លាកព័ត៌មានរបស់អាជ្ញាធរជាតិអប្សរាដែលដាក់នៅតាមប្រាសាទបាយ័នសរសេរថា «ក្រុមដូរតន្ត្រី»។

ចំនួន២នាក់ដែរ[៨]។ នៅពីលើក្រុមវាយគងយើងឃើញមានក្ងស់ ផ្ចិត ដែលទំនងជាមានកងទ័ពនៅចំហៀងក្រុមវាយគងកាន់វត្ថុទាំងនេះ។ ហើយបន្តពីនេះ មានក្រុមអ្នកសែងព្រះតេ្វីង ដែលជាកេតនភណ្ឌមួយក្នុងចំណោមកេតនភណ្ឌផ្សេងៗទៀតរបស់ព្រះមហាក្សត្រសម្រាប់ធ្វើកិច្ចសាសនា។ ព្រះតេ្វីងដាក់លើគ្រែស្នែង ហើយសែងដោយមនុស្សចំនួនប្រហែល ១០នាក់។ នៅចំហៀងអ្នកសែងព្រះតេ្វីង យើងឃើញមានស៊ែ ផ្ចិត និងក្ងស់ជាច្រើនហែគ្រប លើព្រះតេ្វីងនេះ។ បន្ទាប់ពីក្រុមសែងព្រះតេ្វីង មានកងទ័ពសេះ (រូបលេខ២)។ កងទ័ពសេះមិនជិះលើសេះទេ ពួកគេអោបសេះក្នុងទម្រង់ជាបណ្តើរសេះទៅវិញ។ ចំណែកសេះវិញមើលទៅហាក់ដូចជាកំពុងដើរ។ នៅពីក្រោយកងទ័ពសេះ បន្តដោយកងទ័ពថ្មើរជើងក្នុងដំណើរស្វាហាប់ បោះជំហានវែងៗ ប្រដាប់ដោយគ្រឿងអាវុធដូចជាលំពែង និងខែលរាងមូលផង និងខែលរាងទ្រវែងផង។ ខែលរាងទ្រវែងអាចប្រើការពារពីកាប់ដោយដាវ ឬលំពែង និងក៏អាចប្រើការពារគ្រាប់ព្រួញដែរ ពិសេសគេអាចរៀបជាកំពែងជាប់ៗគ្នាការពារគ្រាប់ព្រួញ[៩]។ នៅចំហៀងកងទ័ពថ្មើរជើង យើងឃើញមានព្រៃ និងដើមឈើធំៗ(រូបលេខ៥)។ បន្តពីទ័ពថ្មើរជើង មានក្រុមអ្នកវាយគង ផ្គុំស័ង្ខ ផ្លុំស្នែង ប៉ុន្តែ មិនឃើញអ្នកវាយស្គរទេ(រូបលេខ៦)។ ហើយបន្តមកទៀត មានកងទ័ពថ្មើរជើងមួយកងធំដើរយ៉ាងស្វាហាប់ កាន់អាវុធដូចជា ខែលរាងទ្រវែង ខែលមូល ផ្គាក់ លំពែង។ កងទ័ពមួយកងធំនេះគឺស្ថិតនៅមុខជាប់នឹងដំរីរបស់ព្រះបាទជ័យវរ្ម័នទី៧។ ចំពោះកងទ័ពដែលនៅជិតដំរី ពួកគេកាន់ស៊ែ ផ្ចិត និងក្ងស់ជាច្រើន(រូបលេខ៧)។ ជាប់នឹងកងទ័ពមួយកងធំនេះគឺដំរីរាជដែលជាជំនិះរបស់ព្រះអង្គដែលទ្រង់កំពុងគង់នៅពីលើ ជិះសំដៅទៅធ្វើពិធីឥន្ទ្រាភិសេក។ នៅចំហៀងដំរីក៏មានកងទ័ពហែហមកាន់ស៊ែ ផ្ចិត និងក្ងស់ជាច្រើន។ ដំរីកំពុងដើរទៅមុខ ប្រមោយលើកឡើងលើ និងមានហ្មដំរីម្នាក់ដៃកាន់កង្វេរ។ នៅពីក្រោយដំរីមានកងទ័ពមួយកងជង្ហែក្រោយក្បួនដែលជាក្បួនជង្ហែចុងក្រោយគេបង្អស់។ នៅខាងចុងផ្ទាំងចម្លាក់ឥន្ទ្រាភិសេកនេះ មានចម្លាក់នារីជា

[៨] នៅផ្ទាំងចម្លាក់ក្បួនជង្ហែរខ្វះ ក្រុមវាយគងនេះ មានទាំងអ្នកគោះឆាបផង។

[៩] Hegoualc'h, M.J., 1979, p. 18

ម្ដាយ កូនក្មេង និងមនុស្សម្នាជាច្រើននាក់ទៀតកំពុងឈរ អង្គុយគោរព និងអបអរសាទរចំពោះក្បួនដង្ហែរបស់ព្រះមហាក្សត្រ (រូបលេខ ៨)។ ឋានក្រោមៈ

ផ្ទាំងចម្លាក់ក្នុងឋានក្រោមនេះអាចមើលពីទិសខាងជើង ទៅខាងត្បូង ជាសាច់រឿងនៃក្បួនដណ្ដើ កងទ័ពច្មើរជើង។

ផ្នែកចាប់ផ្ដើមនៃផ្ទាំងចម្លាក់ឋានក្រោមមានកងទ័ពដើរកាន់ផ្គាក់ លំពែង និងខែលមូល។ កងទ័ពមានសម្លៀកបំពាក់ អាវធ្លាក់ជាយនៅសងខាង និងខោចងរឹប ទម្លាក់ជាយចុះក្រោមបន្តិច និងជាយមានរាងជាកន្ទុយត្រី។ យើងសង្កេតឃើញ កងទ័ពមានពាក់ខ្សែក។ នៅជួរទី៤នៃកងទ័ពច្មើរជើងនេះ មានទាហានម្នាក់ ដែកាន់ផ្គាក់ និងមានឆត្រ ឬ ក្ងស់។ បន្ទាប់ពីទ័ពដែកាន់ឆត្រ មានកងទ័ពច្មើរជើងចំនួន៣ជួរទៀត មុននឹងដល់ទាហានម្នាក់ទៀតដែលកាន់ក្ងស់ (រូបលេខ៩)។

បន្ទាប់ពីទាហានដែលមានក្ងស់ គឺជាកងទ័ពស្នា លាយជាមួយទាហានកាន់ផ្គាក់ និងលំពែងខ្លះ មានសម្លៀកបំពាក់ដូចកងទ័ពជួរមុខដែរ (រូបលេខ១០)។

បន្ទាប់ពីកងទ័ពស្នា គឺកងទ័ពលំពែងមានខែលទ្រវែង ហើយនៅពីក្រោយដោយទាហានកាន់ក្ងស់ម្នាក់ (រូបលេខ១១)។

បន្ទាប់ពីទាហានមានក្ងស់ គឺកងទ័ពកាន់ផ្គាក់ និងខែលមូល ហើយបន្តដោយកងទ័ពលំពែងកាន់ខែលទ្រវែង។ កងទ័ពមួយកងនេះនៅពីក្រោយដោយកងទ័ពម្នាក់មានក្ងស់ ដែកាន់ផ្គាក់ ពាក់អាវក្រោះ ដៃស្តាំចង្អុលទៅមុខ។ កាយវិការនេះបង្ហាញថាកងទ័ពពាក់អាវក្រោះ កាយវិការចង្អុល អាចជាមេទ័ពម្នាក់ដែរ (រូបលេខ១២)។

បន្ទាប់ពីមេទ័ពពាក់អាវក្រោះ គឺជាកងទ័ពព្រួញ ដែកាន់ដងធ្នូ និង ខែលរាងមូល។ នៅពីក្រោយទ័ពព្រួញ មានទាហានម្នាក់ទៀតមានក្ងស់ ពាក់អាវក្រោះ ប្រហែលជាមេទ័ពម្នាក់ទៀតដែរ (រូបលេខ១៣)។

បន្ទាប់ពីមេទ័ពមានក្ងស់ គឺកងទ័ពស្នាមិនមានកាន់ខែលទេ។ នៅពីក្រោយទ័ពស្នា គឺទ័ពកាន់លំពែង (រូបលេខ១៤)។

បន្ទាប់ពីទ័ពលំពែង គឺស្ថិតក្នុងជួរទ័ពលំពែងដដែល ហើយនៅពីក្រោយដោយមេទ័ពម្នាក់ទៀតមានក្ងស់ ប៉ុន្តែមិនឃើញមានពាក់អាវក្រោះទេ តែកាយវិការកំពុងចង្អុលទៅមុខ។ នៅពីក្រោយមេទ័ព គឺកងទ័ពប្រដាប់

ដោយផ្អាក់ និង ដាវ ព្រមទាំងខែលមូលគ្រប់គ្នា (រូបលេខ១៥)។

នៅភាគចុងក្រោយនៃផ្ទាំងចម្លាក់ គឺទ័ពកាន់ដាវដែលបន្តពី រូបលេខ១៥។ កងទ័ពនៅខាងចុងក្បួនកំពុងងាកក្រោយមើលមកក្រុមគ្រួសារដែលនៅជូនដំណើរ។ បន្តពីកងទ័ពកាន់ដាវគឺសាច់រឿងបង្ហាញពីសកម្មភាពមនុស្សមួយក្រុម ទាំងក្មេង ទាំងចាស់ ខ្លះកំពុងអង្គុយ ខ្លះឈរ ខ្លះលត់ជង្គង់ធ្វើកាយវិការហាក់ដូចជាកំពុងគោរពចំពោះព្រះមហាក្សត្រ និងអបអរចំពោះក្បួនទ័ព។ ក្នុងនោះក៏មានស្ត្រី និងកូនតូចៗអង្គុយឱបជើងកងទ័ព ដោយទឹកមុខក្រៀមក្រំ (ប្រហែល ភរិយានិងក្រុមគ្រួសារកងទ័ព ជូនដំណើរប្តីចាកចេញទៅជាមួយព្រះមហាក្សត្រ ទៅធ្វើពិធីឥន្ទ្រាភិសេក) (រូបលេខ១៦)។

សរុបសេចក្តីមក ចម្លាក់នៅថែវខាងលិច ផ្នែកខាងជើងប្រាសាទបាយ័ន និងសិលាចារឹកK.469 នេះ អាចសន្និដ្ឋានបានថា «ពិធីឥន្ទ្រាភិសេក» របស់ព្រះបាទជ័យវរ្ម័នទី៧ ពិតប្រាកដមែន។ តាមខ្លឹមសារសិលាចារឹកនោះទៀតសោធ បានបញ្ជាក់ថា ព្រះបាទជ័យវរ្ម័នទី៧ បានប្រារព្ធពិធីនេះ ក្រោយពេលព្រះអង្គធ្វើសង្គ្រាម ច្បាំងឈ្នះចាម និងក្រុមបះបោរក្នុងប្រទេស ពោលគឺ ក្រោយពេលប្រទេសមានសន្តិភាព (រូបលេខ១៧)។



ប្លង់ផ្ទាំងចម្លាក់ «ឥន្ទ្រាភិសេក» នៃប្រាសាទបាយ័ន នៅជ្រុងខាងលិច ស្លាបខាងជើង (ប្រភព៖ អាជ្ញាធរអប្សរា)



រូបលេខ ១



រូបលេខ ២



រូបលេខ ៣



រូបលេខ ៤



រូបលេខ ៥



រូបលេខ ៦



រូបលេខ ៧



រូបលេខ ៨



រូបលេខ ៩



រូបលេខ ១០



រូបលេខ ១១



រូបលេខ ១២



រូបលេខ ១៣



រូបលេខ ១៤



រូបលេខ ១៥



រូបលេខ ១៦



ផ្ទាំងចម្លាក់ឥន្ទ្រាភិសេក (ផ្ទាំងទាំងមូល)

បច្ចេកទេសរូបថត៖ ឡេង សត្យា

## ឯកសារយោង៖


១-ព្រាប ចាន់ម៉ារ៉ា និង ជា សុជាតិ, ព្រះបរមរូបព្រះបាទជ័យវរ្ម័នទី៧, ភ្នំពេញ, ២០១៦

២-Coedès, G., *BEFEO*, XXXII, 1932, p. 71-81

៣-Hegoualc'h, M.J., The Army of Angkor: Military Structure and Weaponry of the Khmers, Orchid Press, 1979, p. 18

៤-Roveda, Vittorio., Reliefs of the Bayon, in *Bayon New Perspectives*, Edited by Joyce Clark, River Book, 2007.

# ស្ពានបណ្ដោតទឹកសម័យអង្គរទ្រទ្រង់កងទ័ពក្នុងសឹកសង្គ្រាម

ដោយ ៖ បណ្ឌិត យង់ ពៅ,បណ្ឌិត ផុន កសិកា,កញ្ញា តាកេត ស័កដា
លោក ឡេង សត្យា, លោកស្រី មិល វាសនា,លោក សួ ប៉ុណ្ណារ៉ាត់
និង លោក រឿន ភារុន

ស្ពានជាសំណង់ឆ្លងកាត់ទទឹងផ្លូវទឹក មាន អូរ, ព្រែក, ស្ទឹងជាដើម សម្រាប់ឆ្លងពីទីម្ខាងទៅទីម្ខាង (វចនានុក្រមខ្មែរ)។

ជាទូទៅ ស្ពានសង់ពីឈើក៏មាន សង់ពីថ្មក៏មាន ប៉ុន្ដែស្ពានឈើចាប់បាក់ជាងស្ពានថ្ម។ បើយើងរំលឹកដល់សម័យបុរាណវិញ សំណង់ស្ពានមិនមែនមានត្រឹមតែជាស្ពានថ្មនោះទេ វាពិតជាមានសំណង់ស្ពានឈើដែរ ប៉ុន្ដែត្រូវពុកផុយអស់ទៅ ព្រោះឈើមិនអាចនៅឋិតថេរយូរអង្វែងដូចថ្មឡើយ។ ពិសេសនៅសម័យមហានគរ (សម័យអង្គរ) មានសំណង់ស្ពានបុរាណនៅឋិតថេរដល់សម័យបច្ចុប្បន្ន ដែលជាប្រភេទស្ពានថ្ម សង់ពីថ្មបាយក្រៀម និង ថ្មភក់ ជាច្រើនដែលសង់នៅតាមបណ្ដោយផ្លូវបុរាណធំៗពីរាជធានីអង្គរឆ្ពោះទៅកាន់ខេត្តខណ្ឌផ្សេងៗក្នុងអាណាចក្រខ្មែរ (Hendrickson 2011, Lusting and Hendrickson 20)។

ចំពោះប្រភេទស្ពានវិញ ភាគច្រើន គេសង់ស្ពានខ្ពស់ផុតពីទឹកដែលអាចឱ្យទូកតូចធំធ្វើចរាចរតាមព្រែក អូរ ស្ទឹងបាន ដោយកាត់ក្រោមស្ពាន។ ចំណែករចនាសម្ព័ន្ធស្ពានខ្ពស់ផុតពីទឹកត្រូវមានសសរទ្រជាច្រើន ចាប់ទីម្ខាងទៅទីម្ខាងទៀត។ ក្រៅពីស្ពានខ្ពស់ផុតពីទឹកនៅមានសំណង់ស្ពានមួយប្រភេទទៀតដែលជាប្រភេទកម្រនឹងជួបប្រទះ គឺ «ស្ពានបណ្ដោតទឹក»។

ស្ពានបណ្ដោតទឹកដែលជាភស្ដុតាងមួយបញ្ជាក់ថា ខ្មែរបុរាណក៏ចេះសង់ស្ពានប្រភេទបណ្ដោតទឹកដែរ គឺឃើញមាននៅចម្ងាក់ធ្លាក់លើថែវខាងជើងនៃប្រាសាទបន្ទាយឆ្មារ ក្នុងខេត្តបន្ទាយមានជ័យ។ អ្នក

ស្រាវជ្រាវ ដូចជាលោក អ៊ឹម សុខរិទ្ធី ក៏បានធ្វើបទបង្ហាញបញ្ជាក់ថា ចម្លាក់ឆ្លាក់នៅថែវខាងជើងនៃប្រាសាទបន្ទាយឆ្មារគឺជាស្ពានបណ្តែតទឹក។ លោក អ៊ឹម សុខរិទ្ធី ក៏លើកឡើងទៀតថា ស្ពានបណ្តែតទឹកដែលសង់ថ្មីនៅកសិន្ទុនៃប្រាសាទអង្គរវត្ត យកតាមគំរូនៃចម្លាក់ស្ពាននៅប្រាសាទបន្ទាយឆ្មារនេះ។

ចម្លាក់ស្ពានបណ្តែតទឹកនៅថែវខាងជើងប្រាសាទបន្ទាយឆ្មារបង្ហាញពីដំណើរឆ្លងកាត់របស់កងទ័ពពីទិសខាងលិចទៅខាងកើត (ជៀបនឹងទីតាំងនៃថែវ)(រូបលេខ១និង២)។ កងទ័ពមានចំនួន២៩នាក់ ស្ថិតនៅលើស្ពានរាប់ទាំងហ្មដំរី២នាក់ផង។ ក្រៅពីកងទ័ព នៅមានដំរីសឹកសង្គ្រាមចំនួន២ទៀត។ កងទ័ពប្រដាប់ដោយគ្រឿងអាវុធធ្វើសឹកសង្គ្រាម ដូចជាៈ ផ្គាក់ លំពែង ដាវ ធ្នូ និង ក្ងស់ ឆ័ត្រ ទៀតផង។ មានដំរី២ដើរកាត់ស្ពាន ប៉ុន្តែមិនមានបំពាក់កូបលើខ្នងនោះទេ (រូបលេខ ៥)។

នៅលើផ្ទៃទឹក មានក្រុមអ្នកនេសាទ (ចំនួន៣ទូក) កំពុងបង់សំណាញ់ និង ស្ទូចត្រី។ ចំណែកនៅក្នុងទឹកវិញ មានសត្វក្រពើ ត្រីតូច ត្រីធំ សត្វស្វាបធំមួយ។ មានសត្វក្រពើមួយស្ថិតនៅផ្នែកខាងក្រោមចម្លាក់ ប៉ែកខាងកើត មានកាយវិការទំនងជាដេញសត្វអ្វីមួយ។ នៅជិតក្រពើនេះដែរ ប៉ុន្តែនៅលើគោកក្បែរច្រាំងស្ទឹង មានសត្វខ្លាធំមួយដែលមានកាយវិការភ័យបះជើង២ឡើងលើ។

នៅតាមមាត់ស្ទឹងវិញ មានដើមឈើធំៗក្នុងនោះមានដើមឫស្សីដែរ។ នៅក្នុងព្រៃ មានសត្វខ្លា និងមនុស្សម្នាក់កំពុងពួនអែបនឹងគល់ឈើក្នុងកាយវិការទំនងជារៀបបាញ់ខ្លានោះ។ នៅផ្នែកខាងក្រោមជាប់នឹងមាត់ស្ទឹងត្រើយខាងកើត មានសត្វខ្លា២ប្រហែលជាកូននិងមេខ្លាដែលរត់ចេញពីមាត់ស្ទឹង ព្រោះត្រូវក្រពើដេញ(រូបលេខ៦)។ សត្វមួយប្រភេទដែលតែងឃើញមាននៅតាមចម្លាក់គឺសត្វកំប្រុក១នៅលើដើមឫស្សី (រូបលេខ ៧) និង១ទៀតនៅលើដើមឈើធំ។ ក្រៅពីនោះ ក៏នៅមានសត្វស្វាបខ្លះដែរ។

## រចនាសម្ព័ន្ធស្ពានបណ្តែតទឹកៈ

តាមចម្លាក់ដែលអាចមើលឃើញស្ពានបណ្តែតទឹកនេះមានបង្គោលសសរចំនួន៤ (បង្គោលសសរ២នៅចុងម្ខាង ចំណែកបង្គោលសសរ២ទៀតនៅចុងម្ខាងទៀត) (រូបលេខ៣ និង៤)។ រនូតស្ពាន ត្រូវចងស្រាក់ ឬ ក្រងតៗគ្នា ហើយចងភ្ជាប់ទៅនឹងបង្គោលសសរនៅខាងចុងសងខាង។ ក្តារស្ពានប្រហែលដាក់ក្រាលពី

លើរនូតទាំងអស់នោះ។ ស្ពាននេះពុំឃើញមានបង្គោលសសរនៅក្នុងស្ទឹងទេ មានន័យថាគេមិនប្រើបង្គោលសសរណាផ្សេងទៀតក្រៅពីបង្គោលសសរនៅចុងសងខាងស្ពានឡើយ។

តាមរយៈចម្ងាក់កងទ័ព និង ដំរីនៅលើស្ពាន យើងអាចសាកល្បងពិចារណាអំពីប្រវែងស្ពាន និង ចំណុះទម្ងន់ស្ពានដែលអាចទ្រទ្របាន។

ជាទូទៅ ទម្ងន់មនុស្សប្រុសអាចមានទម្ងន់ពី ៦០គ.ក ទៅ ៧៥ គ.ក។ ចំពោះកងទ័ពដែលឆ្លងកាត់ការហ្វឹកហាត់ ព្រមទាំងដំណើរវែងឆ្ងាយពីកន្លែងមួយទៅកន្លែងមួយ ពីសមរភូមិមួយទៅសមរភូមិមួយ ពួកគេអាចមានទម្ងន់មិនធ្ងន់ប៉ុន្មានទេ។ ដូច្នេះ យើងអាចសន្មតថា កងទ័ពម្នាក់មានទម្ងន់ ៦៥គ.ក។ កងទ័ពចំនួន២៩នាក់ មានទម្ងន់ ១៨៨៥គ.ក។ បើយើងគិតបញ្ចូលទាំងសម្ភារៈសឹកផងនោះ កងទ័ពអាចមានទម្ងន់២០០០គ.ក.ស្មើនឹង២តោន។

ចំណែកសត្វដំរីវិញ ដំរីពេញវ័យមានទម្ងន់ចាប់ពី ២.៥តោន ទៅ ៧តោន។ ដូច្នេះ បើយើងសន្មតថា ដំរីស្ថិតនៅលើស្ពានមានទម្ងន់ ៤តោន នោះដំរី២មានទម្ងន់៨តោន។

បើតាមការសន្មតទម្ងន់កងទ័ពទាំងអស់ និងដំរីទាំង២ផង ស្ពានបណ្តែតទឹកអាចទ្រទម្ងន់បាន១០តោន។

ចំពោះប្រវែងស្ពានវិញ យើងអាចសន្មតយកប្រវែងដំរីមកពិចារណា។ ជាទូទៅដំរីពេញវ័យអាចមានប្រវែងពី ៣-៥ម៉ែត្រ។ បើយើងសន្មតយកប្រវែងដំរីកំពុងដើរលើស្ពានប្រវែង ៤ម៉ែត្រ ស្ពានបណ្តែតទឹកដែលកាត់លើស្ទឹងអាចមានប្រវែងចាប់ពី ២០ម៉ែត្រ ទៅ ២៥ម៉ែត្រ។

ការពិត ចម្លាក់ស្ពានបណ្តែតទឹកស្ថិតក្នុងឈុតធំមួយដែលឆ្លាក់បង្ហាញពីពិធីឡើងសោយរាជ្យមួយ របស់ឥន្ទ្រកុមារ (ព្រះរាជបុត្រារបស់ព្រះបាទជ័យវរ្ម័នទី៧) អភិសេកឱ្យក្លាយជាស្តេចត្រួតត្រាសាមន្តរដ្ឋនៅវិជ័យក្រោមព្រះរាជអធិបតីភាពរបស់ព្រះបាទជ័យវរ្ម័នទី៧ ដោយមានការចូលរួមពីមហេសីមួយចំនួន ពួកព្រាហ្មណ៍ នាម៉ឺនមន្ត្រី ជាមួយនឹងកងទ័ពថ្មើរជើង និងកងទ័ពសេះដែលត្រៀមខ្លួនជាស្រេចដើម្បីចាកចេញឆ្ពោះទៅទិសខាងកើត ហើយត្រូវឆ្លងកាត់ស្ពានបណ្តែតទឹកនេះ (រូបលេខ ៨)។ កងទ័ព និងដំរីដែលស្ថិតលើស្ពាន ស្ថិតក្នុងកាយវិការទ្រឹងស្ងៀម កំពុងរង់ចាំការចាកចេញដំណើររបស់ ឥន្ទ្រកុមារ ឆ្ពោះទៅទិសខាងកើត បន្ទាប់ពីពិធីគ្រងរាជត្រូវបានបញ្ចប់។

នេះគ្រាន់តែការពិចារណាដោយប្រៀបធៀបទៅនឹងរូបផ្សេងៗ ដែលឆ្លាក់នៅលើថែវនៃប្រាសាទបន្ទាយឆ្មារ។ ទោះយ៉ាងណា អ្វីដែលបានលើកយកមកអត្ថាធិប្បាយខាងលើគ្រាន់តែជាការបង្ហាញខ្លីអំពីបេតិកភណ្ឌជាតិខ្មែរមួយប្រភេទដែលបន្សល់ទុកក្រោមស្នាព្រហស្តរបស់មហាព្រះមហាក្សត្រខ្មែរ (The Great King of Cambodia) គឺព្រះបាទជ័យវរ្ម័នទី៧ដែលគេឱ្យព្រះនាមថា«ចក្រពត្រាធិរាជ»។

ស្ពានបណ្តោតទឹក គឺជានិមិត្តរូបនៃសំណង់ ស្ថាបត្យកម្មខ្មែរឆ្លុះបញ្ចាំងពីបច្ចេកទេស ប្រាជ្ញាវាងវៃ និងចំណេះដឹងរបស់បុព្វបុរសខ្មែរពិតប្រាកដ រួមចំណែកក្នុងយុទ្ធសាស្ត្រធ្វើសង្គ្រាមបង្ក្រាបខ្មាំងសត្រូវ។

## ឯកសារយោង


១-Hendrickson, Mitch, (2011) A Transportation Geographic Perspective on Travel and Communication in Angkorian South East Asia (Ninth to Fifteenth Centuries AD), World Archeology, Vol: 43(3).

២-Lusting, Eileen and Hendrickson Mitch (2012), Angkor’s Roads: An Archaeo-Lexical Approach in Connecting Empire: Vol: 2 Chapter: 3.




ផែនទីប្រាសាទបន្ទាយឆ្មារ (ផែនទីដោយ៖ Olivier Cunin)



រូបលេខ ១៖ ស្ពានបណ្តោតទឹក (រូបថត៖ ឡេង សត្យា)



រូបលេខ ២៖ ស្ពានបណ្ដែតទឹក (ពណ៌ក្រហមព្រឿងៗគឺជារចនាសម្ព័ន្ធនៃស្ពានបណ្ដែតទឹក)
(រូបថត៖ ឡេង សត្យា)



រូបលេខ ៣៖ បង្គោលសសរស្ពានខាងកើត



រូបលេខ ៤៖ បង្គោលសសរស្ពានខាងលិច



រូបលេខ ៥៖ ដំរីលើស្ពានបណ្តោតទឹក (រូបថត៖ ឡេង សត្យា)



រូបលេខ ៦៖ ក្រពើដេញខ្លា



រូបលេខ ៧៖ សត្វកំប្រុកនៅលើដើមឫស្សី



រូបលេខ ៨៖ ព្រះបាទជ័យវរ្ម័នទី៧ និង ព្រះរាជបុត្រ «ឥន្ទ្រកុមារ» ក្នុងពិធីអភិសេកព្រះរាជបុត្រ ឱ្យគ្រងរាជជាស្ដេចសាមន្តរដ្ឋ (រូបថតៈ ឡេង សត្យា)



រូបលេខ ៩៖ ចម្លាក់នៅលើថែវខាងជើងដែលមានស្ពានបណ្ដោតទឹក តភ្ជាប់គ្នានឹងចម្លាក់ពិធីអភិសេកព្រះរាជបុត្រ «ឥន្ទ្រកុមារ» ឱ្យគ្រងរាជជាស្ដេចសាមន្តរដ្ឋ(រូបថត៖ ឡេង សត្យា, ជាប្រភេទរូបថត Photogrammetry)

# ហេតុអ្វីត្រូវសិក្សាបុរាណវត្ថុវិទ្យា?

ដោយ ៖ បណ្ឌិត **ផុន កសិកា**
ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសមានអរិយធម៌ចំណាស់ មានសម្បត្តិវប្បធម៌សម្បូរបែប និងមានសក្តានុពលមហិមាលើទេសចរណ៍វប្បធម៌ ដោយកម្ពុជាមានប្រាសាទបុរាណជាច្រើនស្ថិតនៅស្ទើរពាសពេញផ្ទៃប្រទេស។ ប្រាសាទបុរាណដ៏ច្រើនទាំងនោះគឺជាស្ថានីយបុរាណដែលជាធាតុមួយនៃការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញបុរាណវត្ថុវិទ្យា។ ប្រាសាទបុរាណទាំងនោះតម្រូវឱ្យអ្នកជំនាញបុរាណវត្ថុវិទ្យាច្រើននាក់សិក្សាស្រាវជ្រាវឱ្យបានល្អិតល្អន់ និង ស៊ីជម្រៅនៅតាមស្ថានីយបុរាណ ឬ បុរាណដ្ឋានទាំងនោះ និងបំពេញការងារអតិរេក្ស។

នៅប្រទេសកម្ពុជា មុខវិជ្ជាបុរាណវត្ថុវិទ្យាត្រូវបានបណ្តុះបណ្តាលជាលើកដំបូងនៅមហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈក្នុងឆ្នាំ១៩៦៥ និងបានបើកដំណើរការឡើងវិញនៅឆ្នាំ១៩៨៨ បន្ទាប់ពីត្រូវបានបិទអស់រយៈ១៣ឆ្នាំ(១៩៧៥-១៩៨៨) ដោយសារសង្គ្រាមស៊ីវិល។ និស្សិតជំនាញបុរាណវត្ថុវិទ្យាមានចំនួន៣១ ជំនាន់ហើយ ប៉ុន្តែក្នុងមួយជំនាន់ៗមាននិស្សិតយ៉ាងច្រើនត្រឹម៣០នាក់ប៉ុណ្ណោះ។ ជាងនេះទៀត នៅប្រមាណមួយទសវត្សចុងក្រោយនេះហាក់មិនសូវមាននិស្សិតចាប់អារម្មណ៍ក្នុងការសិក្សាមុខជំនាញបុរាណវត្ថុវិទ្យាឡើយ។ និស្សិតចុះឈ្មោះចូលសិក្សានៅមហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមានមិនដល់៣០នាក់ផងក្នុងមួយឆ្នាំៗ(មួយជំនាន់ៗ)។ ការណ៍នេះអាចដោយសារសិស្សនិងនិស្សិតខ្មែរនៅពុំទាន់បានយល់ដឹងស៊ីជម្រៅអំពីគោលបំណងអត្ថប្រយោជន៍និងការងារនៃអ្នកជំនាញបុរាណវត្ថុវិទ្យា។

អត្ថបទដ៏តូចនេះនឹងព្យាយាមបង្ហាញអំពីគោលបំណងនិងអត្ថប្រយោជន៍នៃមុខវិជ្ជាបុរាណវត្ថុវិទ្យាព្រមទាំងស្ថាបនមួយចំនួនសម្រាប់អ្នកជំនាញបុរាណវត្ថុវិទ្យាបំពេញការងារ។

## សារប្រយោជន៍នៃមុខវិជ្ជាបុរាណវត្ថុវិទ្យា

មុខវិជ្ជាបុរាណវត្ថុវិទ្យាមានគោលបំណងសំខាន់ចំនួន៣ គឺ៖ សិក្សាអំពីប្រវត្តិវប្បធម៌កសាងឡើងវិញនូវជីវិតនិងជីវភាពរស់នៅរបស់មនុស្សក្នុងអតីតកាល ពន្យល់អំពីបម្រែបម្រួល

វប្បធម៌និងការធ្វើឱ្យបុរាណវត្ថុវិទ្យាឱ្យមានទំនាក់ទំនងជាមួយបច្ចុប្បន្ន។

ជាមួយគ្នានេះ គោលបំណងនៃបុរាណវត្ថុវិទ្យាគឺចង់ស្វែងយល់អំពីរបៀបនិងមូលហេតុនៃការប្រែប្រួលអាកប្បកិរិយារបស់មនុស្សពីសម័យកាលមួយទៅសម័យកាលមួយទៀត។ អ្នកជំនាញបុរាណវត្ថុវិទ្យាស្រាវជ្រាវអំពីគំរូឬលក្ខណៈនៃការវិវត្តព្រឹត្តិការណ៍វប្បធម៌សំខាន់ៗ ដូចជា ការអភិវឌ្ឍវិស័យកសិកម្ម ការលេចរូបរាងទីក្រុង ការធ្លាក់ចុះនៃអារ្យធម៌ធំៗ។ សំខាន់នោះ គឺអ្នកជំនាញបុរាណវត្ថុវិទ្យាស្រាវជ្រាវអំពីរបៀបដែលអាចទស្សទាយអំពីការប្រែប្រួលនៃវប្បធម៌ ហើយត្រូវមានគម្រោងល្អៗបែបណាដើម្បីអនាគត។ ការស្រាវជ្រាវបុរាណវត្ថុវិទ្យាមិនត្រឹមតែសិក្សាលើអ្វីៗ ដែលរៀបរាប់ខាងលើប៉ុណ្ណោះទេ តែវាថែមទាំងផ្តល់នូវបេតិកណ្ឌ និងប្រវត្តិសាស្ត្រសម្រាប់វប្បធម៌ផ្សេងៗទៀតផង។ យើងនឹងមិនអាចដឹងអំពីការអភិវឌ្ឍវប្បធម៌របស់មនុស្សនៅសម័យបុរេប្រវត្តិបានទេ ប្រសិនបើមិនមានការសិក្សាតាមបែបបុរាណវត្ថុវិទ្យា។ ជាងនេះទៀត បុរាណវត្ថុវិទ្យាបង្ហាញអំពីរូបភាពនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ក្រុមមនុស្សដូចជា អ្នកបម្រើ អ្នករុករករ៉ែ និងកម្មករអន្តោប្រវេសន៍នៅសម័យដំបូងៗ ដែលមិនមានការកត់ត្រាល្អិតល្អន់ពីអ្នកប្រវត្តិសាស្ត្រ។

នៅសម័យបច្ចុប្បន្ន វប្បធម៌មនុស្សត្រូវបានកត់ត្រាស្ទើរគ្រប់ជ្រុងជ្រោយក្នុងសៀវភៅ ការសែត ទូរទស្សន៍ និង អ៊ិនធឺណែត។ ទោះយ៉ាងណា វានៅមានភាពខុសគ្នានូវរបៀបនៃការកត់ត្រា និងអ្វីដែលមនុស្សប្រព្រឹត្តិ។ ទោះបីជាឯកសារស្រាវជ្រាវមានសារសំខាន់ខ្លាំង ប៉ុន្តែនៅតែមានភាពលម្អៀងរវាងជំនឿ និងកំហុសរបស់អ្នកដែលផលិតឯកសារ។ អតីកាលរបស់មនុស្សគឺជាបេតិកកណ្ឌវប្បធម៌ ហើយរបៀបនៃការជ្រើសរើសព័ត៌មានយកមកប្រើប្រាស់សម្រាប់មនុស្សជំនាន់ក្រោយគឺមានតួនាទីសំខាន់សម្រាប់អ្នកជំនាញបុរាណវត្ថុវិទ្យា។ ការយល់ដឹងអំពីលក្ខណៈនិងការប្រែប្រួលអាកប្បកិរិយារបស់មនុស្សធ្វើឱ្យចំណេះដឹងពីអតីតកាលកាន់តែកើនឡើង និងជួយឱ្យយើងមានផែនការ មិនត្រឹមតែនៅពេលអនាគតទេ ប៉ុន្តែសម្រាប់អ្នកជំនាន់ក្រោយដែលត្រូវបន្តវេន។ គេជឿថាបុរាណវត្ថុវិទ្យាមានសារសំខាន់ដើម្បីឱ្យមនុស្សយល់ ការពារ និងឱ្យតម្លៃដល់បេតិកកណ្ឌវប្បធម៌ដ៏សម្បូរបែប និងដោយឡែកៗ។ អ្នកជំនាញបុរាណវត្ថុវិទ្យាទទួលស្គាល់ពីសារប្រយោជន៍នៃតួនាទីនេះ និងកំពុងអភិវឌ្ឍយន្តការផ្សេងៗសម្រាប់ផ្សព្វផ្សាយតាមសារព័ត៌មាន ការបោះពុម្ពផ្សាយតាមអ៊ិនធឺណិត កម្មវិធីសាធារណៈ និងផ្សព្វផ្សាយដល់សាធារណៈជនអំពីអត្ថប្រយោជន៍នៃវិស័យបុរាណវត្ថុវិទ្យា។

ជាងនេះទៀត ថ្មីៗនេះ តួនាទីនៃវិស័យបុរាណវត្ថុវិទ្យាក្នុងការអភិវឌ្ឍប្រទេសជាតិបានក្លាយជាប្រធានបទដ៏ធំមួយ។ បុរាណវត្ថុវិទ្យាមានសក្តានុពលក្នុងទស្សនៈអភិវឌ្ឍ។ វិស័យនេះជួយរួមចំណែកក្នុងគរុសិក្សា ការរីកចម្រើន

សេដ្ឋកិច្ច ការអភិវឌ្ឍសង្គមវប្បធម៌ ការយល់ដឹង និងកំណែទម្រង់នយោបាយ។ ប្រទេសកំពុងអភិវឌ្ឍត្រូវបង្កើនការប្រើប្រាស់ធនធានដើម្បីពង្រីកការស្រាវជ្រាវវិស័យបុរាណវត្ថុវិទ្យា។

បុរាណវត្ថុវិទ្យាផ្តល់ប្រយោជន៍ដល់វិស័យអប់រំ។ ចំណុចសំខាន់បំផុតមួយនៃបុរាណវត្ថុវិទ្យា គឺវាបានផ្តល់នូវព័ត៌មានប្រវត្តិសាស្ត្រស្តីពីសង្គមបុរាណតាំងពីពុំទាន់មានឯកសារជាលាយលក្ខណ៍អក្សរ។ ក្នុងសង្គមខ្លះមានឯកសារប្រវត្តិសាស្ត្រតាំងពី២០០០ ឬ ៣០០០មុន មក ម៉្លេះ ប៉ុន្តែឯកសារប្រវត្តិសាស្ត្រនៅក្នុងសង្គមខ្លះ គឺទើបតែមាន។ បើគ្មានការស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា ប្រវត្តិនៃប្រទេសទាំងនេះនៅតែមានអាថ៌កំបាំង។ បុរាណវត្ថុវិទ្យាក៏មានប្រយោជន៍ ដល់សហគមន៍ដែរ ដោយវប្បធម៌និងអត្តសញ្ញាណជាតិពន្ធុនៃសហគមន៍មួយត្រូវបានអភិរក្សនិងធ្វើឱ្យកាន់តែរឹងមាំ។ នៅទូទាំងពិភពលោក បុរាណវត្ថុវិទ្យាអាចជួយបង្រួបបង្រួមមនុស្សដែលមានបេតិកភណ្ឌរួមបាន។

បុរាណវត្ថុវិទ្យាមានប្រយោជន៍ដល់វិស័យសេដ្ឋកិច្ច។ បុរាណវត្ថុវិទ្យាមានប្រយោជន៍ខ្លាំងណាស់ក្នុងឧស្សាហកម្មទេសចរណ៍ពិភពលោក។ ទេសចរនៅទូទាំងពិភពលោកសម្រុកទៅទស្សនាស្ថានីយបុរាណល្បីៗដូចជា តំបន់អង្គរប្រទេសកម្ពុជា ពីរ៉ាមីតក្នុងប្រទេសអេហ្ស៊ីប ប្រាសាទក្នុងប្រទេសក្រិច ប្រាសាទម៉ាឈូពីឈូ ប្រទេសប៉េរូ និង មហាកំពែងប្រទេសចិន។ សារមន្ទីរមានទេសចរចូលទស្សនាជាប្រចាំថ្ងៃដើម្បីមើលបុរាណវត្ថុដែលដាក់តាំងក្នុងសារមន្ទីរ។ ជារួម មានសេដ្ឋកិច្ចក្នុងសហគមន៍ ក្នុងតំបន់ ក្នុងប្រទេស និងនៅទូទាំងពិភពលោកដែលធ្វើឱ្យចំណូលខាងសេដ្ឋកិច្ចកើនឡើង ហើយដែលចំណូលនេះបានមកដោយសារទេសចរណ៍បុរាណវត្ថុវិទ្យា។

## ស្ថាប័នបំពេញការងារនៃអ្នកជំនាញបុរាណវត្ថុវិទ្យា

### ១-រាជបណ្ឌិត្យសភាកម្ពុជា

រាជបណ្ឌិត្យសភាកម្ពុជាបានបង្កើតឡើងវិញនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ ដែលមានវិទ្យាស្ថានចំនួន៥ ជាសេនាធិការគឺៈ

១-វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

២-វិទ្យាស្ថានមនុស្សសាស្ត្រនិងសង្គមសាស្ត្រ

៣-វិទ្យាស្ថានជីវសាស្ត្រ វិទ្យាសាស្ត្រសុខាភិបាល និង កសិកម្ម

៤-វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា

៥-វិទ្យាស្ថានភាសាជាតិ។

នៅឆ្នាំ២០០៦ រាជបណ្ឌិត្យសភាកម្ពុជាបានបង្កើតវិទ្យាស្ថានមួយទៀតគឺ វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ[1]។

ផ្នែកបុរាណវត្ថុវិទ្យាជាផ្នែកមួយស្ថិតក្នុងវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈដែលបានបង្កើតឡើងដើម្បីសិក្សាស្រាវជ្រាវវិស័យបុរាណ

[1] http://www.rac-academy.edu.kh

វត្ថុវិទ្យា ប្រមូលនិងអភិរក្សទិន្នន័យដែលបានមកពីការស្រាវជ្រាវ សិក្សាកត់ត្រាទុក និងផ្សព្វផ្សាយរបកគំហើញស្រាវជ្រាវ និងបង្កើនកិច្ចសហប្រតិបត្តិការណ៍ជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដែលទាក់ទងការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា។ ផ្នែកបុរាណវត្ថុវិទ្យាបានទទួលជោគជ័យក្នុងការសិក្សាគម្រោងជាច្រើន និងបានរៀបចំសិក្ខាសាលាជាតិ និងសិក្ខាសាលាអន្តរជាតិមួយចំនួនទៀត។ គម្រោងសិក្សាស្រាវជ្រាវនិងការរៀបចំសិក្ខាសាលាទទួលបានការឧបត្ថម្ភថវិកាពីស្ថាបនអន្តរជាតិ ដូចជា មូលនិធិស្ថានទូតអាមេរិក, មជ្ឈមណ្ឌលខេមរសិក្សា (Center for Khmer Studies) អង្គការមិត្តវប្បធម៌ខ្មែរ (Friends of Khmer Culture) និងជាពិសេសទទួលបានការឧបត្ថម្ភពីរាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ២០១៤ រាជបណ្ឌិត្យសភាកម្ពុជា ដោយមានកិច្ចសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ អាជ្ញាធរជាតិព្រះវិហារ គណកម្មាធិការជាតិបេតិកភណ្ឌពិភពលោក បានរៀបចំសិក្ខាសាលាអន្តរជាតិ «សមាគមន៍បុរេប្រវត្តិសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិក លើកទី២០» នៅខេត្តសៀមរាប។

នៅថ្មីៗនេះ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជាក៏កំពុងរួមចំណែកក្នុងការអភិវឌ្ឍដំណើរសិក្សាស្រាវជ្រាវក្នុងវិស័យបុរាណវត្ថុវិទ្យាដែរ។

## ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម័យសង្គមរាស្ត្រនិយម ការងារវប្បធម៌ស្ថិតនៅក្រោមឱវាទនៃក្រសួងសិក្សាធិការ (ក្រសួងអប់រំ)។ សម័យសាធារណរដ្ឋខ្មែរ ទីស្តីការក្រសួង ត្រូវបានបង្កើតឡើង ដែលមានទីតាំងស្ថិតនៅក្នុងព្រះបរមរាជវាំង។ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ទីស្តីការក្រសួងត្រូវបានបង្កើតឡើងជាថ្មី ដែលមានឈ្មោះថា ក្រសួងឃោសនាការ វប្បធម៌ និងព័ត៌មាន។ នៅសម័យព្រះរាជាណាចក្រកម្ពុជា អាណត្តិទី១ នៃរដ្ឋសភា ក្រសួងបានប្តូរឈ្មោះថា ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ[2]។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានមុខងារនិងភារកិច្ចប្រតិបត្តិនូវនយោបាយការពារ ថែរក្សា និងលើក តម្លៃបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅនៃព្រះរាជាណាចក្រកម្ពុជា គ្រប់គ្រងរមណីយដ្ឋានវប្បធម៌ បុរាណវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា[៣]។ អគ្គនាយក ដ្ឋានបេតិកភណ្ឌមានតួនាទីនិងភារកិច្ចថែរក្សាគ្រប់គ្រងរមណីយដ្ឋានវប្បធម៌ បុរាណវិទ្យា នរវិទ្យា និងប្រវត្តិវិទ្យា និងមាននាយកដ្ឋាន៤ប្រតិបត្តិការងារ ដូចជា នាយកដ្ឋានបុរាណវិទ្យានិងបុរេប្រវត្តិ វិទ្យា នាយកដ្ឋានបុរាណវត្ថុ,នាយកដ្ឋានសារមន្ទីរ និងនាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណ។

[2] http://www.mcfa.gov.kh

[៣] អនុក្រឹតលេខ៖ ២៤ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០០៧។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈទទួលគ្រប់គ្រងស្ថានីយបុរាណទាំងអស់ក្នុងទូទាំងប្រទេសកម្ពុជា លើកលែងតែស្ថានីយដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាក្នុងខេត្តសៀមរាប និងស្ថានីយដែលគ្រប់គ្រងដោយអាជ្ញាធរជាតិព្រះវិហារក្នុងខេត្តព្រះវិហារ។គោលបំណងធំមួយរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គឺជំរុញនិងលើកទឹកចិត្តដល់ការស្រាវជ្រាវវិស័យបុរាណវត្ថុវិទ្យា។ អ្នកជំនាញបុរាណវត្ថុវិទ្យាបានលើកទឹកចិត្តឱ្យចូលរួមសហការសិក្សាស្រាវជ្រាវជាមួយដៃគូស្រាវជ្រាវអន្តរជាតិ ដើម្បីសិក្សាស្រាវជ្រាវ ធ្វើកំណាយ អភិរក្ស និងជួសជុល។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈក៏បានចុះបញ្ជីស្ថានីយបុរាណចំនួនជាង៤០០០ ស្ថានីយនៅទូទាំងប្រទេសកម្ពុជា។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈក៏កំពុងចុះយុទ្ធនាការអប់រំខាងបេតិកភណ្ឌដល់ប្រជាពលរដ្ឋនៅតាមខេត្ត រដ្ឋអំណាចមូលដ្ឋាន មន្ត្រីនគរបាល ព្រះសង្ឃ និង សិស្សនិស្សិតឱ្យយល់ពីតម្លៃបេតិកភណ្ឌនិងរួមចំណែកថែរក្សាការពារ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈក៏កំពុងសាងសង់សារមន្ទីរតាមខេត្តដើម្បីទាក់ទាញទេសចរតាមតំបន់ខេត្តនានា។ មួយរយៈពេលកន្លងមក ក្រសួងវប្បធម៌និងវិចិត្រសិល្បៈទទួលបានជោគជ័យក្នុងការទប់ស្កាត់ការបំផ្លាញ ស្ថានីយបុរាណពីសំណាក់ប្រជាពលរដ្ឋ ឬក្រុមហ៊ុនឯកជន។ ប៉ុន្តែទោះយ៉ាងណា ក្រសួងកំពុងប្រឈមជាមួយការបាត់បង់ស្ថានីយបុរាណមួយចំនួនដែរ ដោយសារនៅតែមានការជីកគាស់បំផ្លាញ មានឈ្មួញមានអំណាចនៅតែបន្តការគាស់បំផ្លាញស្ថានីយបុរាណ។

## អាជ្ញាធរជាតិអប្សរា[4]

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ (អាជ្ញាធរជាតិអប្សរា ឬ អ.ជ.អ) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីជាការឆ្លើយតប ជាពិសេសទៅនឹងលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌនានានៃការចុះបញ្ជីរមណីយដ្ឋានអង្គរក្នុងបេតិកភណ្ឌពិភពលោក ដែលបានធ្វើឡើងក្នុងខែធ្នូ ឆ្នាំ១៩៩២ នៅទីក្រុងសាន់តាហ្វេ រដ្ឋញូម៉ិចស៊ិចកូ នៃសហរដ្ឋអាមេរិក។ លើសពីនេះ នៅក្នុងសម័យប្រជុំលើកទី១៩ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក នាខែធ្នូ ឆ្នាំ១៩៩៥ នៅទីក្រុងប៊ែរឡាំង សេចក្តីប្រកាសស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា ដោយរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានទទួលការសាទរ ការពេញចិត្តយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិ។ បេសកកម្មចម្បងៗរបស់អាជ្ញាធរជាតិអប្សរា រួមមាន៖

- ធានាកិច្ចការពារ ការអភិរក្ស និងការលើកតម្លៃសម្បត្តិវប្បធម៌ធម្មជាតិនៅក្នុងតំបន់សៀមរាប-អង្គរ

-បង្កើតនិងដឹកនាំការអភិវឌ្ឍទេសចរណ៍វប្បធម៌នៃតំបន់សៀមរាប-អង្គរ

[4] http://apsaraauthority.gov.kh

- ដឹកនាំសកម្មភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីចូលរួមក្នុងការអនុវត្តគោល នយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា
- បង្កើតភាពជាដៃគូជាមួយអាជ្ញាធរខេត្ត និងអាជ្ញាធរដែនដី
- សហការជាមួយអង្គការ និងស្ថាប័នជាតិ និងអន្តរជាតិនានាដែលមានគោលដៅដូចគ្នានឹង ការងាររបស់អាជ្ញាធរជាតិអប្សរា ហើយដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់សៀមរាបអង្គរ ។

ស្របពេលដែលអង្គរកំពុងក្លាយជាទិសដៅទេសចរណ៍ធំជាងគេ អាជ្ញាធរជាតិអប្សរាបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើគម្រោងទប់ស្កាត់សំណង់ខុសច្បាប់ក្នុងតំបន់អង្គរ។ ការសិក្សាស្រាវជ្រាវផ្នែកបុរាណវត្ថុវិទ្យា និងអភិរក្សប្រាសាទត្រូវធ្វើដោយអាជ្ញាធរជាតិអប្សរា និងមានកិច្ចសហការជាមួយដៃគូអន្តរជាតិផ្សេងៗផង។ ស្ថាប័នដៃគូ អន្តរជាតិត្រូវមានកម្មវិធីបណ្តុះបណ្តាលនិស្សិត និងកិច្ចសហការជាមួយបុគ្គលិកនិងអ្នកជំនាញបម្រើការក្នុងអាជ្ញាធរជាតិអប្សរា។ ក្នុងពេលដែលចំនួនទេសចរកើនឡើង អាជ្ញាធរជាតិអប្សរានឹងទទួលបន្ទុកក្នុងការទទួលខុសត្រូវកាន់តែខ្លាំងជាង មុន។ អាជ្ញាធរនឹងធ្វើឱ្យស្មើភាពគ្នារវាងការជួសជុលអភិរក្ស ការសិក្សាស្រាវជ្រាវជាមួយនឹងតម្រូវការរបស់សហគមន៍ ព្រមទាំងសម្រប សម្រួលតម្រូវការរបស់ទេសចរដែលជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិកម្ពុជា[5]។

## អាជ្ញាធរជាតិព្រះវិហារ[6]

អាជ្ញាធរជាតិព្រះវិហារជាអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ។ អាជ្ញាធរជាតិព្រះវិហារមាននាយកដ្ឋានសេនាធិការចំនួនចំនួន៦ ក្នុងនោះមាន នាយកដ្ឋានបុរាណវិទ្យានិងប្រាសាទ ដែលមានសកម្មភាពក្នុងកិច្ចការស្រាវជ្រាវបុរាណវត្ថុវិទ្យា។

អាជ្ញាធរបានបង្កើតសារមន្ទីរមួយឈ្មោះ «សារមន្ទីរធម្មជាតិសាកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ» សម្រាប់ដាក់តាំងបុរាណវត្ថុដែលរកឃើញ និងបើកទទួលឱ្យទេសចរជាតិនិងអន្តរជាតិចូលទស្សនា ដើម្បីស្វែងយល់ពីវប្បធម៌ និងប្រវត្តិនៅតំបន់ព្រះវិហារ។

## អាជ្ញាធរជាតិសម្បូរព្រៃគុក

អាជ្ញាធរជាតិសំបូរព្រៃគុក គឺជាពាក្យកាត់មកពីពាក្យ «អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក» ដែលជាគ្រឹះស្ថានសាធារណៈបង្កើតឡើង ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨១០ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ និងវិសោធនកម្មទៅជាគ្រឹះស្ថានសាធារណៈរដ្ឋ

5 Carter, A.K. Heng Piphal, Heng Sophady, and **Phon Kaseka**. 2014. ***Archaeology in Post Khmer Rouge Cambodia***. In C. Smith (ed.), *Encyclopedia of Global Archaeology*, pp. 6060-6061. Springer, New York.

6 http://icc-preah-vihear.org

បាលស្ថិតនៅក្រោមអាជណាព្យាបាលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ(លើផ្នែកបច្ចេកទេស) និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (លើផ្នែកហិរញ្ញវត្ថុ) ដោយព្រះរាជក្រឹត្យលេខនស/រកត/០២២០/២០៤ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។ អាជ្ញាធរនេះមានបេសកកម្ម តួនាទី និងការកិច្ចអភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកឲ្យមានចីរភាព។

អាជ្ញាធរជាតិសំបូរព្រៃគុកមាន៦នាយកដ្ឋានដែលជាសេនាធិការ គឺ៖

១. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋានរមណីយដ្ឋាន បុរាណវិទ្យា និងអភិរក្សប្រាសាទ

៣. នាយកដ្ឋានរៀបចំដែនដី លំនៅឋាន និងប្រជាសាស្ត្រ

៤. នាយកដ្ឋានអភិវឌ្ឍទេសចរណ៍

៥. នាយកដ្ឋានទេសភាពវប្បធម៌ និងបរិស្ថាន

៦. នាយកដ្ឋានសណ្តាប់ធ្នាប់

## សេចក្តីសន្និដ្ឋាន

ការលើកឡើងខាងលើបានបង្ហាញថាជំនាញបុរាណវត្ថុវិទ្យាមានសារសំខាន់ខ្លាំងណាស់សម្រាប់កម្ពុជាដែលមានប្រាសាទបុរាណនិងស្ថានីយបុរាណជាច្រើនត្រូវសិក្សាស្រាវជ្រាវនិងអភិរក្ស (ដូចបានលើកឡើងអំពីតួនាទីនិងការកិច្ចនៅតាមស្ថាបនជំនាញមួយចំនួនខាងលើ)។ ដោយកិច្ចការនេះមានតម្លៃធំធេងសម្រាប់ជាតិ រាជរដ្ឋាបាលកម្ពុជាមានតួនាទីនិងការកិច្ចក្នុងការលើកទឹកចិត្តដល់អ្នកជំនាញបុរាណវត្ថុវិទ្យា ដោយការជ្រើសរើសបន្ថែមនូវមន្ត្រីជំនាញបុរាណវត្ថុវិទ្យា និង គាំទ្រគម្រោងផ្នែកបុរាណវត្ថុវិទ្យា ជាដើម ដើម្បីឱ្យសិស្សនិងនិស្សិតមានចំណាប់អារម្មណ៍ក្នុងការសិក្សាជំនាញបុរាណវត្ថុវិទ្យា។

ក្រៅពីកិច្ចការងារនៅតាមស្ថាបនជាតិខាងលើជំនាញបុរាណវត្ថុវិទ្យា គឺមានសារសំខាន់យ៉ាងខ្លាំងសម្រាប់មគ្គុទ្ទេសក៍ទេសចរ ព្រោះប្រាសាទបុរាណដ៏ច្រើននៅកម្ពុជា គឺជាគោលដៅទេសចរណ៍ចម្បងសម្រាប់ទេសចរជាតិ និងអន្តរជាតិ ដែលត្រូវមានអ្នកជំនាញពន្យល់បកស្រាយ។ មគ្គុទ្ទេសក៍ទេសចរដែលបានសិក្សាជំនាញបុរាណវត្ថុវិទ្យា នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិរក្សវប្បធម៌-អរិយធម៌និងប្រវត្តិសាស្ត្រប្រទេសជាតិ។

# ឯកសារពិគ្រោះ

- អនុក្រឹត្យលេខ៖ ២៨ អនក្រ.បក ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧។

- Carter, A.K. Heng Piphal, Heng Sophady, and Phon Kaseka. 2014. ***Archaeology in Post Khmer Rouge Cambodia***. In C. Smith (ed.), *Encyclopedia of Global Archaeology*, pp. 6062-6063. Springer, New York.

- http://www.rac-academy.edu.kh

- http://www.mcfa.gov.kh

- http://apsaraauthority.gov.kh

- http://icc-preah-vihear.org

# ឡុញ ឡាយ៖ បទពិសោធន៍ជិត៣០ឆ្នាំ ជាអ្នកជំនាញកំណាយបុរាណវត្ថុវិទ្យា នៅតំបន់អង្គរ

ដោយ៖ បណ្ឌិត **ផុន កសិកា**
ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងសង្គមសាស្ត្រ
នៃរាជបណ្ឌិត្យសភាកម្ពុជា
Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

ទ្រឹស្តីមួយរបស់លោក Tony Robbins (American author, coach, motivational speaker, and philanthropist.) បានលើកឡើងថា "Repetition is the Mother of Skill" ដែលមានន័យថា ដើម្បីចេះជំនាញអ្វីមួយ យើងត្រូវអនុវត្តឬប្រតិបត្តិជាញឹកញយនិងដដែលៗ ទើបអាចចេះជំនាញនេះពិតប្រាកដៗ មានទ្រឹស្តីមួយទៀតរបស់លោក Albert Einstein លើកឡើងថា «The only source of knowledge is experience» ដែលមានន័យថា ប្រភពនៃចំណេះដឹងទទួលបានពីបទពិសោធន៍។

ជំនាញជាច្រើនត្រូវការអនុវត្តជាប្រចាំ និងប្រើពេលវេលាយូរ មុននឹងទទួលបានជាជំនាញពិតប្រាកដនិងច្បាស់លាស់។ ជំនាញកំណាយក្នុងវិស័យបុរាណវត្ថុវិទ្យាគឺជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវបុរាណវត្ថុវិទ្យា ដែលតម្រូវឱ្យមានការអនុវត្តជាក់ស្តែងនៅរណ្តៅកំណាយ ទើបអ្នកស្រាវជ្រាវចាប់យកជំនាញនិងទទួលបានចំណេះដឹងពិតប្រាកដៗ។

អត្ថបទនេះ ខ្ញុំសូមរៀបរាប់ដោយសង្ខេបអំពីលោក **ឡុញ ឡាយ** ដែលមានជំនាញជាអ្នកកំណាយបុរាណវត្ថុវិទ្យានៅតំបន់អង្គរ ខេត្តសៀមរាប ដោយសារការអនុវត្តកិច្ចការកំណាយអស់រយៈពេលជិត៣០ឆ្នាំ។

## ជីវប្រវត្តិលោក ឡុញ ឡាយ

លោក ឡុញ ឡាយ កើតនៅឆ្នាំ១៩៧៤ នៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។ លោកគឺជាកូនទី២ ក្នុងចំណោមបងប្អូនបង្កើតចំនួន៩ (ប្រាំបួន) នាក់។ បច្ចុប្បន្ន លោកកំពុងរស់នៅភូមិប្រឡាយ ឃុំខ្នាត ស្រុកពួក

*ខេត្តសៀមរាប មានគ្រួសារ និងកូនចំនួន៤នាក់ ប្រុស៣នាក់និងស្រី១នាក់។*

*លោក ឡាយ បានចូលរៀននៅសាលាបឋមសិក្សា នៅឆ្នាំ១៩៨៧ ប៉ុន្តែលោកបានរៀនត្រឹមថ្នាក់ទី២ប៉ុណ្ណោះ ដោយសារស្ថានភាពគ្រួសារមិនអាចបន្តការសិក្សាបានទៀត។*

*លុះដល់ឆ្នាំ១៩៩៤ លោកបានចូលធ្វើការជាមួយអង្គការ* JSA (Japanese Government Team for Safeguarding Angkor ([https://angkor-jsa.org)](https://angkor-jsa.org)) *រហូតដល់ឆ្នាំ២០០៤ ទើបអង្គការ* JSA *រំសាយបុគ្គលិក ដែលមានលោក ឡាយ ក៏ត្រូវរំសាយដែរ។*

*ចាប់ពីឆ្នាំ២០០៤មកដល់បច្ចុប្បន្ន លោក ឡុញ ឡាយ ក៏បានចូលរួមធ្វើកិច្ចការកំណាយជាមួយគម្រោងស្រាវជ្រាវផ្សេងៗ ដែលមកពីប្រទេសអូស្ត្រាលី សហរដ្ឋអាម៉េរិក ប្រទេសបារាំង ជប៉ុន សឹង្ហបូរី និង ជាមួយរាជបណ្ឌិត្យសភាកម្ពុជា។*

## ជាអ្នកជំនាញកំណាយបុរាណវត្ថុវិទ្យា

*អង្គការ* JSA (Japanese Government Team for Safeguarding Angkor) *គឺជាអង្គការរបស់រាជរដ្ឋាភិបាលប្រទេសជប៉ុនសហការណ៍ជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការជួសជុល និង អភិរក្សប្រាសាទក្នុងតំបន់អង្គរ។ កិច្ចការដំបូងរបស់អង្គការនេះគឺការសិក្សាស្រាវជ្រាវ ជួសជុល និង អភិរក្សប្រាសាទបាយ័ន្ត និងប្រាសាទសួរព្រ័ត្រ។ នៅពេលដំបូងៗនោះ អង្គការ*JSA *ជ្រើសរើសបុគ្គលិកខ្មែរចំនួន ១៨០នាក់ ដែលក្នុងនោះ លោក ឡុញ ឡាយ ក៏បានចូលបម្រើការនៅអង្គការ* JSA *នេះ ក្នុងនាមជាបុគ្គលិក។*

*បុគ្គលិកត្រូវបែងចែកជា៣ក្រុម គឺក្រុមបុរាណវិទ្យា ក្រុមជួសជុលប្រាសាទ និងក្រុមវាស់ស្ទង់គូប្លង់។ លោក ឡាយក៏បានបញ្ចូលក្នុងក្រុមបុរាណវិទ្យាផង ក្រុមជួសជុលផង និងក្រុមវាស់ស្ទង់គូរប្លង់ផងដែរ។ ការធ្វើបែបនេះគឺដើម្បីឱ្យបុគ្គលិកម្នាក់ៗបានយល់អំពីការងាររួម និងអាចដោះដូរគ្នាបាន។*

*ក្រោយមកទៀត លោក ឡាយ ក៏ត្រូវបានឱ្យចូលក្នុងក្រុមបុរាណវិទ្យា ដោយចូលរួមធ្វើកំណាយនៅប្រាសាទសួរព្រ័ត្រដែលមានអ្នកជំនាញជនជាតិជប៉ុនជាអ្នកដឹកនាំការងារកំណាយ។*

*នៅឆ្នាំដំបូងៗ លោក ឡាយ គឺ ជាបុគ្គលិកធម្មតាដូចគេឯងពល់គ្នា។ លុះធ្វើការបានមួយរយៈ អ្នកជំនាញជប៉ុនចាប់អារម្មណ៍ការងារកំណាយរបស់លោក ឡាយ ដោយសារគាត់ធ្វើកំណាយបានស្អាត តម្រឹមជញ្ជាំងកំណាយស្អាតនិងត្រង់ល្អ។ ប៉ុន្តែ លោក ឡាយ មិនចេះ*

ភាសាអង់គ្លេស មិនចេះភាសាជប៉ុន គាត់ត្រឹមតែបញ្ចេញកាយវិការបង្ហាញអ្នកជំនាញជប៉ុនៗ ទោះយ៉ាងនេះក្តី អ្នកជំនាញជប៉ុននៅតែចាប់អារម្មណ៍ថា លោក ឡាយ ជាមនុស្សឆ្លាត និងយល់ការងារ។ ក្រោយមក អ្នកជំនាញជប៉ុនក៏ចាប់ផ្តើមសាកល្បងឱ្យគាត់គូរចែកស្រទាប់ដីនៅលើជញ្ជាំងក្នុងរណ្តៅកំណាយ (Soil Layer Classification)។ ការចែកស្រទាប់ដីរបស់គាត់បានត្រឹមត្រូវ ធ្វើឱ្យអ្នកជំនាញជប៉ុនជឿជាក់ថាលោក ឡាយ ឆ្លាត ហើយយល់ការងារ អាចធ្វើកិច្ចការបច្ចេកទេសបានខ្លះៗ។ ដោយឃើញថា លោកឡាយអាចចែកស្រទាប់ដីបាន អ្នកជំនាញជប៉ុនក៏សាកឱ្យគាត់គូរស្រទាប់ដីក្នុងក្រដាសមីលីម៉ែត្របន្ថែមទៀត រហូតគាត់អាចគូរស្រទាប់ដីបញ្ចូលក្នុងក្រដាសបាន។

ក្នុងរដូវធ្វើកំណាយម្តងៗ អង្គការ JSA តែងជ្រើសរើសនិស្សិតមហាវិទ្យាល័យបុរាណវិទ្យា នៃសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ចុះកម្មសិក្សា ហ្វឹកហ្វឺន រៀនសូត្របច្ចេកទេសធ្វើកំណាយ។ នេះក៏ជាឱកាសសម្រាប់លោក ឡាយ បានស្គាល់ប្រាស្រ័យទាក់ទងជាមួយនិស្សិតមហាវិទ្យាបុរាណវិទ្យាផងដែរ។ លោក គង់ វីរៈ(បច្ចុប្បន្នលោក គង់ វីរៈ គឺជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបេតិកភណ្ឌនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ) កាលនោះគឺជាអ្នកជំនាញបុរាណវត្ថុវិទ្យាខ្មែរក៏បានជួយបង្ហាត់ដល់លោក ឡាយ ឱ្យចេះគូរប្លង់រណ្តៅ និងប្លង់បុរាណវត្ថុដែលរកឃើញក្នុងរណ្តៅ (feature)។ ក្រៅពីនោះ នៅមានលោក ហេង ពិគាល់ (លោក ហេង ពិគាល់បានបន្តការសិក្សានៅសាកលវិទ្យាល័យ ហាវ៉ៃ នៃសហរដ្ឋអាម៉េរិក និងទទួលបានសញ្ញាបត្របណ្ឌិតបុរាណវត្ថុវិទ្យា នៅឆ្នាំ២០១៨) ក៏បានជួយពន្យល់អំពីចំណេះដឹងខាងវប្បធម៌ និងជំនាញកំណាយបន្ថែមទៀតដល់លោក ឡាយ ដែរ។

នៅពេលលោក ឡាយ ចេះការងារកំណាយកាន់តែច្រើន អ្នកជំនាញជប៉ុនក៏បញ្ជូនគាត់ឱ្យទទួលកិច្ចការវាស់ស្ទង់ដោយប្រើម៉ាស៊ីន Eye Level Machine តំបន់អង្គរផង និងនៅតំបន់ប្រាសាទកោះកេរផងដែរ។

លោក ឡាយ នៅបន្តកិច្ចការជាអ្នកធ្វើកំណាយនៅប្រាសាទសួរព្រ័តរហូតដល់ឆ្នាំ២០០៤ ទើបលោកឈប់ពីបុគ្គលិកនៃអង្គការ JSA។

ដោយសារ លោក ឡុញ ឡាយ មានជំនាញខាងកំណាយច្បាស់លាស់ ធ្វើការងារដោយភាពអំណត់ ព្រមទាំងទឹកចិត្តស្រឡាញ់ការងារកំណាយ និង ដោយមានការទទួលស្គាល់ពីនិស្សិតបុរាណវិទ្យាដែលបានចុះធ្វើកម្មសិក្សាជាមួយអង្គការ JSA លោក ឡាយ ត្រូវបានគេណែនាំឱ្យចូលរួមធ្វើកំណាយជា

មួយគម្រោងអន្តរជាតិផ្សេងៗ ដូចជា គម្រោងស្រាវជ្រាវនៅប្រាសាទបាសែត ខេត្តបាត់ដំបង ដឹកនាំដោយលោកស្រីបណ្ឌិត Miriam Stark (Director of Southeast Asian Studies, University of Hawaii at Manoa, USA (https://anthropology.manoa.hawaii.edu/miriam-stark/)), គម្រោងស្រាវជ្រាវលំនៅដ្ឋានក្នុងក្រុងអង្គរដែលដឹកនាំដោយលោកស្រីបណ្ឌិត Alison Carter (Assistant Professor at Oregon University, USA (https://anthropology.uoregon.edu/profile/acarter4/)) និងគម្រោងស្រាវជ្រាវបុរាណវត្ថុវិទ្យានៅបន្ទាយ លង្វែក ដឹកនាំដោយលោកបណ្ឌិត Martin Polkinghorne (Senior Lecturer in Archaeology, College of Humanities, Arts and Social Sciences of Flinders University, Australia)។ លោក ឡាយ ក៏ធ្លាប់ចូលរួមធ្វើកំណាយ ស្រាវជ្រាវជាមួយគម្រោងបុរាណវត្ថុវិទ្យា ក្រោមការដឹកនាំរបស់លោក Brice Vincent (នាយកសាលាបារាំងចុងបូព៌ា ខេត្តសៀមរាប ÉFEO, Siem Reap, https://efeo . academia.edu/BriceVincent)។ ក្រៅពីគម្រោងស្រាវជ្រាវខាងលើ នៅមានគម្រោងស្រាវជ្រាវរបស់លោកបណ្ឌិត Dougald O'Reilley ដែលបានធ្វើកំណាយនៅភូមិល្វា តំបន់អង្គរ ខេត្តសៀមរាប (https://archanth.cass.anu.edu.au/people/associate-professor-dougald-oreilly)។ នៅមានគម្រោងអន្តរជាតិមកពីប្រទេសសិង្ហបុរី និងប្រទេសជប៉ុន ដែលលោក ឡាយ បានចូលរួមធ្វើកំណាយ។

នៅឆ្នាំ២០១៩ លោក ឡាយ ត្រូវបានទទួលការអញ្ជើញឱ្យចូលរួមកំណាយស្រាវជ្រាវឡស្លដែកនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

នៅឆ្នាំ២០២០ លោក ឡាយ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមធ្វើកំណាយស្រាវជ្រាវប្រព័ន្ធធារាសាស្ត្រនៅតំបន់បន្ទាយលង្វែក ដែលដឹកនាំដោយរូបខ្ញុំផ្ទាល់(ផុន កសិកា)។ កំណាយស្វែងយល់អំពីប្រព័ន្ធធារាសាស្ត្រនៅតំបន់បន្ទាយលង្វែកតម្រូវឱ្យប្រើគ្រឿងយន្តកាយដី (Excavator) ជាជំនួយព្រោះការងារមានទ្រង់ទ្រាយធំ និងដីកជម្រៅជ្រៅ។ លោក ឡាយ ក៏អាចជួយកិច្ចការក្នុងការបញ្ជាអ្នកបើកគ្រឿងយន្តឱ្យកាយដីតាមបច្ចេកទេសបុរាណវត្ថុវិទ្យាបានដែរ។

ក្រៅពីការអនុវត្តការងារជំនាញធ្វើកំណាយ លោក ឡាយ ក៏តែងជួយពន្យល់អំពីបច្ចេកទេសធ្វើកំណាយដល់និស្សិតបុរាណវិទ្យាដែលចូលរួមការងារជាមួយ និងអ្នកជំនាញបុរាណវត្ថុវិទ្យាក្មេងៗដែលទើបចូលបម្រើការងារ។ រាល់ការធ្វើកំណាយ តែងមានការចូល

រួមពីប្រជាពលរដ្ឋក្នុងតំបន់ធ្វើកំណាយ។ លោក ឡាយ ក៏ជួយពន្យល់អំពីរបៀបធ្វើកំណាយដល់ប្រជាពលរដ្ឋដែលចូលរួមធ្វើកំណាយដែរ។

ក្រៅពីការងារជំនាញ លោក ឡាយ នៅមានគុណសម្បត្តិម៉្យាងដែលពាក់ព័ន្ធនឹងរបៀបធ្វើការងារជាក្រុម (Team Work) និងការចូលក្នុងសហគមន៍ណាមួយដោយមិនមានបញ្ហា ដែលកត្តាទាំងនេះគឺជាចំណុចសំខាន់ដែរក្នុងការប្រតិបត្តិកំណាយបុរាណវត្ថុវិទ្យានៅទីតាំងណាមួយ។

## សន្និដ្ឋាន

លោក ឡុញ ឡាយ គឺជាអ្នកជំនាញធ្វើកំណាយបុរាណវត្ថុវិទ្យាម្នាក់ដែលត្រូវបានស្ថាប័នជាតិ និង អន្តរជាតិទទួលស្គាល់ពីចំណេះជំនាញរបស់លោក។ លោកអាចទទួលកាន់ការងារធ្វើកំណាយបាន ដូចជាៈ ការរៀបចំទីតាំងរណ្តៅកំណាយ ការធ្វើកំណាយ (ជីកតាមបច្ចេកទេសបុរាណវត្ថុវិទ្យា) ការបែងចែកស្រទាប់ដី ការគូរស្រទាប់ដីក្នុងក្រដាស់ ការគូប្លង់បាតរណ្តៅ ការវាស់កម្ពស់រណ្តៅនិងវត្ថុដែលរកឃើញ ព្រមទាំងការពិចារណាអំពីស្ថានភាពរណ្តៅកំណាយ និងស្ថានភាពនៃវត្ថុដែលរកឃើញក្នុងរណ្តៅកំណាយ។ លោក ឡាយ ក៏អាចជួយផ្តល់យោបល់ក្នុងការសម្រេចធ្វើកំណាយទៅតាមស្ថានភាពជាក់ស្តែង។

លោកបានរៀនត្រឹមថ្នាក់ទី២ ស្ទើរតែមិនចេះអានអក្សរផង តែលោកតស៊ូ ព្យាយាមយកចិត្តទុកដាក់នឹងការងារ ចង់ចេះ ចង់ដឹង ត្រងត្រាប់ស្តាប់ការណែនាំពីអ្នកជំនាញបរទេសអ្នកជំនាញខ្មែរ និងនិស្សិតទៀត ទើបលោកអាចរៀនសូត្រទាញយកជំនាញកំណាយបានច្បាស់លាស់។

ជំនាញដែលលោកទទួលបាននេះក៏ដោយសារការអនុវត្តផ្ទាល់ជាច្រើនឆ្នាំណាស់មកហើយ ដូចទ្រឹស្តីដែលនិយាយថា "Repetition is the Mother of Skill"។ ដូចគ្នានឹងទ្រឹស្តីរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា ថា«ធនធានធម្មជាតិប្រើប្រាស់កាន់តែច្រើនកាន់ តែរេចរឹល តែធនធានមនុស្សកាន់តែប្រើកាន់តែរីកចម្រើន»។

នេះចាត់ទុកជាមរតកមនុស្សរស់ម្នាក់ដែលមានជំនាញធ្វើកំណាយច្បាស់លាស់ និងបានបញ្ចេញសមត្ថភាពរបស់ខ្លួនចូលរួមសិក្សាស្រាវជ្រាវដើម្បីស្វែងរកអាថ៌កំបាំងកាលពីអតីតកាលរបស់កម្ពុជា។



លោក ឡុញ ឡាយ ធ្វើកំណាយនៅបន្ទាយលង្វែក ឆ្នាំ២០១៩



លោក ឡុញ ឡាយ ធ្វើកំណាយនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ចុងឆ្នាំ២០១៩





លោក ឡុញ ឡាយ ធ្វើកំណាយនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប ចុងឆ្នាំ





លោក ឡុញ ឡាយ ក្នុងសកម្មភាពគូរប្លង់បាតរណ្ដៅកំណាយ នៅទីតាំងកំណាយប្រព័ន្ធធារាសាស្ត្រនៅ តំបន់បន្ទាយលង្វែក ឆ្នាំ២០២០



លោក ឡុញ ឡាយ ក្នុងសកម្មភាពពិនិត្យការធ្វើកំណាយដោយគ្រឿងយន្ត (excavator) ធ្វើកំណាយប្រព័ន្ធធារាសាស្ត្រ



លោក ឡុញ ឡាយ ក្នុងសកម្មភាពគូរស្រទាប់ដីបញ្ចូលក្នុងក្រដាស នៅទីតាំងកំណាយប្រព័ន្ធធារាសាស្ត្រនៅតំបន់បន្ទាយលង្វែក ឆ្នាំ២០២០

# ចំណោទបញ្ហា

*ដោយ ៖ បណ្ឌិត* **ព្រំ ទេវី**
*អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*សមាជិកបណ្ឌិតសភាចារ្យបម្រុង*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*
Email: promtevy@gmail.com

*ការសរសេរនិក្ខេបបទឬសារណា គឺជាការងារសំខាន់របស់និស្សិតដើម្បីឈានទៅបញ្ចប់ការសិក្សា រីឯការជ្រើសរើសសំណួរស្រាវជ្រាវអាចជាផ្នែកមួយ ដែលពិបាកបំផុតនៅក្នុងកិច្ចការនេះ។ និស្សិតអាចចាប់ផ្តើមគិតថា តើគេជ្រើសរើសប្រធានបទអ្វីដែលសមស្របសម្រាប់ការស្រាវជ្រាវរបស់គេដោយចាប់ផ្តើមពីគំនិតនេះ គេត្រូវរៀបចំឱ្យទៅជាសំណួរដែលអាចស្រាវជ្រាវបាន។*

*សំណួរស្រាវជ្រាវឬចំណោទបញ្ហា គឺជាសំណួរដែលនិស្សិតមានបំណងនឹងស្រាយបំភ្លឺ និងខ្លឹមសារនៃការស្រាយបំភ្លឺនោះជាអត្ថបទនិក្ខេបបទឬសារណាទាំងមូលតែម្តង។ សំណួរដែលនឹងចោទឡើង នេះសុទ្ធតែមានបំណងចង់ឱ្យសង្គមមានការប្រសើរឡើង ទោះជាការស្រាវជ្រាវនោះ នៅក្នុងវិស័យនៃចំណេះដឹងណាមួយក៏ដោយ។*

*លើសពីនេះទៅទៀតចំណោទបញ្ហាមិនមែនជាសំណួរមានលក្ខណៈជាការវាយតម្លៃ និងមិនត្រូវប្រើពាក្យក្នុងន័យអវិជ្ជមានដែរ។ អត្ថបទស្រាវជ្រាវមួយមានចំណោទបញ្ហា ឬសំណួរស្រាវជ្រាវពីរបែប៖ ចំណោទបញ្ហាសំខាន់ និងចំណោទបញ្ហាបន្ទាប់បន្សំ។*

## ចំណោទបញ្ហាសំខាន់

*ចំណោទបញ្ហាសំខាន់ ឬសំណួរស្រាវជ្រាវសំខាន់ជាសំណួរតែមួយគត់ ដែលអ្នកស្រាវជ្រាវត្រូវកត់ត្រាទុកក្នុងចិត្ត បានន័យថាជាអ្វីដែលគេព្យាយាមស្វែងរក ហើយសំណួរនេះហើយដែលជាមូលហេតុនាំឱ្យមានការស្រាវជ្រាវដែរ។ សំណួរតែមួយគត់ នេះមានលក្ខណៈទូលាយ ហើយជាទូទៅគេ មិនអាចស្រាយបំភ្លឺបានទាំងស្រុងទេ។ គម្រោងស្រាវជ្រាវមួយមានចំណោទបញ្ហាសំខាន់តែមួយ*

គត់ ហើយក៏ជាមូលហេតុដែលនាំឱ្យមានគម្រោងស្រាវជ្រាវនេះដែរ។ ចម្លើយនៃចំណោទបញ្ហាសំខាន់ជាខ្លឹមសារនៃនិក្ខេបបទឬអត្ថបទស្រាវជ្រាវទាំងស្រុង។ ឧទាហរណ៍៖ តើសន្ទិសញ្ញាអន្តរជាតិរបស់អង្គការពលកម្មអន្តរជាតិបានរួម ចំណែកអ្វីខ្លះដើម្បីដោះស្រាយបញ្ហាជូនពលករកម្ពុជាដែលកំពុងរស់នៅនិងធ្វើការនៅបរទេស ជាពិសេសស្ត្រីដែលបម្រើការងារតាមផ្ទះ? ឧទាហរណ៍មួយផ្សេងទៀត តើធនាគារពាណិជ្ជអាចចូលរួមចំណែកអ្វីខ្លះក្នុងស្តារឡើងនសេដ្ឋកិច្ចប្រទេសកម្ពុជា ក្រោយពេលចប់ជំងឺរាតត្បាតកូវីដ១៩? ចំពោះសំណួរទាំងអស់នេះ អ្នកស្រាវជ្រាវអាចមានចម្លើយរាប់មិនអស់។

សម្រាប់អ្នកស្រាវជ្រាវដំបូងៗអាចមានការលំបាកខ្លះក្នុងការកំណត់ចំណោទ បញ្ហាសំខាន់នេះ ព្រោះថាក្នុងការសិក្សាពីមុនៗមកអាចមាន ទម្លាប់ភាគច្រើនកំណត់ តែប្រធានបទ ឬចំណងជើងនៃអត្ថបទ ហើយគេចាប់ផ្តើមតែងនិពន្ធអត្ថបទតែម្តង។

**ចំណោទបញ្ហាបន្ទាប់បន្សំ**

យើងឃើញថា ក្នុងសំណួរខាងលើនេះគេអាចមានចម្លើយច្រើនរាប់មិនអស់ទេ។ គួរចងចាំថា ការសរសេរនិក្ខេបបទឬសារណាដើម្បីបញ្ចប់ការសិក្សា ក៏ដូចជាកិច្ចការស្រាវជ្រាវ ជាទូទៅគ្មានអ្នកណាម្នាក់អាចធ្វើហើយអស់ហើយគ្មាននៅសល់អ្វីនោះទេ។ អ្នកដែលអះអាងថា ខ្លួនធ្វើការស្រាវជ្រាវហើយអស់គ្មានអ្វីគួរឱ្យនៅសល់សម្រាប់ធ្វើការស្រាវជ្រាវទៀតទេ គឺជាការយល់ច្រឡំទាំងស្រុងព្រោះថា ការស្រាវជ្រាវ គឺជាកិច្ចការរបស់មនុស្សជាទូទៅក្នុងគោលបំណងចង់ឱ្យសង្គមប្រសើរឡើង ដោយហេតុថាការធ្វើឱ្យប្រសើរឡើងនៃសង្គមរបស់មនុស្សមិនចេះចប់មិនចេះហើយ ដូចនេះការស្រាវជ្រាវក៏មិនចេះចប់មិនចេះហើយដែរ។ បើដូច្នេះនិស្សិតត្រូវធ្វើដូចម្តេចដើម្បីឱ្យគេមើលឃើញថាការសរសេរសារណារបស់គេបានបញ្ចប់? ភារកិច្ចជាបន្តទៀតគេត្រូវកំណត់ចំណោទបញ្ហាបន្ទាប់បន្សំ។

ចំណោទបញ្ហាបន្ទាប់បន្សំនៅក្នុងកិច្ចការស្រាវជ្រាវមួយ ជាសំណួរដែលត្រូវកំណត់ចេញពីចំណោទបញ្ហាសំខាន់មាន

ចំនួនចាប់ពីពីរឡើងទៅមានលក្ខណៈជាក់លាក់ជាងចំណោទបញ្ហាសំខាន់ មានទំនាក់មួយគ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។ ជាទូទៅសំណួរបែបនេះនិស្សិតត្រូវកំណត់ចេញពីចំណោទមានលទ្ធភាពអាចស្រាយបំភ្លឺឱ្យបានទាំងស្រុង។ ក្នុងគម្រោងស្រាវជ្រាវមួយគេអាចកំណត់ចំណោទបញ្ហាបន្ទាប់បន្សំចំនួនប៉ុន្មាន? ជាការពិតណាស់គ្មានអ្នកណាម្នាក់អាចស្រាវជ្រាវអំពីបញ្ហាមួយចប់ទាំងស្រុងនោះទេ។ ពេលវេលាជាកត្តាកំណត់សំខាន់បំផុតចំពោះនិស្សិត និងថវិកាដែលនិស្សិតត្រូវចំណាយសម្រាប់ការប្រមូលទិន្នន័យ។ បើនិស្សិតមានភ័ព្វសំណាងដោយសារប្រធានបទដែលគេស្រាវជ្រាវនោះ អាចជាប្រយោជន៍ដល់ស្ថាប័នណាមួយ ដោយផ្ទាល់ស្ថាប័ននោះអាចផ្តល់ជាថវិកាខ្លះៗក្នុងការស្រាវជ្រាវ របស់និស្សិតដែរ។

-ប្រភពបេក្ខជនបណ្ឌិតភាគច្រើនសុទ្ធតែមានមុខរបររួចទៅហើយមុននឹងត្រឡប់មកសិក្សាថ្នាក់បណ្ឌិត មានបទពិសោធន៍ និងជំនាញផ្សេងៗគ្នា។ ក្នុងតួនាទីជាមេធាវី គេអាចមានសំណួរស្រាវជ្រាវអំពី តួនាទីមេធាវី ជាព្រះសង្ឃអាចមានចំណាប់អារម្មណ៍ចំពោះបញ្ហាសាសនា ការគ្រប់គ្រងវត្តអារាមជាដើម។

ប្រព័ន្ធផ្សព្វផ្សាយក៏មានតួនាទីសំខាន់ក្នុងការផ្តល់គំនិតដំបូងឱ្យអ្នកស្រាវជ្រាវដែរ។ ឧទាហរណ៍ មានការផ្សព្វផ្សាយថា បណ្តាប្រទេសអាស៊ាន និងប្រទេសនៅអាស៊ីបូព៌ាចំនួន៥ (ចិន កូរ៉េខាងត្បូង ជប៉ុន ញូវហ្សេឡែន និងអូស្ត្រាលី) ព្រមព្រៀងគ្នានឹងអនុវត្តពាណិជ្ជកម្មសេរី។ យើងអាចមាន គំនិតថា កម្ពុជាជាប្រទេសសមាជិកអាស៊ានមួយដែរ តើគួរត្រៀមលក្ខណៈអ្វីខ្លះ ដើម្បីឱ្យប្រទេសកម្ពុជាទទួល បានអត្ថប្រយោជន៍ស្មើភាពគ្នានឹងបណ្តាប្រទេសដែលចូលរួមទាំងអស់?

ចំពោះអ្នកស្រាវជ្រាវដំបូងៗ ដែល មិនទាន់មានបទពិសោធន៍ការងារ គេអាចដកស្រង់ចេញពីកង្វះខាតក្នុងស្នាដៃអ្នកស្រាវជ្រាវរបស់អ្នកមុនៗ។ តាមធម្មតាក្នុងស្នាដៃស្រាវជ្រាវនីមួយៗតែងតែមានបញ្ជាក់នូវដែនកំណត់។ តាមរយៈដែន កំណត់នេះហើយ ដែលយើងអាចដឹងថា អ្វីដែលគេបានស្រាវជ្រាវ និងអ្វីដែលមិនទាន់។ មានអត្ថបទស្រាវជ្រាវខ្លះមានការបញ្ជាក់ច្បាស់ៗបន្ថែមទៀត បន្ថែមលើដែនកំណត់នៃការស្រាវជ្រាវជាចំណុចៗតែម្តងដើម្បីឱ្យអ្នកអានបានដឹង ថាតើអ្វីដែលតម្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀត។

*លើសពីនេះទៅទៀត ចំណោទបញ្ហានៃការស្រាវជ្រាវអាចកើតចេញមកពីដំណោះស្រាយបញ្ហាជីវភាពប្រចាំថ្ងៃ ឧទាហរណ៍ ដូចជា តើត្រូវធ្វើដូចម្តេចដើម្បីពង្រីកទីផ្សារ? តើត្រូវរៀបចំគោល នយោបាយដូចម្តេចដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរបស់ប្រជាជនក្រោយចប់វិបត្តកូវីដ-១៩?*

## គោលបំណងនៃចំណោទបញ្ហា

*ទោះជាចំណោទបញ្ហានៃការស្រាវជ្រាវមួយ អាចមានប្រកពច្រើនយ៉ាងណាក៏ដោយ គេអាចកំណត់ព័ត៌មានទាំងនោះជា ៣ក្រុមសំខាន់ៗគឺ៖*

- ***ដើម្បីពង្រឹងចំណេះដឹងមូលដ្ឋាន៖*** *ការស្រាវជ្រាវប្រភេទនេះភាគច្រើនធ្វើឡើងដោយអ្នកស្រាវជ្រាវជំនាញជាសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ ឬនៅបណ្ឌិត្យសភាជាដើម។ ប្រធានបទដែលគេជ្រើសរើសយកភាគច្រើនយ៉ាងហោចណាស់ជាលក្ខណៈជាតិ ឬជាលក្ខណៈសកលតែម្តង ដើម្បីបង្កើតទ្រឹស្តី ឬជាប្រយោជន៍របស់ប្រទេសទាំងមូល ឧទាហរណ៍ ដូចជាការពិចារណាអំពីហេតុអ្វីបានជាវត្ថុតែងធ្លាក់ពីលើ ចុះក្រោមរហូតបានបង្កើតជាច្បាប់ទំនាញផែនដី ឬក៏ការស្វែងរកឯកសារច្បាប់ដើម ពាក់ព័ន្ធនឹងរដ្ឋបាលបារាំងក្នុងនាមជាប្រទេសអាណានិគមដែលបានកំណត់ព្រំប្រទល់ប្រទេសកម្ពុជាជាមួយប្រទេសថៃជាដើម។*

**ដើម្បីដណ្តើមឱកាស៖**

*និស្សិតដែលមិនទាន់មានឱកាសការងារ គេអាចធ្វើការជ្រើសរើសយក ចំណោទបញ្ហាមួយដែលគេចាប់អារម្មណ៍ និស្សិតនោះនឹងក្លាយជាអ្នកឯកទេសម្នាក់ដោយមិនដឹងខ្លួន។ ចំណោទបញ្ហាដូចជា តួនាទីមេធាវីក្នុងក្តីរដ្ឋប្បវេណីកម្មករអន្តោប្រវេសន៍ ពាណិជ្ជកម្មអេឡិចត្រូនិច។ល។ សុទ្ធសឹងតែអាចផ្តល់ឱកាសឱ្យនិស្សិតមានឯកទេសយ៉ាងជាក់លាក់មួយ។ ដូចគ្នាដែរ ចំពោះស្ថាប័ន ឬក្រុមហ៊ុនមួយដែលចង់ក្តាប់ឱកាសទីផ្សារ គេក៏ត្រូវកំណត់ចំណោទបញ្ហាជាក់លាក់សម្រាប់ធ្វើការស្រាវជ្រាវដែរ។*

***-ដើម្បីដោះស្រាយបញ្ហាអ្វីមួយ៖***

*ការបង្កើតចំណោទបញ្ហាដើម្បីដោះស្រាយបញ្ហាមួយ ជាទូទៅត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាដោយឡែករបស់ស្ថាប័ន ឬក្រុមហ៊ុនមួយប៉ុណ្ណោះ អាចនិយាយបានថាជាចំណោទបញ្ហាកម្រិតមីក្រូ។ ចំណោទបញ្ហាមានដូចជា តើត្រូវធ្វើដូចម្តេចដើម្បីផ្តល់សេវាឱ្យអតិថិជនគោលដៅបានប្រសើរ*

ជាងនេះ? ឬមួយក៏ តើត្រូវធ្វើដូចម្តេចដើម្បីរៀបចំប្រព័ន្ធសិក្សាពីចម្ងាយឱ្យបានដល់សិស្សគ្រប់រូបក្នុងកំលុងពេលមានវិបត្តកូវីដ-១៩?

-ឧទាហរណ៍នៃដំណើរការកំណត់ចំណោទបញ្ហាពុំមានរូបមន្តឬក្បួនខ្នាតណាមួយច្បាស់លាស់ ថាតើនិស្សិតត្រូវកំណត់ឡើងដោយវិធីណាទេ។ ខាងក្រោមនេះជាជំហាននៃដំណើរការកំណត់ចំណោទបញ្ហា។

**-ជ្រើសរើសវិស័យណាមួយដែលអ្នកពេញចិត្ត៖** បន្ទាប់ពីជ្រើសរើសវិស័យណាមួយហើយ និស្សិតត្រូវបំបែកជាផ្នែកតូចៗបន្តទៀត។ ឧបមាថា វិស័យដែលគេពេញចិត្តគឺ មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម។

**-បំបែកជាអនុវិស័យ៖** បំបែកវិស័យនៃការសិក្សាដ៏ទូលំទូលាយមួយឧទាហរណ៍ មីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម (Micro- Small and Medium Enterprises: MSMEs) ជាអនុវិស័យតូចៗ យើងបាន ដូចជា ទិដ្ឋភាពនៃការចុះបញ្ជី ការគ្រប់គ្រងសហ គ្រាសប្រភេទនៃប្រតិបត្តិការ និងដំណើរការអភិវឌ្ឍន៍ ការចងក្រងជាបណ្តាញគោលនយោបាយគាំទ្រមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម ជាដើម។

**-ជ្រើសរើសអនុវិស័យទាំងឡាយដែលអ្នកពេញចិត្តយកមកធ្វើការសិក្សា៖** និស្សិត ឬអ្នកស្រាវជ្រាវថ្មីតែងតែគិតថា ការកំណត់អនុវិស័យជាការលំបាក។ ចំណង់ចំណូលចិត្ត ការអានឯកសារ សមត្ថភាព និងមានពេលវេលាគ្រប់គ្រាន់ ជាលក្ខខណ្ឌអនុញ្ញាតឱ្យការសិក្សាទៅលើអនុវិស័យទាំងនោះធ្វើទៅកើត។ ទោះជាយ៉ាងណាក៏ដោយ និស្សិតត្រូវជ្រើសរើសយកតែអនុវិស័យទាំងឡាយណា ដែលអាចយកមកសិក្សាបានក្នុងកំលុងពេលចំនួនថវិកា និងសមត្ថភាពដែលមាន។ របៀបមួយនៃការជ្រើសរើសគឺចាប់ផ្តើមពីការជម្រុះចោល បានន័យថាលុបចោលនូវផ្នែកណាដែលអ្នកមិនពេញចិត្តជាទីបំផុត។ ចុងបញ្ចប់អ្នកស្រាវជ្រាវអាចជ្រើសរើសបាននូវអនុវិស័យដែលគេមានការពេញចិត្តនិងអាចគ្រប់គ្រងបាន។ ទោះជាយ៉ាងណាក៏ដោយ អនុវិស័យមួយក៏អាចមានតម្លៃគ្រប់គ្រាន់និងអាចជាការសិក្សាយ៉ាងទូលំទូលាយបានដែរ។

ក្នុងចំណោមអនុវិស័យដែលបំបែកពីមុនមកឧទាហរណ៍មានចំនួន៥ កាត់យកត្រឹមតែ៣ ដែលយើងពេញចិត្តជាងគេបង្អស់រួមមាន៖ ១)ការគ្រប់គ្រងសហគ្រាស MSM-

Es ២) *ការចងក្រងជាបណ្តាញ* MSMEs *និង* ៣) *គោលនយោបាយគាំទ្រ* MSMEs។

***-អនុវិស័យដែលអាចធ្វើការស្រាវជ្រាវបាន៖*** *ក្នុងចំណោមអនុវិស័យខាងលើដែលយើងកំណត់ថាពេញចិត្តនោះ តើយើងអាចបង្កើតជាសំណួរស្រាវជ្រាវអ្វីខ្លះ ដែលអ្នករំពឹងថានឹងអាចឆ្លើយបាន? សូមធ្វើឱ្យលម្អិតតាមដែលអ្នកអាចធ្វើបាន។ បើសិនជាអនុវិស័យដែលយើងពេញចិត្តនោះ បែរជាមិនអាចបង្កើតសំណួរស្រាវជ្រាវបាន អ្នកស្រាវជ្រាវអាចផ្លាស់ប្តូរបាន។ ចំពោះអនុវិស័យការគ្រប់គ្រងសហគ្រាស* MSMEs *យើងអាចកំណត់សំណួរស្រាវជ្រាវបានដូចជា៖*

*-តើរាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយយ៉ាងណាខ្លះ ដើម្បីគ្រប់គ្រង* MSMEs?

*-តើ* MSMEs *នៅកម្ពុជាមានផែនការអ្វីខ្លះដើម្បីត្រៀមខ្លួនចូលរួមចំណែកក្នុងការធ្វើពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់?*

*-តើ* MSMEs *នៅកម្ពុជាមានផែនការអភិវឌ្ឍធនធានមនុស្សដូចម្តេចខ្លះ?*

- *តើ* MSMEs................

# ច្បាប់ និង ឥរិយាបថរបស់មនុស្ស

Law and Human Attitude

*ដោយៈ បណ្ឌិត* **អ៊ុំ ប៉ុម**
*ជំនួយការ រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*នៅលើពិភពលោកយើងនេះ គេសង្កេតឃើញមានភាវៈគួរឱ្យកត់សម្គាល់បួនយ៉ាងគឺ មនុស្ស សត្វ រុក្ខជាតិ និងរ៉ែធម្មជាតិ ហើយក្នុងចំណោមភាវៈទាំងបួននេះទៀតសោតភាវៈ "មនុស្ស" មាននៅជាប់នឹងខ្លួននូវរបស់ពិសេសម្យ៉ាងដែលភាវៈដទៃទៀតគ្មាននោះគឺ "វិចារណញ្ញាណ" សម្រាប់គិតពិចារណាទៅលើអ្វីៗទាំងអស់ ដែលបានជួបប្រទះក៏ដូចជាទៅលើអំពើប្រព្រឹត្តរបស់ខ្លួន។ ជាងនេះទៅទៀត ក្នុងដំណើរអត្ថិភាពនៅលើភពផែនដីយើងនេះ មនុស្សដើរតួជាអ្នកតាក់តែងច្បាប់សម្រាប់សង្គមផង ហើយក៏ជាកម្មវត្ថុនៃការគិតពិចារណាចំពោះការតាក់តែងច្បាប់ផង។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏ក្នុងដំណើរអនុវត្តនូវតួនាទីរបស់ខ្លួនជាកម្មវត្ថុរបស់ច្បាប់ក៏មានប្រភេទមនុស្សខ្លះយល់បានត្រឹមត្រូវអំពីច្បាប់ លើកតម្កើងច្បាប់ដាក់ចិត្តដាក់កាយគោរពច្បាប់និងចាត់ទុក ច្បាប់ជំជាងបុគ្គលខ្លួនឯង។ ម្ល៉ោះហើយ ព្រោះតែឥរិយាបថភ្ញាក់រលឹកបែបនេះ គេក៏បានសុខស្រួលក្នុងដំណើរជីវិតរស់នៅជាមួយនឹងសង្គមដែលគេកំពុងតែចូលរួមប្រាស្រ័យ។ ផ្ទុយទៅវិញ ក្នុងដំណើរអត្ថិភាពរបស់មនុស្សដដែល គេក៏សង្កេតឃើញមានប្រភេទមនុស្សខ្លះទៀតយល់មិនបានត្រឹមត្រូវអំពីច្បាប់មើលស្រាលច្បាប់ មិនបានផ្សារភ្ជាប់ខ្លួនជាមួយច្បាប់ ចង់តែប្រព្រឹត្តនូវអ្វីៗទៅតាមទំនើងចិត្តនឹកឃើញ ធ្វើអ្វីៗផ្ទុយពីការកំណត់របស់ច្បាប់តំណាងឆន្ទៈរួមរបស់មនុស្សក្នុងសង្គមដែលគេកំពុងរស់នៅ។ ម្ល៉ោះហើយ ដោយសារតែអាកប្បកិរិយាភ័ន្តច្រឡំបែបនេះ គេក៏ពុំបានសុខស្រួលឡើយហើយព្រមទាំងជួបប្រទះនឹងការដាក់ទណ្ឌកម្មត្រឡប់វិញពីសំណាក់ អាជ្ញាធរទៅតាមកម្រិតនៃអំពើខុសឆ្គងរបស់គេថែមទៀតផង។*

*សំណួរអាចចោទសួរថា តើហេតុអ្វីបានជាមានបាតុភាពជាឥរិយាបថពីរប្រភេទផ្ទុយគ្នាបែបនេះ កើតឡើងចំពោះមនុស្សក្នុងសង្គម? តើត្រូវធ្វើបែបណាដើម្បីឲ្យមនុស្សផ្លាស់ប្ដូរឥរិយាបថរបស់ខ្លួនពីឥរិយាបថអវិជ្ជមានហើយបែរត្រឡប់ទៅរកឥរិយាបថបែបវិជ្ជមាន ស្របទៅតាមអ្វីដែលច្បាប់ចង់បាន?*

ទាំងអស់នេះ គឺជាបញ្ហាចោទដ៏ស្មុគស្មាញសម្រាប់យើងទាំងអស់គ្នាដើម្បីសាកល្បងស្វែងរកចម្លើយប្រកបដោយសុភនិច្ឆ័យហើយរួមគ្នាដោះស្រាយនូវហេតុភេទដែលតែងតែកើតមានឡើងបែបនេះក្នុងឥរិយាបថរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ។ ប៉ុន្តែដើម្បីមានមូលដ្ឋានរឹងមាំនឹងដោះស្រាយនូវបញ្ហាដូចពោលខាងលើនេះ យើងគប្បីត្រឡប់មកសិក្សាស្វែងយល់រួមគ្នាជាមុន អំពីថាតើអ្វីទៅដែលហៅថាច្បាប់? ច្បាប់មានប្រភពមកពីណា? ច្បាប់មានតួនាទីអ្វីខ្លះចំពោះសង្គម?

## ១- តើច្បាប់ជាអ្វី?

មាននិយមន័យមួយចំនួនដែលខ្ញុំបានស្រាវជ្រាវឃើញហើយសូមលើកយកមកបញ្ជាក់ជូននៅពេលនេះ ទាក់ទងទៅនឹងសំណួរដែលលើកឡើងថា តើច្បាប់ជាអ្វី?

### ១.១-និយមន័យច្បាប់តាមរយៈវចនានុក្រម

ក-វចនានុក្រមរបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត បោះពុម្ពគ្រាទី៥ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧ ត្រង់ទំព័រ២១៥ បានឲ្យនិយមន័យស្ដីពី "ច្បាប់" បែបនេះថា "ច្បាប់ជាវិន័យ ជាក្រិត្យក្រមជាក្បួនប្រដៅមនុស្សទាំងអស់នៅក្នុងនគរអនុវត្តតាម ដើម្បីឈានឆ្ពោះទៅរកអំពើប្រព្រឹត្តល្អត្រឹមត្រូវតាមគន្លង"។

ខ-ចំពោះវចនានុក្រមអុកស្វតអឺដវ៉ាន់លើនើយ (Oxford Advanced Learner's) បោះពុម្ពឆ្នាំ ២០០៣ ត្រង់ទំព័រ៧៨៦ បានលើកឡើងជានិយមន័យសាមញ្ញបែបនេះថា ច្បាប់ជាវិធានផ្លូវការរបស់ប្រទេសមួយឬរដ្ឋមួយ លើកឡើងពីអ្វីដែលប្រជាជនត្រូវធ្វើឬមិនត្រូវធ្វើ(Law is an official rule of a country or state that says what people may do or may not do)។

បើតាមនិយមន័យខាងលើនេះ ច្បាប់គឺជាវិន័យ ជាក្រិត្យក្រម ជាក្បួនប្រដៅឬជាវិធានផ្លូវការរបស់ ប្រទេសនីមួយៗបង្ហាញប្រាប់ប្រជាជន ពីអ្វីដែលត្រូវធ្វើនិងអ្វីដែលមិនត្រូវធ្វើ ឈានឆ្ពោះទៅរកអំពើប្រព្រឹត្តល្អ អំពើដែលមានផលប្រយោជន៍ មានវឌ្ឍនភាពសម្រាប់សង្គម។ ផ្ទុយទៅវិញ អ្វីដែលមិនត្រូវធ្វើនោះ គឺជាកាយវិការ ដែលឈានឆ្ពោះទៅរកអំពើអាក្រក់ អំពើអសីលធម៌ គ្មានផលប្រយោជន៍ និងប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈក៏ដូចជា របៀបរៀបរយសង្គម ព្រមទាំងធ្វើឲ្យសង្គមមានឧបសគ្គមិនអាចរីកចំរើនទៅមុខដោយរលូនបាន។

### ១.២-និយមន័យច្បាប់តាមរយៈការគិតរបស់ទស្សនវិទូនយោបាយមួយចំនួន

#### ១.២.១-ទស្សនៈរបស់ស៊ីសេរ៉ុង (១០៦-៤៣មុនគ.ស)

បើតាមលោកស៊ីសេរ៉ុង (Cicéron) ជាទស្សនវិទូនយោបាយដ៏ឆ្នើមប្រចាំទីក្រុងរ៉ូម បានលើកឡើងពី និយមន័យរបស់ច្បាប់ យ៉ាងដូច្នេះថា"ច្បាប់គឺជាការបែងចែករវាងអ្វីដែលត្រូវនិងអ្វីដែលខុស" (Law is the distin-ction between thing just and unjust)។ បើតាមនិយមន័យនេះ យើងអាចចោទសួរថា តើអ្វីទៅដែលអាចឱ្យគេ បែងចែកបាន រវាង "ត្រូវ"និង"ខុស"?។ បើតាមទស្សនៈផ្ទាល់របស់លោក អ្វីដែលធ្វើឲ្យមនុស្សបែងចែកបានរវាងត្រូវនិងខុសគឺ "វិចារណញ្ញាណ" នោះឯង។ ប៉ុន្តែទោះជាយ៉ាងនេះក្តី លោកក៏នៅតែមិន អស់ចិត្ត ខ្លាចក្រែងមានការយល់ច្រឡំចំពោះពាក្យ"វិចារណញ្ញាណ" ពីព្រោះវិចារណញ្ញាណរបស់មនុស្ស អាចមានត្រូវផងនិងខុសផងពោលគឺពុំមានលក្ខណៈត្រឹមត្រូវជាសកលនោះឡើយ។ ដូច្នេះហើយបានជាលោកបន្ថែមពាក្យ"ត្រឹមត្រូវ"នៅក្នុងនិយមន័យថ្មីមួយទៀតរបស់លោកថា "ច្បាប់គឺជាវិចារណញ្ញាណត្រឹមត្រូវ" (Law is the right reason) បានសេចក្តីថា ច្បាប់នោះត្រឹមត្រូវគ្រប់លំហ ទីឋានភូមិសាស្ត្រ និងគ្រប់កាលវេលាទាំងអស់។ ជាចុងក្រោយ លោកបានបញ្ចប់និយមន័យរបស់ច្បាប់ ដោយពិចារណាប្រៀបធៀបច្បាប់ទៅនឹង មនុស្សដែលជាភាវៈរស់តាមនិយមន័យមួយបែបទៀតថា"ច្បាប់គឺជាចៅក្រមដ៏ស្ងៀមស្ងាត់" (Law is a silent magistrate)។ បើតាមទស្សនៈនេះ ច្បាប់ពឹងពាក់ខ្លួនទាំងស្រុងទៅលើ ចៅក្រមដែលជាមនុស្សមានវិញ្ញាណឱ្យនិយាយជួសខ្លួនឬនិយាយផ្ទុយមកវិញថា "ចៅក្រមគឺជាច្បាប់ចេះនិយាយ"(Magistrate is a speaking Law)។ ទស្សនៈចុងក្រោយនេះ សបញ្ជាក់ឱ្យឃើញថា បើចៅក្រមដែលជាអ្នកអនុវត្តច្បាប់មានគុណសម្បត្តិល្អ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈខ្ពស់តំណាងយុត្តិធម៌ពិតប្រាកដ អាចឱ្យធ្លុះបញ្ចាំងត្រឡប់វិញថាច្បាប់នោះល្អ។ ផ្ទុយទៅវិញ បើចៅក្រមជាមនុស្សមិនប្រកបដោយគុណធម៌ ខ្វះសីលធម៌វិជ្ជាជីវៈជាចៅក្រម ច្បាប់នោះ**អាច**ត្រូវបានគេមើលឃើញថា ជារបស់ឥតបានការអាក្រក់ជួរជាតិគួរឱ្យស្អប់ខ្ពើមនិងមិនគួរឲ្យគោរពទៅវិញ។ ដូច្នេះបើតាមទស្សនៈខាងលើច្បាប់មានលក្ខណៈអាក្រក់ឬល្អ អាស្រ័យទៅលើចៅក្រមដែលដើរតួនាទីជាប្រធានវិស័យ និងជាអ្នកកំណត់ ដូចដែលលោកស៊ី សេរ៉ុង ធ្លាប់បានរំលឹកដាស់តឿនយើងនិងទាញអារម្មណ៍ពួកយើងឱ្យយក ចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់ទៅលើប្រធានវិស័យមួយនេះ ដើម្បីកុំឱ្យជះឥទ្ធិពលអាក្រក់ដល់ តម្លៃពិតរបស់ច្បាប់បង្កបានទៅជាអំពើ ឬសកម្មភាពមិនគោរពច្បាប់របស់មនុស្សភាគច្រើននៅក្នុងសង្គម។ ប៉ុន្តែ បើគេគិតមកសង្គមបច្ចុប្បន្ន ក្នុងសតវត្សរ៍យើងនេះវិញ ច្បាប់ល្អឬមិនល្អ អាចអាស្រ័យ

បន្ថែមទៀតទៅលើ និទ្ទាការនយោបាយនៃអ្នកតាក់តែងច្បាប់ក៏ដូចជា អាជ្ញាធរដែលជាអ្នកអនុវត្តច្បាប់។ ផ្សារភ្ជាប់នឹងបែបផែននៃការជះឥទ្ធិពលទៅលើ គុណតម្លៃរបស់ច្បាប់តាមរយៈចរិតលក្ខណៈទាំងបីរបស់ច្បាប់ ដូចលោកសាំងថូម៉ាស់ អាក្វាយ នើស (Saint Thomas Aquinas) មេដឹកនាំសាសនាគ្រឹស្តក្នុងសតវត្សរ៍ទី១៣ ធ្លាប់បានបញ្ជាក់អះអាងរួចមកហើយតាមរយៈឃ្លាដ៏មានតម្លៃទាំងបីរបស់លោកយ៉ាង នេះថា"ច្បាប់ត្រូវអនុម័តទៅតាមវិធានមួយចំនួនរបស់វិចារណញ្ញាណ ច្បាប់ត្រូវតែត្រឹមត្រូវនិងស៊ីសង្វាក់គ្នាជារួមជាមួយនឹងអំពើល្អ"ច្បាប់ត្រូវមានធម្មានុរូបភាព(Legitimacy) ឬភាពត្រឹមត្រូវតាមច្បាប់។

## ២- ប្រភពនៃច្បាប់

ជាទូទៅ អ្វីៗទាំងអស់ដែលកើតមកលើលោកយើងនេះ សុទ្ធតែមានប្រភពរបស់វា។ យ៉ាងណាមិញបើ គេពិចារណាមកលើច្បាប់វិញ តើគេយល់ឃើញបែបណាដែរ?

មកដល់ត្រង់ចំណុចនេះ យើងគប្បីរំលឹកទៅដល់ទស្សនៈរបស់ ម៉ុងតេសគីយើ (១៦៨៩-១៧៥៦)។ ទស្សនវិទូនយោបាយរូបនេះ បានអះអាងថា "ភាវៈទាំងអស់ដែលឋិតនៅលើភពផែនដីយើងនេះសុទ្ធតែមាន ច្បាប់" បានន័យថា អាទិទេពក៏មានច្បាប់ មនុស្សមានបញ្ញា មនុស្សសាមញ្ញធម្មតាក៏មានច្បាប់សត្វក៏មានច្បាប់។ បើនិយាយយោងទៅលើប្រភពវិញ លោកបានបញ្ជាក់បន្ថែមថា ច្បាប់មានប្រភពចេញមកពីមូលហេតុពីរយ៉ាងគឺ កាយមូលហេតុ(Physical cause) និងសីលមូលហេតុ(Moral Cause)។ ចំពោះប្រភពជាកាយមូល ហេតុនៅទីនេះ លោកចង់ផ្តោតជាសំខាន់ទៅលើកត្តាមួយចំនួនរួមមានៈ មនុស្ស (សំខាន់គឺចរិតមនុស្ស) ទឹកដី អាកាសធាតុ ទីតាំងភូមិសាស្ត្រ សង្គមបរិយាកាស ប្រវត្តិសាស្ត្រ វប្បធម៌និងជំនាញឯកទេស។ ប្រសិនបើអ្វីទាំងនោះ ខុសគ្នាឬមានស្ថានភាពបែបណា ច្បាប់ក៏មានលក្ខណៈបែបនោះដែរ ដោយហេតុថា មនុស្សជាកម្មវត្ថុ និងជាអ្នកតាក់តែងច្បាប់បានទទួលឥទ្ធិពលពីអ្វីទាំងឡាយនោះហើយដែលអ្វីទាំងអស់នោះស្ថិតក្នុងកាលវេលា និងលំហជាមួយគ្នា។

រីឯប្រភពជាសីលមូលហេតុវិញ គឺជាប្រភពដែលចេញមកពីមូលហេតុទាក់ទងទៅនឹងស្មារតី ឬព្រលឹង របស់មនុស្សគ្រប់ៗរូប។ ស្មារតីឬព្រលឹងនោះតែងជះឥទ្ធិពលខ្លាំងក្លាទៅលើការបង្កើតច្បាប់នៃប្រទេសនីមួយៗ។ ឧបមាថា បើស្មារតីឬព្រលឹងនោះ ជាស្មារតីឬព្រលឹងប្រកបដោយសុចន្ទៈរបស់ពពួកអភិជនាធិបតេយ្យដែលធ្វើអ្វីៗ តែងតែគិតគូរដល់ផលប្រយោជន៍ជាតិ ច្បាប់ដែលបង្កើតឡើងក៏មានលក្ខណៈបែបនោះដែរ។ ផ្ទុយទៅវិញ បើស្មារតីឬព្រលឹងនោះ ជារបស់ពួក

*អប្បជនាធិបតេយ្យ ដែលប្រកាន់រឹងមាំទៅលើផលប្រយោជន៍របស់ក្រុម គេមួយក្ដាប់តូចនោះ ច្បាប់ដែលតាក់តែងចេញមក ក៏មានសភាពបែបនោះដែរ។*




ឥទ្ធិពលនៃកាយមូលហេតុមកលើច្បាប់
តាមគំនិតរបស់ម៉ុង

## ៣- ប្រភេទនៃច្បាប់

*ទន្ទឹមនឹងការរៀបរាប់ពីប្រភេទច្រើនយ៉ាងរបស់ច្បាប់រួមមាន ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់ នយោបាយ ច្បាប់បរិស្ថាន ច្បាប់បញ្ញា ច្បាប់គតិយុត្ត... លោកបានបង្រួមច្បាប់ទាំងអស់នោះឲ្យរួមចូលគ្នាមក នៅត្រឹមចំណុចដែលថា ច្បាប់មានពីរប្រភេទតែប៉ុណ្ណោះគឺ ច្បាប់ពិភពរូបវន្ត និងច្បាប់ពិភពបញ្ញា។ តើច្បាប់ពិភពទាំងពីរនេះមានន័យដូចម្ដេច?*

### *៣.១-ច្បាប់ពិភពរូបវន្ត*

*ច្បាប់ពិភពរូបវន្ត គឺជាច្បាប់ដែលគ្រប់គ្រងពិភពរូបធាតុទាំងអស់នៅលើផែនដីយើងនេះ។ ដោយឡែកបើនិយាយទាក់ទងទៅនឹងចរិតលក្ខណៈវិញ ច្បាប់ប្រភេទនេះត្រូវបានគេពន្យល់បន្ថែមបែបនេះថា ច្បាប់ពិភព រូបវន្តគឺជាច្បាប់ទំនាក់ទំនង គឺជាច្បាប់ពិពណ៌នានូវអ្វីដែលមានពិតក្នុងពិភព" លោកសច្ចៈ"ហើយច្បាប់នេះ មានចរិតលក្ខណៈពិសេសខុសប្លែកពីច្បាប់ដទៃទៀត នៅត្រង់ថាជា"ច្បាប់ធម្មជាតិ"* (Natural Law) *ហើយក៏ជាច្បាប់ដែលមិនចេះប្រែប្រួលសោះឡើយ។*

### *៣.២- ច្បាប់ពិភពបញ្ញា*

*ច្បាប់ពិភពបញ្ញា ជាច្បាប់ដែលកើតចេញពីសមត្ថភាពនៃខួរក្បាលរបស់មនុស្ស។ បានន័យថា បើសមត្ថភាពនៃការគិតរបស់មនុស្សបានត្រឹមកម្រិតណាច្បាប់នោះក៏មានកម្រិតត្រឹមប៉ុណ្ណោះដែរ ហើយក៏អាចកើតមានករណីជាការគិតដោយមិនបានប្រមើលមើលវែងឆ្ងាយជាមុនឬជាការគិតមិនបានគ្រប់ជ្រុងជ្រោយឬក៏ អាចជាការគិតដោយផ្អែកលើចរិតលក្ខណៈរបស់ក្រុមមនុស្សទាំងពីរប្រភេទ ដូចបានរៀបរាប់ពីខាងដើមរួចមក ហើយ។ ដូច្នេះហើយបានជាក្នុងនិយមន័យស្ដីពីច្បាប់ ម៉ុងតេសគីយើ បានសង្កត់ធ្ងន់ថា "ច្បាប់ជាចំណងទាក់ ទងទាំងឡាយ*

ចេញមកពីអ្វីដែលមាននិងពីអ្វីដែលនឹងកើតមានឡើង" ហើយផ្ទុយពីច្បាប់ពិភពរូបវ័ន្ត ច្បាប់ ប្រភេទទីពីរនេះអាចមានចរិតជាច្បាប់ប្រែប្រួល ព្រមទាំងអាចមានការភ័ន្តច្រឡំថែមទៀតផង ពីព្រោះច្បាប់នេះស្ថិតក្រោមអំណាចនៃតណ្ហារបស់មនុស្ស។ ដូច្នេះ ដោយសារតែតណ្ហាញាំញី មនុស្សគិតពីអ្វីៗតែងមានភាពលម្អៀងនិងភ័ន្តច្រឡំ។ ឧបមាថា បើច្បាប់នោះតាក់តែងឡើងដោយជំពូកជនដែលមានតណ្ហាក្រាស់ ដូចជាក្រុម អប្បជនាធិបតេយ្យដែលគ្រប់គ្រងប្រទេសដោយមិនខ្វល់ខ្វាយពីសុខទុក្ខរបស់ប្រជាជន ច្បាប់ដែលបង្កើតឡើង ដោយក្រុមនោះច្បាស់ជាធ្លាក់ក្នុងសភាពការពារផលប្រយោជន៍តែម្យ៉ាងរបស់ក្រុមគេជាក់ជាមិនខាន។

ដូច្នេះហើយបានជាក្នុងសម័យបច្ចុប្បន្ន ដើម្បីជៀសវាងពីផលប៉ះពាល់ធ្ងន់ធ្ងរបែបនេះមុននឹងដាក់ច្បាប់មួយឱ្យដំណើរការជាផ្លូវការទៅបាន ច្បាប់នោះត្រូវដាក់ឆ្លងស្ថាប័នទទួលខុសត្រូវជាច្រើនថ្នាក់ ចាប់ផ្តើមពីស្ថាប័នសាមី ពិនិត្យ ពិចារណានិងផ្តល់យោបល់បន្ថែម ដើម្បីអាចចៀសផុតពីបាតុភាព ភ័ន្តច្រឡំ ឬ គិតមិនបាន ដិតដល់ក្នុងប្រការណាមួយដែលជាហេតុបច្ច័យធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋភាគ ច្រើននៅទូទាំងប្រទេសក៏ដូចជាប៉ះពាល់ដល់តម្លៃពិតនៃច្បាប់បង្កបានជាបាតុភាពអស់ជំនឿ ពីសំណាក់ប្រជាជនទៅលើច្បាប់។

បន្ថែមចំពោះករណីខាងលើ ដោយហេតុថាច្បាប់កើតចេញពីការគិតដោយប្រើប្រាស់បញ្ញា **ម៉ុងតេសគី យើ** បានចែកច្បាប់ពិភពបញ្ញាជាបីប្រភេទតូចៗតទៅទៀត ដែលពាក់ព័ន្ធជាសំខាន់ទៅលើតួអង្គបីគឺ អាទិទេព ទស្សនវិទូ និងអ្នកតាក់តែងច្បាប់។

### ៣.២.ក-ច្បាប់ទេវៈឬច្បាប់សាសនា

បើរំលឹកទៅដល់ទស្សនៈខាងដើមដែលលោកបានពោលថា "ជារួមមនុស្សក៏មានច្បាប់ អាទិទេពក៏មានច្បាប់" ច្បាប់ទេវៈឬច្បាប់សាសនា ជាច្បាប់មួយប្រភេទដែលប្រកាសឲ្យប្រើដោយអាទិទេព។ច្បាប់ប្រភេទនេះ មានគោលដៅគ្រើនរំលឹកស្មារតីរបស់មនុស្សឱ្យចងចាំពីករណីយកិច្ចរបស់ខ្លួន ចំពោះអាទិទេព បានន័យថាមនុស្សត្រូវមាន កាតព្វកិច្ចធ្វើសក្ការៈបូជាចំពោះអាទិទេពដើម្បីសុំត្រឡប់វិញនូវសេចក្តីសុខ ការសម្រេចប្រយោជន៍ផ្សេងៗឬលាភជ័យណាមួយ។

### ៣.២.ខ-ច្បាប់សីលធម៌

ជាច្បាប់ដែលប្រកាសឱ្យប្រើដោយទស្សនវិទូ សម្រាប់គ្រើនរំលឹកស្មារតីរបស់មនុស្សឱ្យចងចាំ ពីករណីយកិច្ចដែលត្រូវធ្វើចំពោះខ្លួនឯងផ្ទាល់ ហើយសម្រួចសម្រាំងនូវសីលធម៌ល្អចំពោះខ្លួនឯង ពីព្រោះបើខ្លួនឯងល្អ សង្គមក៏បានល្អទៅតាមនោះដែរ។

***៣.២.គ-ច្បាប់នយោបាយ និងច្បាប់រដ្ឋប្បវេណី***

*ជាច្បាប់មួយដែលប្រកាសឲ្យប្រើដោយអ្នកតែងច្បាប់ ដើម្បីក្រើនរំលឹកស្មារតីរបស់មនុស្សឱ្យចងចាំនូវករណីយកិច្ចរបស់ខ្លួនចំពោះអ្នកដទៃនិងចំពោះសង្គម តួយ៉ាងដូចជាជួយអ្នកដទៃដោយមិន ប្រកាន់វណ្ណៈពណ៌សម្បុរ ឬនិន្នាការនយោបាយឲ្យរួចផុតពីក្ដីលំបាកវេទនាគ្រប់បែបយ៉ាង ឬក៏ជួយសង្គមឱ្យរីកចំរើនទៅមុខក្នុងសុខសន្តិភាពជាដើម។*

## ៤- តួនាទីរបស់ច្បាប់

*មកដល់ត្រង់ចំណុចនេះ ទស្សនៈរបស់ប្លាតុង(៤២៧-៣៤៧មុនគ.ស) បានអះអាងថា ច្បាប់មានតួនាទីបីយ៉ាងគឺ អប់រំ បង្ការនិងព្យាបាល។ តើតួនាទីទាំងបីនេះមានន័យយ៉ាងណាខ្លះ?*

***៤.១-អប់រំ***

*បើគិតទៅតាមន័យធម្មតា "អប់រំ" មកពីពាក្យឡាតាំងថា* Educere *ឬ* Educare *។ "អប់រំ" ក៏មានន័យ ថាទាញចេញពី, នាំចេញពីផ្គត់ផ្គង់បណ្ដុះដើម្បីនាំឆ្ពោះទៅរកគោលដៅណាមួយ។ បើតាមទស្សនៈរបស់លោក អាន់ឌែរសុន*(Anderson)*វិញ"អប់រំ" មានន័យ ថា ជាដំណើរដែលបុគ្គលម្នាក់ៗរៀនសូត្រនូវអ្វីដែលចាំបាច់ ដើម្បីតម្រូវទៅតាមជីវភាពរបស់គេ។ ដូច្នេះសរុបន័យទាំងអស់មកវិញ "អប់រំ" អាចជាអំពើឬសកម្មភាពដែលនាំមនុស្សឲ្យចេញផុតពីអ្វីដែលអាក្រក់ ដែលគ្រោះថ្នាក់ ដែលមិនគួរគប្បីឆ្ពោះទៅរកអ្វីដែលត្រឹមត្រូវល្អប្រសើរ។ "អប់រំ"អាចជាការបណ្ដុះឱ្យមនុស្សម្នាក់ៗនូវសីលធម៌។"អប់រំ"អាចជាការហ្វឹកហាត់ជាការបង្រៀនមនុស្សឱ្យចេះជំនាញវិជ្ជាជីវៈ ឬចេះពីរបៀបទំនាក់ទំនងសង្គម ដើម្បីញ៉ាំងឱ្យជីវភាពរស់នៅរបស់ពួកគេបានសុខស្រួល។ ក្នុងន័យនេះដដែល បើគិតឱ្យបានស៊ីជម្រៅដោយផ្សារភ្ជាប់ ទៅនឹងច្បាប់ តួនាទីអប់រំរបស់ច្បាប់មានន័យថា ច្បាប់បានចង្អុលបង្ហាញប្រាប់មនុស្សនូវអ្វីដែលត្រឹមត្រូវ អ្វីដែលមិនត្រឹមត្រូវគួរធ្វើឬមិនគួរធ្វើក្នុងអាកប្បកិរិយាប្រព្រឹត្តរបស់ខ្លួន ដើម្បីស្វែងរកឱ្យមនុស្សនូវភាពសុខដុមរមនាក្នុងសង្គមដែលគេកំពុងរស់នៅ។តួនាទី អប់រំរបស់ច្បាប់ក៏មានន័យម្យ៉ាងទៀតថា ច្បាប់ប្រាប់ឱ្យដឹងពីអ្វីដែលច្បាប់ចង់បានក្នុងអំពើប្រព្រឹត្តរបស់បុគ្គលម្នាក់ៗក្នុងគោលបំណងជានានូវសណ្ដាប់ធ្នាប់និងរបៀបរៀបរយសង្គម សម្រាប់កាលវេលាជាក់លាក់ណាមួយ។ ឧបមាថា បើលើសកាលកំណត់នោះមនុស្សនៅតែសោះអង្គើយធ្វើមិនដឹងមិនឮ ឬក៏មិនព្រមធ្វើខ្លួនឱ្យចុះសម្រុងជាមួយនឹងអ្វីដែលច្បាប់ចង់បាន ច្បាប់នឹងអប់រំមនុស្សនេះតាមរយៈអាជ្ញាធរមានសមត្ថកិច្ច ដោយវិធាន*

ការផាកពិន័យដាក់ទោសទណ្ឌទៅតាមកម្រិតនៃអំពើប្រព្រឹត្តដើម្បីឱ្យមនុស្សនោះរាងចាលឈប់ប្រព្រឹត្តបែបនេះតទៅទៀត។ ដូច្នេះ "អប់រំ"របស់ច្បាប់តាមគំនិតរបស់ថ្នាតុង គឺប្រាប់ឱ្យដឹងដោយធ្វើការបញ្ច្រាបឱ្យជ្រួតជ្រាបនូវអ្វីដែលគួរធ្វើនិងមិនគួរធ្វើ ព្រមទាំងអប់រំដោយដាក់ពិន័យនៅពេលដែលអ្វីៗត្រូវហាមប្រាមនោះ មិនទទួលបានត្រឡប់វិញនូវការគោរពតាម។ ចុះ"បង្ការ"វិញ តើមានន័យដូចម្ដេច?

### ៤.២-បង្ការ

បង្ការមានន័យថា មើលឃើញជាមុននូវអ្វីៗដែលអាចនឹងកើតមានឡើង។ ដូច្នេះត្រូវតែធ្វើច្បាប់ដើម្បីរាំងខ្ទប់ជាមុន កុំឱ្យអ្វីៗទាំងនោះ កើតមានឡើងបានហើយបង្កទៅជាភាពវឹកវរច្របូកច្របល់ក្នុងសង្គម។ បើគេនិយាយជាភាសាសាមញ្ញមានន័យថា "ចោរមិនទាន់លួចគោទេ តែយើងធ្វើក្រោលធ្វើរបងឱ្យបានរឹងមាំជាមុន ដើម្បីការពារកុំឱ្យចោរចូលលួចបាន"។ ប្រហាក់ប្រហែលគ្នាទៅនឹងរឿងនេះដែរ ឧបមាថា ប្រទេសណាមួយនោះបំរុងនឹង បញ្ចប់សង្គ្រាមជាមួយគូបដិបក្ខនាពេលខាងមុខ ដូច្នេះ អ្នកធ្វើច្បាប់ត្រូវប្រមើលមើលឲ្យបានវែងឆ្ងាយថា តើពេលបញ្ចប់សង្គ្រាមទៅអាចកើតមានគ្រោះថ្នាក់ឬបាតុភាពអសកម្មអ្វីខ្លះ ទាក់ទងនឹងអាវុធយុទ្ធភណ្ឌ? ដូច្នេះ ដើម្បីការពារកុំឱ្យមានបាតុភាព ចោរលួច ចោរប្លន់ប្រដាប់អាវុធឬអំពើបាញ់បោះសងសឹកសម្លាប់គ្នាដោយព្រៃផ្សៃកើតមានក្នុងប្រទេស ទើបនឹងបញ្ចប់សង្គ្រាម គេត្រូវធ្វើច្បាប់ស្ដីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ ព្រមទាំងចាត់វិធានការអនុវត្តឱ្យបានតឹងរ៉ឹងបំផុត ដើម្បីការពារភាពសុខសាន្តជូនប្រជាជន។ ចំណែក"ព្យាបាល"វិញ តើមានន័យយ៉ាងណាដែរ?

### ៤.៣-ព្យាបាល

"ព្យាបាល"មានន័យថា អ្វីមួយកើតឡើងហើយទើប ដាក់ថ្នាំព្យាបាលឬចាត់វិធានការទប់ស្កាត់ជា ក្រោយដើម្បីកុំឲ្យរីករាលដាលធំតទៅទៀត ពោលគឺ ឱ្យស្ថិតក្នុងសភាពរួមតូចបន្តិចម្ដងៗទៅវិញ។ ហេតុអ្វីបានជាមានហេតុភេទដូច្នេះកើតឡើង? ពីព្រោះដូចបានបញ្ជាក់ពីខាងដើមស្រាប់ "ច្បាប់" អាស្រ័យទៅលើមនុស្សជាអ្នកបង្កើត។ ក្នុងកាលៈទេសៈខ្លះអ្នកធ្វើច្បាប់(តាក់តែងច្បាប់)ក៏មានភាពធេកល្វែងដែរ អាស្រ័យដោយពេលវេលានៃការរៀបចំតាក់តែងមានរយៈពេលខ្លី ឬមួយក៏អាស្រ័យដោយការគិតពិចារណា ឬការស្រាវជ្រាវបញ្ហាមិនបានដិតដល់ឬក៏មកពីភាពលម្អៀងដោយចេតនារបស់ក្រុមអ្នកតាក់ តែងច្បាប់ពាក់ព័ន្ធទៅនឹងផលប្រយោជន៍ ជាអាថ៌កំបាំងណាមួយរបស់ពួកគេ។ ដូច្នេះហើយបានជាមានទង្វើធ្វើតាមក្រោយបែបនេះ។ សមដូចពាក្យចាស់បានពោលថា "ចោរលួចគោបាត់ទៅហើយ

ទើបស្រះរបង" ឬទើបធ្វើក្រោលឲ្យរឹងមាំ។ ក៏មានសភាពដូចគ្នាទៅនឹងករណីនេះដែរ នៅចុងឆ្នាំ២០១៩ និងបន្តចូលមកឆ្នាំ២០២១ យើងនេះ ពិភពលោកបានទទួលរងនូវការរាតត្បាតជាសកល និងដោយឥតបានត្រៀមទុកជាមុនពីជម្ងឺ ផ្លូវដង្ហើម ដ៏កាចសាហាវមួយបែបបណ្តាលមកពី មេរោគជាវីរុស "កូរ៉ូណា"(Corona virus)ដែលក្រុមអ្នកប្រាជ្ញខាងវេជ្ជសាស្ត្រឱ្យឈ្មោះថា "ជម្ងឺកូវីដ១៩" (Covid-19)។ ដោយបាត់ម្ចាស់ការក្នុងការទប់ទល់ឬការមើលស្រាលផងនោះ ធ្វើឱ្យប្រទេស ខ្លះជួបប្រទះគ្រោះថ្នាក់ធ្ងន់ធ្ងរដោយសារជម្ងឺនេះ ចេះតែរីករាលដាលធំឡើងៗហើយបរិមាណអ្នកស្លាប់ក៏បានកើនឡើងខ្ពស់គួរឱ្យព្រួយបារម្ភ។ តាមពិតទៅ គ្មាននរណាម្នាក់បានដឹងជាមុនអំពីជម្ងឺដ៏ចម្លែកបែបនេះទេ ទាល់តែមានអ្នកស្លាប់នៅឯខេត្តវូហាន់ ប្រទេសចិនទើបអ្នកជំនាញខាងវេជ្ជសាស្ត្រចាប់អារម្មណ៍ ហើយស្រាវជ្រាវទៅក៏រកឃើញថា មានជំងឺដ៏កាចសាហាវនេះ កំពុងធ្វើសកម្មភាពរាតត្បាត។ ដូច្នេះវិធានការដែលសមស្របបំផុតគឺមានតែវិធានការព្យាបាលទេ ទើបមានប្រសិទ្ធភាពដើម្បីទប់ស្កាត់កុំឱ្យជំងឺនេះរីករាលដាលធំឡើងតទៅទៀតបាន។ ទន្ទឹមនឹងនេះ ក្នុងការព្យាបាល គេក៏អាចប្រើវិធានការចម្រុះក៏បានពោលគឺអប់រំដើម្បីបង្ការកុំឱ្យជំងឺកើតមាននៅកន្លែងផ្សេងទៀត ព្រមទាំងអប់រំដើម្បីព្យាបាលនៅ កន្លែងដែលកើតមានរួចទៅហើយនិងធ្វើច្បាប់ឬប្រើប្រាស់វិធានការផ្សេងៗ សម្រាប់អនុវត្តការត្រួតពិនិត្យដោយតឹងរ៉ឹងបំផុត។ ទោះបីជាយ៉ាងនេះក្តី ក៏មានករណី "អ្នកខ្លះ គោរពបាន អ្នកខ្លះ ទៀតគោរពមិនបាន" ហើយជំងឺអាចពង្រីកសកម្មភាពបានកាន់តែខ្លាំងក្លាថែមទៀត។ ហេតុអ្វីបានជាមានឥរិយាបថគោរពច្បាប់ផង និងមិនគោរពច្បាប់ផងបែបនេះកើតឡើង?

## ៥-ឥរិយាបថរបស់មនុស្សចំពោះច្បាប់

ដូចដែលខ្ញុំបានបញ្ជាក់ជូនពីខាងដើមរួចមកហើយស្រាប់ ក្នុងជីវិតរបស់មនុស្សជាធម្មតាតែងមាន ឥរិយាបថពីរនេះកើតឡើងគឺ ឥរិយាបថគោរពនិងមិនគោរពច្បាប់។ ឥរិយាបថទាំងពីរនេះ នៅលាយឡំជាមួយគ្នា។ ដូច្នេះយើងអាចស្វែងយល់តទៅទៀតថា តើឥរិយាបថជាអ្វី? ឥរិយាបថបានដល់លំនាំឬកពាឬកិរិយាដែលទាក់ទងដល់សកម្មភាព ដេក ដើរ ឈរ អង្គុយ របស់មនុស្សម្នាក់ៗ។ ឥរិយាបថទាំងបួននេះ សុទ្ធតែមានច្បាប់ទម្លាប់ទាំងអស់ តើនៅកន្លែងណាត្រូវដេក? ហើយដេករបៀបណា? តើនៅកន្លែងណាត្រូវដើរ? ហើយដើររបៀប ដូច ម្តេចដើម្បីឱ្យបានសមរម្យមិនផ្តាំផ្គង់មិនទាស់ភ្នែកឬមិនធ្វើឱ្យរំខានដល់អ្នកដទៃ។ល។

## ៥.១- ឥរិយាបថគោរពច្បាប់

ឥរិយាបថ គោរពច្បាប់ បានដល់ឥរិយាបថ"វិជ្ជមាន" បានមកពីការអប់រំបណ្តុះបណ្តាលនៃស្ថាប័នគ្រួសារ សាលារៀន ក៏ដូចជាស្ថាប័នសាសនា។ ជាឥរិយាបថនៃប្រភេទមនុស្សដែលប្រកប ដោយវិចារណញ្ញាណត្រឹមត្រូវ មានការទទួលខុសត្រូវខ្ពស់ ភ្ញាក់រលឹក គិតពិចារណាទៅលើទង្វើរបស់ខ្លួនជាប់ជាប្រចាំហើយដែលអ្នកប្រាជ្ញខាងចិត្តវិទ្យាឱ្យឈ្មោះថា ជាប្រភេទមនុស្សដែលមានអត្តប្រសើរខ្ពង់ខ្ពស់(Super Ego)។ មនុស្សប្រភេទនេះតែងតែ គិតគូរជាប់ជានិច្ចទៅលើឥរិយាបថរបស់ខ្លួន ព្រួយបារម្ភខ្លាចឥរិយាបថអស់ទាំងនេះ ប៉ះទង្គិចដោយប្រការណាមួយទៅលើអារម្មណ៍អ្នកដទៃដែលរស់នៅក្នុងមជ្ឈដ្ឋានជាមួយគ្នា។ ជាងនេះទៅទៀត គេតែងតែគិតគូរដោយ ភ្ញាក់រលឹកនិងឯកភាពគ្នាថា ត្រូវតែមានច្បាប់ដើម្បីធ្វើឱ្យសង្គមមានលំនឹង មានសណ្តាប់ធ្នាប់របៀបរៀបរយល្អ ចៀសផុតពីអំពើរំលោភបំពានគ្រប់បែបយ៉ាងទៅលើមនុស្សដូចគ្នា។ មនុស្សប្រភេទនេះតែងឱ្យតម្លៃខ្ពស់ទៅលើការគោរពច្បាប់បទដ្ឋាននានាដែលកើតចេញពីការស្រុះស្រួលចិត្តគ្នានាំគ្នាបង្កើ-តបានជាឆន្ទៈរួមសម្រាប់អនុវត្តទាំងអស់គ្នា។ មិនថានៅក្នុងអង្គភាពឬស្ថាប័នណាមួយទេ ប្រសិនបើអង្គភាពឬស្ថាប័ននោះសម្បូណ៌ទៅដោយមនុស្សប្រភេទនេះជាសមាជិក អង្គភាពឬស្ថាប័ននោះ ក៏មិនសូវមានភាពស្មុគស្មាញកើតឡើងឡើយ។ ផ្ទុយទៅវិញ អង្គភាពឬស្ថាប័ននោះតែងតែទទួលបាននូវភាពសុខដុមរមនា និងភាពរីកចំរើនទៅមុខជាលំដាប់ ពីព្រោះមនុស្សចេះស្តាប់បង្គាប់គ្នា ចេះឱ្យតម្លៃគ្នានិងគោរពគ្នា ក្រោមឥទ្ធិពលនៃបទដ្ឋានឯកភាពមួយដែលជាភ្នាក់ង៉ារ "ត្រួតពិនិត្យសង្គម" ដ៏សក្តិសិទ្ធរបស់ស្ថាប័ន។

## ៥.២-ឥរិយាបថមិនគោរពច្បាប់

បើគេ សញ្ជឹងគិតឱ្យជិតដល់ទៅឃើញថាមានសភាពស្មុគស្មាញនិងវែងឆ្ងាយ ណាស់ចំពោះ ឥរិយាបថបែបនេះ ហើយទន្ទឹមនឹងនេះដែរ គេក៏អាចរកឃើញនូវមូលហេតុជាអត្តនោម័តនិងបរានុម័តច្រើនយ៉ាងដែលកើតចេញពីការមិនគោរពច្បាប់។ បណ្តាមូលហេតុទាំងនោះ រួមមាន:

-មូលហេតុដំបូង អាចបណ្តាលមកពីការឱ្យតម្លៃរបស់បុគ្គលនោះ ផ្ទុយពីសច្ចភាពជាសកល ដែលមានពិតនៅក្នុងលោកិយសច្ចៈយើងនេះ។ ជាក់ស្តែងគេយល់ថា កាយវិការមិនគោរពច្បាប់គឺ "ល្អ"សម្រាប់រូបគេ។ ដូច្នេះ"ល្អ"របស់គេផ្ទុយពី"ល្អ"ជាសកលរបស់មនុស្សទូទៅដែលប្រកាន់យកការគោរពច្បាប់ជាធំ។ តាមពិតទៅ"ល្អ"បែបនេះបានទទួលឥទ្ធិពលពី "សភាពធម្មជាតិបីយ៉ាង" (សភាវ គតិ អត្តទត្ត និងចំណង់) ដែល

ជា សភាពមិនទាន់បានទទួលការអប់រំហើយ ដែលតែងតែបដិបក្ខ ជាប់ជានិច្ចជាមួយនឹង "សភាពជាពលរដ្ឋ" របស់មនុស្សរស់នៅក្នុងសង្គមជាមួយគ្នា។ បើករណីបែបនេះកើតមានឡើងហើយ ច្បាស់ណាស់ថា វានឹងនាំទៅដល់ការកើតមាននូវការមិនគោរពច្បាប់ដោយចៀសមិនផុត។

-មូលហេតុមួយទៀត អាចបបណ្ដាលមកពីកម្រិតអប់រំ ឱ្យស្គាល់ខុសត្រូវអាក្រក់ល្អនៅក្នុងគ្រួសារមិនបានដិតដល់ ឬមួយក៏មកពីការទទួលឥទ្ធិពលពីពូជពង្ស ឬក៏មកពីការទទួលឥទ្ធិពលពីគ្រួសារជិតខាងដែលជាគ្រួសារគ្មានវិន័យ គ្មានសណ្ដាប់ធ្នាប់ ឥតច្បាប់ទម្លាប់ គ្មានឋានានុក្រម តួនាទីច្បាស់លាស់ក្នុងគ្រួសារពោលគឺ ឪពុកមិនប្រាកដថាជាឪពុក ម្ដាយមិនប្រាកដជាម្ដាយ កូនមិនប្រាកដថាកូន។ ដោយសារហេតុ បច្ច័យយ៉ាងនេះហើយ បានជាខុងជឺ តែងយកចិត្តទុកដាក់ទៅលើគ្រួសារ ដោយអប់រំមនុស្សពីឋានានុក្រម និងពីតួនាទីក្នុងគ្រួសារតាមប្រសាសន៍ដ៏មានអត្ថន័យមួយឃ្លាថា "រដ្ឋមន្ត្រីគឺរដ្ឋមន្ត្រី ឪពុកគឺឪពុក កូនគឺកូន" ជាដើម។

-មួយវិញទៀត ឥរិយាបថបែបនេះម្យ៉ាងក៏មកពី គំរូប្រព្រឹត្តបានមិនបានល្អរបស់អាជ្ញាធរដែលតំណាងឱ្យច្បាប់ដូចដែលលោកស៊ីសេរ៉ុង ធ្លាប់បានលើកឡើងក្នុងនិយមន័យស្ដីពីច្បាប់យ៉ាងនេះថា: "ចៅក្រមគឺជាច្បាប់ចេះនិយាយ"។ បើចៅក្រមនិយាយស្រួលមិនស្រួលអាចជះឥទ្ធិពលធំធេងទៅលើគុណតម្លៃរបស់ច្បាប់ ពីព្រោះច្បាប់ពឹងពាក់ចៅ ក្រមឱ្យនិយាយជួសខ្លួន។

-ម្យ៉ាងទៀត ឥរិយាបថមិនគោរពច្បាប់ក៏អាចមកពីការទទួលឥទ្ធិពលពីសង្គមឥតច្បាប់ទម្លាប់ដែលខ្លួន គេផ្ទាល់កំពុងរស់នៅក៏សឹងតែថាបាន ហើយក៏អាចមកពីការអនុវត្តបែបបទនៃការដាក់ទណ្ឌកម្មចំពោះអំពើរំលោភបំពានច្បាប់របស់អាជ្ញាធរប្រេតិបត្តិនៅធូររលុង ឬមិនមានយុត្តិធម៌ត្រឹមត្រូវពោលគឺ អាចលម្អៀងឆ្ពោះទៅរកអគតិណាមួយធ្វើឱ្យជះឥទ្ធិពលមិនល្អដល់ជំនឿ និងប្រសិទ្ធភាពនៃការគោរពច្បាប់។ សមដូចពាក្យដំណាលតៗគ្នាមកថា: "ចោររួចខ្លួនម្ចាស់ជាប់គុក" ឬមួយបាតុភាពបែបនេះ អាចបណ្ដាលមកពីអាកប្បកិរិយាសោះអង្គើយមិនរវល់ខ្វល់ខ្វាយអំពីការដាក់ពិន័យចំពោះអ្នកប្រព្រឹត្តខុស បណ្ដោតបណ្ដោយឲ្យសភាពអនាធិបតេយ្យកើតមានឡើងព្រោងព្រាតតាមអំពើចិត្ត។ ឬមួយក៏អាចមកពីការឆ្លៀតឱកាសកេងចំណេញរបស់គណបក្សនយោបាយណាមួយ ដែលបង្កើតឱ្យមានភាពរីករវមិនគោរពច្បាប់ទម្លាប់ដើម្បីទម្លាក់កំហុទៅលើអសមត្ថភាពដឹកនាំ គ្រប់គ្រងរបស់គណបក្សនយោបាយដែលកំពុងកាន់អំណាច។ ឬមួយក៏មកពីកម្រិតអប់រំឱ្យជ្រួតជ្រាបអំពី

ច្បាប់និងការដាក់ទោសទណ្ឌចំពោះ ប្រភេទទាំងឡាយនៃបទល្មើសនៅមិនទាន់ច្បាស់លាស់ពេញលេញក្នុងប្រទេសដែលកំពុងធ្វើអន្តរកាលឆ្ពោះទៅរក "នីតិរដ្ឋ"។

-បាតុភាពនៃការមិនគោរពច្បាប់ ក៏អាចបណ្តាលមកពីឥទ្ធិពលផ្សេងៗទៀតដែរ តួយ៉ាង ដូចជា ឥទ្ធិពលនៃស្ថានភាពស្រុកទេសដែលធ្លាប់ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃអូសបន្លាយរយៈពេលយូរឆ្នាំ ម៉្លោះហើយ ក៏កើតឡើងនូវបាតុភាពអសកម្ម "មិនគោរពច្បាប់តែអាងលើកម្លាំងបាយយកឈ្នះចាញ់" គ្របដណ្តប់ទៅលើចិត្តគំនិតនៃជំពូកជនឆ្លងកាត់សង្គ្រាមនោះក៏សឹងមាន។ ឬមួយក៏មកពីឥទ្ធិពលនៃការសេពគ្រឿងញៀនហួកម្រិត ធ្វើឱ្យឡប់សតិ លែងដឹងខុសត្រូវ អាក្រក់ល្អ យកការឈឺចាប់ យកអំពើបង្ក របួសស្នាម អំពើឧក្រិដ្ឋកម្មមកធ្វើជាសេចក្តីសប្បាយឆ្ពោះទៅរកសេចក្តីស្លាប់សម្រាប់ខ្លួនក៏សឹងតែថាបាន។

-មូលហេតុចុងក្រោយ ក៏អាចមកពីទម្លាប់អាក្រក់របស់ជំពូកជន ដែលមានទំនោរចង់តែប្រព្រឹត្តអ្វីៗទៅតាមទំនើងចិត្តនឹកឃើញ បណ្តោតបណ្តោយខ្លួនឱ្យធ្លាក់ក្នុងសភាវគតិឥតគិតពិចារណា ឬក៏ធ្លាក់ទៅក្នុងអត្តទត្ថដែលគិតតែបុគ្គលផ្ទាល់ខ្លួន មិនគិតពីអ្នកដទៃ ចង់ប៉ះពាល់ទៅលើសិទ្ធិនិង ផលប្រយោជន៍អ្នកណាក៏មិនខ្វល់ខ្វាយ ឬក៏ធ្លាក់ទៅក្នុងតណ្ហាលោភលន់ឥតព្រំដែន ខ្វះមនសិការ ដែលសុទ្ធតែជាទង្វើមិនគាប់ប្រសើរសម្រាប់សង្គម ឈានឆ្ពោះទៅរកអំពើមិនគោរពច្បាប់។

**៥.៣-តើត្រូវធ្វើយ៉ាងណាដើម្បីផ្លាស់ប្តូរឥរិយាបថរបស់មនុស្ស ពីការមិនគោរពច្បាប់ ឆ្ពោះទៅរកការ គោរពច្បាប់? ចម្លើយឆ្លើយថា គេអាចផ្លាស់ប្តូរឥរិយាបថទាំងនេះបានទាល់តែមានវិធានការបន្ទាន់មួយចំនួន។** តទៅនេះ គឺជាខ្លឹមសារជាក់ស្តែងនៃវិធានការដើម្បីត្រិះរិះពិចារណា និងសាកល្បងដោះស្រាយនូវបញ្ហា ចោទខាងលើ:

-ជាបឋម គេគប្បីថ្លឹងឱ្យមានតុល្យភាពរវាងការ "អប់រំ" និងវិធានការ "រដ្ឋបាល" ចាប់បង្ខំឱ្យគោរពដោយដាក់ពិន័យ។ ធ្វើយ៉ាងណាក្នុងការអនុវត្តច្បាប់គប្បីកុំធ្ងន់ខ្លាំងទៅលើវិធានការ អប់រំ ឬអត់ឱនហួសកម្រិតដែលជាហេតុធ្វើឱ្យអ្នកប្រព្រឹត្តខុសបានចិត្តចង់ប្រព្រឹត្តអំពើខុសឆ្គងកាន់តែច្រើនឡើង។

-គប្បីលុបបំបាត់នូវទស្សនៈក្រេងរអែងរបស់អាជ្ញាធរថា "បើធ្វើខ្លាំងទៅនាំឲ្យប៉ះពាល់យ៉ាងនេះ ឬ យ៉ាងនោះដល់សិទ្ធិមនុស្សនាំតែលំបាកដល់ខ្លួន" ម៉្លោះហើយចេះតែសម្ងំយកសុខតែរៀងៗខ្លួន ជាហេតុធ្វើឱ្យបាត់បង់នូវឆន្ទៈ និងការទទួលខុសត្រូវក្នុងមុខនាទីរបស់ខ្លួនជាអាជ្ញាធរ។

-គប្បីអប់រំឲ្យបានស៊ីជម្រៅ និងជាប់ជាប្រចាំអំពីតម្លៃនៃការគោរពច្បាប់ថាជាការ

នាំមកនូវសេចក្ដីថ្លៃថ្នូរ ភាពស៊ីវិល័យសក្ដិសមជាពលរដ្ឋនៃប្រទេសដែលប្រកាន់ខ្ជាប់ "នីតិរដ្ឋ"។

-ដោយឡែក ចំពោះអ្នកតំណាងឱ្យច្បាប់ គប្បីធ្វើគំរូឱ្យមហាជនបានឃើញផ្ទាល់ភ្នែក អំពីស្មារតីគោរពច្បាប់របស់ខ្លួនដោយមិនភ្លាំងភ្លាត់ទៅក្នុងឥរិយាបថ "ហាមគេមិនឱ្យធ្វើ តែល្មើសខ្លួនឯង" ជាហេតុនាំឲ្យសាបរលាបដល់ឧត្ដមភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់។ យូរៗទៅក៏កើតជាជំងឺមាក់ងាយច្បាប់ថាជា "របស់សាមញ្ញជារបស់ដែលមនុស្សបង្កើត គ្មានអ្វីគួរឲ្យកោតញញើតសោះឡើយ។ ដូច្នេះចង់គោរពក៏បាន មិនគោរពក៏បានគ្មានចោទជាបញ្ហាអ្វីឡើយ"។

-គប្បីកែប្រែ ទស្សនៈដែលធ្លាប់តែចាត់ទុកថាអំណាចច្បាប់ ស្ថិតក្រោមអំណាចបុគ្គលឱ្យត្រឡប់មករកទស្សនៈត្រឹមត្រូវឡើងវិញ ដោយចាត់ទុកអំណាចច្បាប់ធំជាងអំ-ណាចបុគ្គល។ នោះហើយដែលគេហៅថាបាន"ទទួលការអប់រំពីអំណាច"ពិតប្រាកដ។

-គប្បីលើកកំពស់ស្មារតីទទួលខុសត្រូវចំពោះមុខច្បាប់: អ្នកណាធ្វើខុស អ្នកនោះទទួល គ្មានវប្បធម៌ រួចខ្លួន គ្មានវប្បធម៌ទំលាក់កំហុសឱ្យអ្នកដទៃដែលមិនបានប្រព្រឹត្តខុស គ្មានវប្បធម៌គេចវេះពីសំណាញ់ច្បាប់។

-លើកកំពស់បុគ្គលិកលក្ខណៈរបស់មនុស្សតាមរយៈការអប់រំពីស្ថាប័នគ្រួសារ សាលារៀន និងស្ថាប័ន សាសនា។

-គប្បីឱ្យមនុស្សទាំងអស់ យល់បានទូលំទូលាយអំពីទស្សនាទានស្ដីពី"នីតិរដ្ឋ"ដែលជាទស្សនាទានមួយលើកទឹកចិត្តឱ្យមនុស្សនាំគ្នាបង្កើតច្បាប់ទម្លាប់ឱ្យបានគ្រប់គ្រាន់សម្រាប់ប្រទេសនាំគ្នាស្វែងយល់ពីច្បាប់ឲ្យបានច្រើន និងនាំគ្នាគោរពច្បាប់ទម្លាប់កាន់តែម៉ត់ចត់ថែមទៀត

-រឹតបន្តឹងការផាកពិន័យក្នុងន័យអប់រំកម្រិតខ្ពស់ចំពោះអ្នកប្រព្រឹត្តល្មើសច្បាប់។

-លុបបំបាត់វប្បធម៌មើលបំណាំគ្នា: "គោរពអ្វីតែឯង បើគេឯទៀតមិនគោរពផងឃើញតែគេបានសុខ រួចខ្លួនរហូត"។

-លុបបំបាត់វប្បធម៌ "គោរពតែពេលឃើញអាជ្ញាធរ ពេលមិនឃើញអាជ្ញាធរមិនខ្វីគោរព"។ នេះហើយ ជាឥរិយាបថដែលមិនទាន់ភ្ញាក់រលឹក ជាឥរិយាបថដែលមិនទាន់ក្លាយទៅជាទម្លាប់ក្នុងការគោរពច្បាប់។

-ពង្រឹង"សភាពជាពលរដ្ឋ"ដោយលុបបំបាត់ជាបណ្ដើរៗនូវ"សភាពជាធម្មជាតិ" របស់មនុស្សពីព្រោះសភាពធម្មជាតិ គឺជាគ្រោះថ្នាក់ធ្ងន់ធ្ងរសម្រាប់សង្គម ហើយក៏ជាឧបសគ្គដ៏ធំ រាំងស្ទះដល់ការកសាង"នីតិរដ្ឋ" សម្រាប់ប្រទេសនីមួយៗ មិនឱ្យរីកចំរើនទៅមុខបាន។

*-គប្បីមានច្បាប់ធានាសន្តិសុខផ្ទាល់ចំពោះអាជ្ញាធរទទួលបន្ទុកត្រួតពិនិត្យការអនុវត្តច្បាប់។*

*-រៀបចំគូសជាសញ្ញានៅតាមទ្រូងផ្លូវ ដាក់ផ្លាកសញ្ញានៅតាមដងផ្លូវ និងនៅតាមទីសាធារណៈនានា ឱ្យបានគ្រប់គ្រាន់ដើម្បីកុំឱ្យអ្នកល្មើសច្បាប់មានលេសថាយ៉ាងនេះ ឬយ៉ាងនោះ ឬប្រកែកប្រណាំងយករួចខ្លួន។*

*-ប្រែក្លាយ ការគោរពច្បាប់ឱ្យទៅជាចលនាភ្ញាក់រលឹកនៅទូទាំងប្រទេស ដោយគ្មានការបន្ទំឬមើល បំណាំគ្នាក្នុងចំណោមមនុស្សទាំងអស់ដោយមិនគិតពីឋានៈឬតួនាទី។*

*-លើកកំពស់សីលធម៌វិជ្ជាជីវៈ ចំពោះអាជ្ញាធរពាក់ព័ន្ធ ដោយអប់រំឱ្យបុគ្គលទាំងនោះប្រកាន់យកនូវអាកប្បកិរិយាថ្លៃថ្នូរមិនរំលោភបំពានសិទ្ធិចំពោះអ្នកប្រព្រឹត្តខុសច្បាប់។*

*រាល់វិធានការដែលបានរៀបរាប់មកខាងលើ អាចប្រព្រឹត្តទៅបាន អាស្រ័យទៅលើការចូលរួមចំណែក ទទួលខុសត្រូវផ្ទាល់ពីស្ថាប័នជាប់ពាក់ព័ន្ធទាំងឡាយដូចជា **ស្ថាប័នអប់រំ ស្ថាប័នគ្រួសារ ស្ថាប័នសាសនា សង្គម ស៊ីវិលឬអង្គការមហាជននានា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អ្នកច្បាប់ តុលាការ អ្នកតំណាងប្រជាពលរដ្ឋ**(តំណាងរាស្ត្រ) **ក៏ដូចជាការរួមចំណែកជាកាតព្វកិច្ចផ្ទាល់របស់ប្រជាពលរដ្ឋម្នាក់ៗ។***

## សេចក្តីសន្និដ្ឋាន

*សរុបសេចក្តីមក ច្បាប់អាចចាត់ទុកជាវិធានផ្លូវការរបស់ប្រទេសឬរដ្ឋនីមួយៗ ដោយការចង្អុលបង្ហាញពីអ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ។ ទន្ទឹមនឹងនេះ ច្បាប់ក៏អាចចាត់ទុកថាជាវិចារណញ្ញាណត្រឹមត្រូវខុសប្លែកពីវិចារណញ្ញាណធម្មតា ហើយដែលនាំទៅដល់លទ្ធភាពមួយអាចបែងចែកបានច្បាស់លាស់នូវអ្វីដែលត្រូវពីអ្វីដែលខុស។ ច្បាប់ត្រូវបានគេឱ្យតម្លៃថា ជាភ្នាក់ងារត្រួតពិនិត្យសង្គមដ៏មានប្រសិទ្ធភាពសម្រាប់ថែរក្សា សណ្តាប់ធ្នាប់និងរបៀបរៀបរយសាធារណៈរបស់ប្រទេស។ ជាងនេះទៅទៀត ច្បាប់ត្រូវបានគេមើលឃើញថា អាក្រក់ឬល្អអាស្រ័យទៅលើសកម្មភាពប្រព្រឹត្តបែបអវិជ្ជមាន ឬវិជ្ជមានរបស់អ្នកតំណាងឱ្យច្បាប់។ ផ្សារភ្ជាប់ទៅ នឹងច្បាប់នេះដែរ គប្បីចងចាំថា "នីតិរដ្ឋ" គឺជារបស់មួយមានតម្លៃខ្ពង់ខ្ពស់បំផុត ប៉ុន្តែក៏ជារបស់ដែលពលរដ្ឋ គ្រប់រូបអាចឈោងចាប់បានប្រសិនបើពលរដ្ឋទាំងអស់ដាក់ចិត្តដាក់កាយ សិក្សាស្វែងយល់ព្រមទាំងទទួល យកដោយស្មារតីភ្ញាក់រលឹក និងទទួលខុសត្រូវខ្ពស់។*

# ឯកសារពិគ្រោះ

១-**ជួន ណាត** *វចនានុក្រមខ្មែរ ភាគទី១* បោះពុម្ពគ្រាទី៥ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ១៩៦៧។

២-**អ៊ុំ ប៊ុម** *ប្រវត្តិគំនិតនយោបាយបស្ចិមប្រទេស* ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ ឆ្នាំ២០០៨។

៣- **អ៊ុំ ប៊ុម** *ចំណេះដឹងជាមូលដ្ឋានអំពីសង្គមវិជ្ជា ភាគទី២* ឯកសារបង្រៀនឆ្នាំ២០០៩។

៤- **អ៊ុំ ប៊ុម** *សង្គមវិជ្ជាអប់រំ* ឯកសារបង្រៀនឆ្នាំ២០១២។

៥- **Ebenstein Alan & Ebenstein William Great Political Thinker, Sixth Edition 2000.**

៦-**Sachdeva R.D & Bhushan Vidiya An Introduction to Sociology, Kitab Mahal, 22A Sarojini Naidu Marg, Allhalad, Century printer 22, 1997.**

៧-**Oxford Advanced Learner's Dictionary New Edition, Oxford university press, 2003.**

# ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសង្ខេប

*ដោយៈ បណ្ឌិត* **ឃិន យ៉ន់** *ប្រធាននាយកដ្ឋានកិច្ចការទូទៅ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

*អក្សរសិល្ប៍ខ្មែរចែកជាពីរប្រភេទធំៗ គឺអក្សរសិល្ប៍ប្រជាប្រិយ និង អក្សរសិល្ប៍សំណេរ ឬហៅថាអក្សរសិល្ប៍ចំណារ។*

## ១-អក្សរសិល្ប៍ប្រជាប្រិយ

*អក្សរសិល្ប៍ប្រជាប្រិយមានតាំងពីសម័យបុព្វកាលមក គឺមានតាំងពីសម័យកកើតមនុស្ស មានភាសា មានកាយវិការ មានសម្តីនាំឱ្យមានអក្សរសិល្ប៍ប្រជាប្រិយ ហើយវាបានវិវត្តតាមទម្រង់ផ្សេងៗ មានចម្រៀងប្រជាប្រិយ ដែលស្ថិតនៅក្នុងប្រភេទពាក្យជូនប្រជាប្រិយហ្នឹង ហើយមានទេវកថាដែលបកស្រាយបញ្ហាធម្មជាតិ បាតុភូតធម្មជាតិ ការកើតការស្លាប់របស់មនុស្សនៅក្នុងសង្គមបុព្វកាល បន្ទាប់មកទៀតកើតឡើងនៅរឿងព្រេង រឿងព្រេងខ្មែរ ឡើងនៅដើមសម័យប្រវត្តិសាស្ត្រ បង្ហាញពីការកកើតទឹកដីជាប្រទេស ជារដ្ឋបង្ហាញពីតួអង្គវីរជន មេដឹកនាំ ជាស្តេច ជាមេទ័ព ប្រវត្តិភូមិសាស្ត្រទឹកន្លែង គឺព្រេងកថា បន្ទាប់ពីព្រេងកថាមាននិទានកថា ដែលនិទានពីទំនាស់ក្នុងជីវភាពប្រចាំថ្ងៃ។ ទំនាស់បុគ្គលនិងបុគ្គលជាមួយធម្មជាតិ បុគ្គលអ្នកមាននិងអ្នកក្រ អ្នកតូចនិងអ្នកធំ ស្តេចនិងរាស្ត្រនឹងទៅ ហ្នឹងគឺនិទានកថា។ និទានកថា ចែកជាបួនប្រភេទទៀតគឺ និទានកថាសំណើច និទានកថារិះគន់ ឬហៅថានិទានកថាសង្គម និទានកថាអស្ចារ្យ និងនិទានកថាសត្វ។*

## ២-អក្សរសិល្ប៍សំណេរ

*អក្សរសិល្ប៍សំណេរ ចែកជាបីសម័យកាលធំៗ ដោយចែកទៅតាមនិរុត្តិសាស្ត្រនិងវិធីសាស្ត្រតែងនិពន្ធគឺៈ*

**២-១-ដំណាក់កាលទីមួយ** *សម័យកាលទី១ គឺអក្សរសិល្ប៍បុរាណ ឬក៏អក្សរសិល្ប៍សិលាចារឹក ដែលកើតនៅសម័យមុន*

អង្គរ និងសម័យអង្គរ ទម្រង់ភាគច្រើនជារបាក្យត្រ ជាកំណាព្យ ជារបាយការណ៍សកម្មភាពផ្សេងៗ និងអក្សរសិល្ប៍ព្រាហ្មណ៍និយមភាគច្រើនហើយវាបានបង្ហាញពីសកម្មភាពជំនឿក្នុងពុទ្ធសាសនាថេរវាទ (ហីនយាន) ពុទ្ធសាសនាអាចារ្យវាទ(មហាយាន) និងជំនឿក្នុងសាសនាព្រាហ្មណ៍សិវនិយមភាគច្រើនផងដែរ។

អក្សរសិល្ប៍ព្រាហ្មណ៍និយម នៅក្នុងសម័យបុរាណនេះ គឺភាគច្រើនជាស្នាដៃដែលឆ្លុះបញ្ចាំងលើកដំកើងព្រះវិស្ណុ ដែលរឿងរ៉ាវទាំងឡាយភាគច្រើន គឺនិយាយអំពីអវតារបស់ព្រះវិស្ណុ។

**២-២-ដំណាក់កាលទី២** សម័យកាលទី២ គឺអក្សរសិល្ប៍សម័យកណ្តាល (មជ្ឈឹមសម័យ)៖ អក្សរសិល្ប៍សម័យកណ្តាល នេះ គឺផ្តោតទៅលើសម័យក្រោយអង្គរ មកដល់ឆ្នាំ១៩០០ គឺបើគិតរាប់ជាឆ្នាំចាប់ចាកចោលក្រុងអង្គរ ឆ្នាំ១៤៣១ រហូតដល់ឆ្នាំ១៩០០។ សម័យកាលនេះអាចហៅថា អក្សរសិល្ប៍ប្រពៃណី ជាអក្សរសិល្ប៍សាស្ត្រាស្លឹករឹត ជាអក្សរសិល្ប៍ពុទ្ធនិយមបែបខ្មែរ ទទួលឥទ្ធិពលឬគោរពប្រតិបត្តិពុទ្ធសាសនាថេរវាទ។

រឿងរ៉ាវជាច្រើនទាក់ទងនឹងពុទ្ធប្រវត្តិ ដែលដកស្រង់ចេញមកពីគម្ពីរព្រះត្រៃបិដកសុទ្ធដែរគេឃើញស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមចែកជាបីប្រភេទ ទីមួយគឺអក្សរសិល្ប៍ពុទ្ធនិយមសុទ្ធសាធ សំដៅទៅលើគម្ពីរទសជាតក រឿងរ៉ាវទសជាតកនិងរឿងជាតក ៥៤៧ រឿងទៀត ដែលដកស្រង់ចេញពីគម្ពីរសុត្តន្តបិដក ក្នុងព្រះត្រៃបិដក ហ្នឹងមានទាំងរឿងចាបស្រុកចាបព្រៃ ក៏ជារឿងពុទ្ធនិយមសុទ្ធសាធដែរ។ ទី២គឺអក្សរសិល្ប៍ពុទ្ធនិយមក្លាយឬគម្ពីរបញ្ញាសជាតកមាន៥០រឿងហ្នឹង គឺព្រះសង្ឃជំនាន់ក្រោយសម័យអង្គរ មានព្រះសង្ឃខ្មែរ សៀម លាវ ភូមា បានទៅសិក្សាពុទ្ធសាសនានៅប្រទេសស្រីលង្កា ហើយត្រឡប់មកវិញ តែងនិពន្ធរឿងហ្នឹង ហើយរឿងហ្នឹងគេនិពន្ធរួមគ្នា នៅឈៀងម៉ៃ ទើបព្រះសង្ឃទាំងអស់ បានបែកគ្នាមកកាន់ប្រទេសរៀងៗខ្លួន មានរឿងមួយចំនួនដូចគ្នា និងរឿងមួយចំនួនទៀតមិនសូវដូចគ្នាទេ រឿងនេះត្រូវបាននិពន្ធតាមលំនាំគម្ពីរទសជាតកដែរ ប៉ុន្តែបានផ្សារភ្ជាប់ជាមួយនឹងតម្រូវការចាំបាច់ក្នុងសង្គមប្រទេសនីមួយៗ នៅក្នុងសម័យកាលនោះ។ ដូច្នេះបានជាគេ

ឃើញនៅក្នុងគម្ពីរបញ្ញាសជាតកហ្នឹងភាគច្រើនបានបង្ហាញពីសកម្មភាពជាក់ស្ដែងក្នុងការប្រព្រឹត្តិប្រតិបត្តិពុទ្ធសាសនា។ ទីបី គឺ អក្សរសិល្ប៍ពុទ្ធនិយមក្លាយហួសហេតុ (ផ្ទុម) គឺសំដៅលើស្នាដៃទាំងឡាយដែលនិពន្ធនៅក្នុងចុងសម័យលង្វែក និងសម័យឧដុង្គព្រមទាំងដើមសម័យអាណាព្យាបាលបារាំងដែលអ្នកនិពន្ធ និពន្ធតាមគម្ពីរទសជាតកនៅក្នុងសេចក្ដីផ្ដើម និងបញ្ចប់រឿងយកលំនាំដើមដូចជា រឿងក្នុងទសជាតក ប៉ុន្តែនៅក្នុងដំណើររឿងគឺនិយាយអំពីជីវភាពជាក់ស្ដែង ដូចជា ដំណើររឿងស្នេហា ការផ្សងព្រេងរបស់តួអង្គ ឬក៏ដំណើរសង្គ្រាមច្បាំងគ្នាដើម្បីយកជ័យជម្នះ ដែលតាមបែបគោលព្រាហ្មណ៍និយម ទៅដល់ពេលបញ្ចប់រឿងបែបពុទ្ធនិយមនេះហើយទើបគេហៅថា ពុទ្ធនិយមក្លាយហួសហេតុ ឬផ្ទុម។

**២-៣-ដំណាក់កាលទី៣** សម័យកាលទីបី គឺអក្សរសិល្ប៍ទំនើប គិតចាប់ពីឆ្នាំ ១៩០០ រហូតមកដល់បច្ចុប្បន្នសំដៅទៅលើស្នាដៃប្រលោមលោកពាក្យរាយ ដែលនិយាយអំពីបញ្ហាជីវភាពជាក់ស្ដែង លែងពាក់ព័ន្ធជាមួយមនោគមន៍វិជ្ជាសាសនាហើយ ហើយលក្ខណៈពិសេសអក្សរសិល្ប៍ទំនើប គឺការកកើតនៅរោងពុម្ព ដែលមានការបោះពុម្ពជាសៀវភៅ លែងចារឹកលើថ្ម លែងចារលើស្លឹកទ្រាំងទៀតហើយ រីឯការតែងនិពន្ធក៏លែងតែងជាពាក្យកាព្យទៀតដែរ គឺសរសេរជាអក្សររាយ។

## ឯកសារពិគ្រោះ


១-ឃីង ហុកឌី *ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ ២០០៣*

២-ស៊ុំ ឈុំប៊ុន *មេរៀនឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រ សកភព ១៩៩៩*



សិលាចារឹក វ៉ូកាញ់ ចារឹកប្រហែលនៅចុងសតវត្សទី២ ឬដើមសតវត្សទី៣ នៃគ្រិស្តសករាជ
និយាយអំពីជំនឿរបស់ព្រះបាទស្រីមារៈ ចំពោះព្រះពុទ្ធសាសនា

# ទស្សនៈនានាក្នុងការរើសគូស្រករ ក្នុងអក្សរសិល្ប៍សម័យអាណានិគមនិយមបារាំង

*ដោយៈ បណ្ឌិត* **ឃិន យ៉ន់** *ប្រធាននាយកដ្ឋានកិច្ចការទូទៅ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា*

*សម័យអាណានិគមនិយមបារាំងជាដំណាក់កាលមួយដ៏គួរឱ្យកត់សម្គាល់ក្នុងប្រវត្តិអក្សរសាស្ត្រអក្សរសិល្ប៍ខ្មែរ។ អំណាចអាណាព្យាបាលបារាំង ដែលក្រោយមកបានប្រែក្លាយជាអំណាចអាណានិគមនិយម បានរៀបចំប្រមែប្រមូលរាល់សេចក្តីត្រូវការរបស់គេពីដែនដីកម្ពុជា រៀបចំចាត់ចែងរាល់គោលនយោបាយលើវាសនា អនាគតកម្ពុជា ដោយគ្មានសួរយោបល់ឯកភាពពីសាមីម្ចាស់ស្រុកឡើយ។*

*អំណាចអាណានិគមនិយមបារាំងបានកែប្រែស្ទើររាល់របៀបរបប បែបបទការងារ ជាបន្តបន្ទាប់ ដោយព្យាយាមធ្វើទំនើបកម្មលើគ្រប់វិស័យ។ ចាប់ពីទសវត្សទី២ នៃសតវត្សទី២០មក បារាំងបានលូកដៃចូលកែប្រែវិស័យសិក្សាធិការអប់រំ ចាប់ពីការសិក្សាបែបប្រពៃណី មកជាសាលាវត្តកែប្រែ ដោយបញ្ចូលគ្រូបង្រៀនជាគ្រូហស្ត បញ្ចូលក្បួនគរុកោសល្យទំនើប អនុញ្ញាតឱ្យសិស្សស្រីបានចូលរៀន ហើយប្រែក្លាយមកជាសាលាទំនើបពេញលេញ មានកម្មវិធីសិក្សាច្បាស់លាស់ ដោយមានភាសាបារាំងជាភាសាគោល។ ការសិក្សាកម្មវិធីសិក្សាថ្មី ការចេះដឹងភាសាបារាំងគួបផ្សំជាមួយទស្សនៈយល់ដឹងបែបបស្ចឹមប្រទេស ដែលជះឥទ្ធិពលតាមរយៈជីវភាពរស់នៅការប្រឡូកការងារជាមួយមន្ត្រីរដ្ឋការអាណានិគម និងការអានស្តាប់ប្រលោមលោកភាសាបារាំង បានធ្វើឱ្យមានការផ្លាស់ប្តូរវិធីសាស្ត្រតែងនិពន្ធប្រលោមលោកខ្មែរព្រមទាំងទស្សនៈនានាក្នុងជីវភាពរស់នៅប្រចាំថ្ងៃ រហូតដល់ការប្រឆាំងជំទាស់នឹងផ្នត់គំនិត ទំនៀមទម្លាប់ប្រពៃណីមួយចំនួនដែលបានអនុវត្តជាបន្តបន្ទាប់មកតាំងពីសម័យបុរាណរហូតដល់ដើមសតវត្សទី២០នេះ។*

*ផ្នត់គំនិត ទំនៀមទម្លាប់ប្រពៃណីមួយចំនួនដែលគេយល់ថា មានលក្ខណៈចាស់គំរិល មិនទាន់សម័យ មិនមានឥទ្ធិពលល្អ ជាវិជ្ជមានដល់បែបផែនជីវិត ដល់ការរស់នៅប្រចាំថ្ងៃរបស់មហាជន ត្រូវបានរិះគន់ជាបន្តបន្ទាប់តាមរយៈស្នាដៃអក្សរសិល្ប៍នាដើមសតវត្សទី២០។*

## ១-លោកទស្សនៈពីរផ្ទុយគ្នាក្នុងសម័យកាលតែមួយលើការរៀបចំគូស្រករ

ការរៀបចំគូស្រករកូនចៅ គឺជារឿងសំខាន់ចំបាច់មួយដែលមាតាបិតា អាណាព្យាបាលទូទៅតែងយកចិត្តទុកដាក់គិតគូររៀបចំជានិច្ច។ នៅសម័យបុរាណជានិច្ចកាល ការរៀបចំគូស្រករ សុទ្ធតែត្រូវបានធ្វើឡើងដោយឪពុកម្តាយ ឬអាណាព្យាបាលដែលភាគច្រើន ច្រើនតែមិនសួរចិត្តកូនចៅ វៀរលែងតែក្នុងសាស្ត្រាល្បែងមួយចំនួនដែលបង្ហាញពីដំណើរជីវិតព្រះរាជបុត្រានៃក្សត្រនគរណាមួយ ទៅរៀនសិល្បសាស្ត្រពីឥសីនៅឯស្រុកនិគមឆ្ងាយ តែងតែពេញចិត្តនារី នៅតាមតំបន់ដែលខ្លួនឆ្លងកាត់ ហើយក៏ប្រលោមលួងលោមស្នេហាពីនារីនោះដោយមិនសួរនាំយោបល់ពីចាស់ទុំ។ សភាពព្រឹត្តិការណ៍បែបនេះ មាននៅជាច្រើនរឿងក្នុងសាស្ត្រាល្បែង ហើយរឿងខ្លះរាជបុត្រមួយអង្គ មានមហេសីចិត្តឯងដល់ទៅបី បួនឬ ប្រាំមួយ ប្រាំពីរ។ ការរើសគូស្នេហ៍ចិត្តឯងនេះ មានតែចំពោះតួអង្គរាជបុត្រា ក្នុងសាស្ត្រាល្បែងតែប៉ុណ្ណោះក្រៅពីនេះចំពោះកូនចៅប្រជារាស្ត្រគឺពុំទាន់ឃើញមានស្នាដៃអក្សរសិល្បបែបប្រពៃណីណាលើកឡើងឡើយ។

នៅដើមសតវត្សទី២០ ក្រោយទទួលឥទ្ធិពលបស្ចឹមប្រទេស តាមរយៈរបបអាណានិគមនិយមបារាំង ផ្នត់គំនិតថ្មីនៃការរៀបចំគូស្រករ ក៏លេចចេញជារូបរាង និងសកម្មភាពឡើង ហើយលាតត្រដាងក្នុងស្នាដៃប្រលោមលោកទំនើប ដែលទើបមានរូបរាងដែរ ដោយសារអ្នកនិពន្ធដែលទទួលបានការសិក្សាអប់រំទំនើប។

ផ្នត់គំនិតថ្មី សេរីភាពក្នុងការជ្រើសរើសគូស្រករ ដែលទើបដុះដាលឡើងបានប្រឈមគ្នាជាមួយផ្នត់ គំនិតចាស់បុរាណ «នំមិនធំជាងនាឡិ» បានលេចចេញជាហូរហែក្នុងស្នាដៃល្បីៗ ជាច្រើនមានជាអាទិ៍ ក្នុងរឿងទុំទាវ ដែលនិពន្ធដោយព្រះភិក្ខុបទុមត្ថេរសោម នាឆ្នាំ១៩១៥ បានបង្ហាញពីបដិបក្ខមតិទស្សនៈគ្នារវាងតួអង្គនាងទាវ ដែលទាមទារនូវសិទ្ធិសេរីភាពផ្ទាល់ខ្លួនក្នុងការជ្រើសរើសយកបុរស ដែលខ្លួនស្រឡាញ់ មិនអនុលោមតាមការសម្រេចរបស់ម្តាយ ប្រឈមជាមួយនឹងម្តាយនាង ដែលប្រកាន់យកទស្សនៈចាស់គំរិល «នំមិនធំជាងនាឡិ» ក្នុងការរៀបចំគូស្រករឱ្យកូនចៅ ចាត់ចែងវាសនាអនាគតនាង ឱ្យរៀបការជាមួយបុរសដទៃ ជាកូនមន្ត្រីធំ មានទ្រព្យសម្បត្តិច្រើន តែមិនជាទីពេញចិត្តរបស់នាងទាវ។

### ១-១-ទស្សនៈផ្ទុយគ្នាក្នុងស្នាដៃតែមួយ

#### ១-១-១-ទស្សនៈផ្ទុយគ្នាក្នុងស្នាដៃអក្សរសិល្បបែបប្រពៃណី

នៅក្នុងការស្វែងយល់ពីទស្សនៈផ្ទុយគ្នាក្នុងស្នាដៃអក្សរសិល្បប្រពៃណី នៅដើមសតវត្សទី២០ ការសិក្សាអនុវត្តលើស្នាដៃលេចធ្លោមួយ ជាស្នាដៃគំរូក្នុងសម័យកាល

ដែលគ្រប់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវឱ្យតម្លៃមិនអាចគណនាបាន គឺរឿងទុំទាវនិងរឿងទាវឯក។មូលហេតុដែលធ្វើឱ្យការសិក្សានេះផ្ដោតការយកចិត្តទុកដាក់ទៅលើស្នាដៃទាំងពីរចំណងជើងនេះ ដោយសារដំណើររឿងមានលំនាំប្រហាក់ប្រហែលគ្នាស្ទើរតែទាំងស្រុង ហើយស្នាដៃបានផ្ដោតទៅលើបញ្ហាព្រឹត្តិការណ៍តែមួយ ដោយគ្រាន់តែអ្នកនិពន្ធលើកយកមកចងក្រងមុនក្រោយគ្នា ប្រមាណជិតកន្លះសតវត្សតែប៉ុណ្ណោះ។

ចំពោះស្នាដៃរឿងទាវឯកនេះ ក្នុងរយៈពេលកន្លងមកពុំទាន់មានអ្នកសិក្សាណាធ្វើការសិក្សាលម្អិតស៊ីជម្រៅនៅឡើយ មានតែលោកបណ្ឌិតសភាចារ្យ ឃីង ហុកឌី ប៉ុណ្ណោះដែលបានយកសាស្ត្រាទាវឯកនេះមកចងក្រងជាសៀវភៅ ដោយរក្សាទុកនូវពាក្យពេចន៍នាសម័យនោះទាំងស្រុង និងមានសរសេរជាភាសាខ្មែរទំនើបផង និងបកប្រែជាភាសាបារាំង ផង។

សាស្ត្រាទាវឯក ចារចប់នៅថ្ងៃសៅរ៍ ១៣កើត ខែអស្សុជ ចុល្លសករាជ១២៦៦ ឆ្នាំជូតទោស័ក(ចំាចប្ប់ នៅថ្ងៃសៅ ១៣កើត ខែអាសុច ចុលសក្ខ់រាជ១២៦៦ ឆ្នាំជូតទោសក្ស់)[1]។ បើគិតជាព.ស គឺត្រូវនឹងព.ស ២៤៤៨។ បើគិតជាគ.ស គឺត្រូវនឹង១៩០៥។

រឿងទាវឯកត្រូវបានកវីខ្មែរ លាតត្រដាងតថភាពខ្មែរក្នុងសម័យលង្វែក ដែលមានបញ្ជាក់ព្រះនាមព្រះរាជាព្រះបាទរាមា។ នៃះនិងដំណាលកាលដើមដាន មុនមានខ្សួតខ្សានសោយរាជា ស្ដេចទ្រង់ព្រះនាមព្រះរាមា គ្រព្ដុំគ្រងកម្ពុជាធិប្ដីយ៍[2]។

## ព្រះបាទរាមាក្នុងសាស្ត្រាទាវឯក ក្នុងរឿងទុំទាវ ជានរណា?

ការសិក្សាពីសង្ខេបប្រវត្តិនៃរឿងយើងឃើញថារឿងទាវឯក ស្ថិតនៅក្នុងរជ្ជកាលព្រះបាទរាមាជើងព្រៃ ដែលមានរាជធានីនៅស្រីសន្ធរ ក៏ប៉ុន្តែនៅក្នុងដំណើររឿង អ្នកនិពន្ធបែរជាប្រើរាជធានីនៅឧដុង្គទៅវិញដូចមានឃ្លាកាព្យបញ្ជាក់ដូច្នេះថា៖

បូនើ្យមានព្រះបន់ទូលមក
ឱ្យយកពេជ្ឈឯកនិងអាញណា
ចូលទៅឧដុងថ្វ្យខ្សត្រារ
ត្ងំបងឱ្យជាចម្រៀងថ្វ្យ[3]។
ពេលបា្យបានដល់ឱដុង
អាម៉ាស្សយកថង់នោះឯងមិញ
ជូនទោរមើនឯកស្រាយថង់ចេញ
ឃើញស្វារបារ្សីពេញចិត្រអរ[4]។

ចំណែកនៅក្នុងឯកសារមហាបុរសខ្មែរវិញ ក៏មានតំណាលអំពីព្រឹត្តិការណ៍នាងទាវ និងម៉ឺនឯក ផងដែរ ប៉ុន្តែនៅក្នុងរជ្ជកាល

---

[1] ឃីង ហុកឌី សាស្ត្រា *ទាវឯក* ឆ្នាំ២០០៥ ទំព័រ១១០។

[2] -ដ- ទំព័រ៦៩។

[3] ឃីង ហុកឌី សាស្ត្រា *ទាវ ឯក* ជ-ឯ-ម ទំព័រ៧៩-៨០។

[4] -ដ- ទំព័រ៩៧។

ព្រះបាទបរមិន្ទរាជា ទៅវិញ។ ហើយព្រះរាជាអង្គនេះ ត្រូវបានឯកសាររាជពង្សាវតានេះកត់ត្រាទុកថាជាព្រះរាជាប្រកបដោយទសពិធរាជធម៌ មានវីរភាពក្លាហាន មានជោគជ័យក្នុងសង្គ្រាមផង ផ្ទុយពីព្រះបាទរាមាដែលជាស្តេចល្មោភស្រី ចាប់ដណ្តើមប្រពន្ធគេ មិនគិតគូរខ្វល់ខ្វាយពីរាជកិច្ចរបស់នគរ និងសុខទុក្ខប្រជារាស្ត្រ។ ក្រៅពីនេះ ក៏នៅមានព្រះរាជាមួយអង្គទៀតដែលប្រព្រឹត្តអំពើអបាយមុខ ចាប់ពង្រត់ប្រពន្ធគេផងដែរ គឺករណីព្រះពញាតន់ ដែលចាប់យកនាងទាវ ជាប្រពន្ធរបស់ពញាចី យកទៅវាំង នាងទាវមានស្វាមីភក្តិជាមួយប្តី អត់បាយ១០ថ្ងៃ ក៏ស្លាប់ទៅ។ ដំណឹងនេះដល់ពញាចីជាស្វាមី ខឹងខ្លាំងណាស់ក៏ចុះចូលនឹងព្រះរាមកែវព្រះភ្លើង ចូលលុកធ្វើគត់ព្រះពញាតន់ ចោលទៅ។

ចំពោះបញ្ហាស្នេហា នៅក្នុងរឿងទុំទាវ ក្តី ក្នុងរឿងទាវឯកក្តី តួអង្គឯក នាងទាវ ជាបុគ្គលដែលប្រកាន់យកទស្សនៈជំហរផ្ទាល់ខ្លួនក្នុងការជ្រើសរើសគូស្រករ ដោយសម្រេចចិត្តជ្រើសយកបុរស ជាទីពេញចិត្តរបស់ខ្លួនមកធ្វើជាគូអនាគត ជាប្តីមិនអនុលោមទៅតាមការចាត់ចែងរបស់ម្តាយ។ ម្តាយនាងទាវ បានរៀបចំឱ្យនាងទាវ ទៅម៉ឺនងួន ជាកូនស្តេចត្រាញ់អរជូន ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ ជាស្តេចត្រាញ់ខ្នងពោះក្រៅ មានយសស័ក្តិធំខ្ពស់ ទ្រព្យសម្បត្តិស្តុកស្តម្ភ ដែលមហាជនយល់ថា មានអនាគតល្អ មានមុខមាត់ខ្ពង់ខ្ពស់ទៅថ្ងៃអនាគតសម្រាប់នាងទាវ។

ទស្សនៈរបស់មនុស្សចាស់ខ្មែរ ជាឪពុកម្តាយ ជាពិសេស ស្ត្រីជាម្តាយតែម្តង តែងយកចិត្តទុកដាក់ខ្ពស់ទៅលើការរៀបចំទុកដាក់កូនចៅ ដោយចង់ឱ្យកូនទោះបីកូនប្រុសក្តី កូនស្រីក្តីមានអនាគតល្អ មានប្តីមានប្រពន្ធ ជាកូនអ្នកមាន អ្នកធំ ជាអ្នកមានបណ្តាស័ក្តិខ្ពស់អាចឱ្យកូនចៅខ្លួនរស់ស្រួលទៅថ្ងៃអនាគត មិនមានជួបប្រទះការលំបាកខ្វះខាតក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ ជាងនេះទៅទៀត ស្ត្រីជាម្តាយ ដែលមានកូនស្រីមានរូបសម្បត្តិស្រស់ស្អាត តែងតែចង់ឱ្យកូនស្រីរបស់ខ្លួនមានអនាគតល្អជាមួយបុរសណាដែលគាត់យល់ថា កូនស្រីគាត់អាចផ្ញើវាសនា អនាគតជាមួយទៅថ្ងៃក្រោយបាន។ យាយជាម្តាយនាងទាវ ទាំងក្នុងរឿងទុំទាវ ទាំងក្នុងរឿងទាវឯក គឺសុទ្ធតែមានគំនិតបែបនេះ (ទស្សនៈនំមិនធំជាងនាឡិ) ដូច្នេះហើយទើបគាត់ព្យាយាមរៀបចំកូនស្រីរបស់គាត់ឱ្យបានជួបជាមួយ បុរសជាអ្នកមានទ្រព្យ មានអំណាចដែលគាត់ស្គាល់ និងអាចចាត់ចែងអាពាហ៍ពិពាហ៍ជាមួយកូនស្រីគាត់បានគឺម៉ឺនងួន កូនប្រុសរបស់ឧកញ៉ាអរជូន។

ចំណែកឯនាងទាវ ជាកូនស្រីវិញពុំមានទស្សនៈផ្ទត់គំនិតដូចម្តាយនាងទេ។

នាងជាស្រីវ័យក្មេងនៅក្នុងម្ចប់ប៉ុន្តែមិនរម្ងាប់ចិត្តទៅក្នុងម្ចប់ ប្រព្រឹត្តខ្លួនទៅតាមអារម្មណ៍ដោយគ្មានការទប់ស្កាត់ខ្លួនឯងក្នុងលក្ខណៈ «ឃើញភ្ញាម ស្រឡាញ់ភ្លែត» ហើយអនុវត្តបែប«ទុំមុនស្រគៀល» ជាមួយទុំជាតួអង្គឯកប្រុសតែម្តង។

នាងទាវឃើញឯកបើកទ្វារបានប្រះទោរលើរខ្នើយកៀសំពាណយកភួយដណ្តប់គ្របអប្រប្រានធ្វេសធ្វេវិញ្ញាណក្មេចស្មារដើ្យ។

អ្នកឯកផ្ទេកផ្ងីតចូលទៅទៀបដាក់ដៃ្យទៅស្ទាបអង្អែលខ្នើយស៍សើហដំណើរផ្លូនពីសី្យ នាងល្អរពេត្យក្រែរកផ្ញឹមគ្មាន។ នាងទាវប្រែរប្រានធ្វើជាភ្ញាក

ដិងស្មារដើ្យជាក័ធ្វើជាអឿន
ក្រោកឡើងសញ្ជប់ជ្រុព្ត់ស្រមៀន
ផ្ទព្ធ់គៀនវ្ញំនងឯកឱបជាប័។
អ្នកឯកញ័ញិមបើបកគ័ត្រោរ
លោមថាហ្បែផ្លួលមាស័ចំណាប័
បើផ្អូនមិតមាសមិនរង៉ាព្ធ័
បងនិងត្រឡប់វិលទៅវិញ[៥]។

ក្នុងរឿងទាវឯក ឯកនិងនាងទាវតែងតែទាក់ទងគ្នានៅពេលយប់ អស់រយៈកាលបីខែ ដោយយាយម្តាយនាងទាវ ពុំបានដឹងឡើយ ពីព្រោះវេលាយប់ជាឱកាសល្អមួយដែលគូស្នេហ៍អាចទាក់ទងស្នេហាគ្នានិងងាយស្រួលក្នុងការលាក់កំបាំងការពិតផងដែរ ហើយម្យ៉ាងវិញទៀត ផ្ទះរបស់អ្នកទាំងពីរនៅជិតគ្នាផង ទើប ឯក មានឱកាសអាចស្កាត់មកជួប ទាវ បានរាល់យប់។

ទោះបីជានាងទាវ មានអារម្មណ៍ឆាប់ស្រើបស្រាលក្នុងរឿងស្នេហាក៏ពិតមែន ប៉ុន្តែនាងពុំមានចិត្តសាវ៉ា ភ្លើតភ្លើនក្នុងរឿងស្នេហា ទៅស្រឡាញ់ប្រុសពីមួយទៅមួយឡើយ។ នាងទាវ មានភក្តីភាព ស្មោះស្ម័គ្រចំពោះតែទុំ (ឯក) ប៉ុណ្ណោះ។

នៅក្នុងរឿងទុំទាវ និងរឿងទាវឯក បានបង្ហាញពីទស្សនៈពីរខុសគ្នារវាងមនុស្សចាស់ (ឪពុកម្តាយ) និងអ្នកជំនាន់ក្រោយជាកូន ចំពោះបញ្ហាស្នេហា ពោលគឺឪពុកម្តាយ (យាយម្តាយទាវ ឧកញ៉ាអរជូនជាឪពុកម៉ឺនងួន) តែងតែប្រកាន់នូវទស្សនៈនំមិនធំជាងនាឡិ ក្នុងការរៀបចំចាត់ចែងវាសនាអនាគតកូនចៅ ដោយកូនចៅត្រូវតែគោរព ស្តាប់បង្គាប់តាមការរៀបចំរបស់ឪពុកម្តាយ មិនត្រូវប្រឆាំងជំទាស់រឹងទទឹងដោយប្រការណាមួយអ្វីឡើយ។ ផ្ទុយទៅវិញអ្នកជំនាន់ក្រោយជាកូនចៅ បែរជាមានគំនិតផ្ទុយស្រឡះពីចាស់ទុំជាឪពុកម្តាយដោយការព្យាយាមដណ្តើមសិទ្ធិជ្រើសរើសគូអនាគតដោយខ្លួនឯង មិនចំណុះឱ្យគំនិតឪពុកម្តាយ ដែលតែងតែគិតថា ខ្លួនស៊ីអំបិលច្រើនជាងកូនស៊ីបាយ ស្គាល់ពន្លឺព្រះអាទិត្យមុនកូន ជាអ្នកផ្តល់កំណើតឱ្យកូន ស្គាល់សង្គមច្បាស់ជាងកូន មានបទពិសោធន៍ច្រើនជាងកូន អាច

[៥] ឃីង ហុកឌី សាស្រ្តា *ទាវ ឯក* ជ-ឯ-ម ទំព័រ៧៧-៧៨។

នាំកូនទៅរកអនាគតបានល្អជាងកូន ជ្រើសរើសដោយខ្លួនឯង។

### ១-១-២ ទស្សនៈផ្ទុយគ្នាក្នុងស្នាដៃប្រលោមលោកទំនើប

ប្រលោមលោកទំនើបនាដើមសតវត្សទី២០ ដែលត្រូវបានលើកយកមកធ្វើការសិក្សាស្វែងយល់អំពីទស្សនៈផ្ទុយគ្នាក្នុងការរើសគូស្រករនាពេលនេះ គឺរឿងផ្កាស្រពោន របស់អ្នកនិពន្ធ នូ ហាច ដែលត្រូវបាននិពន្ធឡើងនាឆ្នាំ១៩៤០។

រឿងផ្កាស្រពោន និពន្ធឡើងនាចុងសម័យអាណាព្យាបាលបារាំងក្នុងឆ្នាំ១៩៤០។ ដំណើររឿងបរិយាយ ពីជីវិតស្នេហាដ៏កម្សត់មួយគូដែលរងគ្រោះ និរាសព្រាត់ប្រាស់ដោយការប្រកាន់ខ្ជាប់ទស្សនៈចាស់គំរិលរបស់មាតាបិតា អាណាព្យាបាលក្នុងការរៀបចំវាសនាអនាគតឱ្យកូនចៅ ក្នុងសម័យអាណាព្យាបាលបារាំង។ ការវិវឌ្ឍន៍ខាងផ្នត់គំនិតរបស់យុវជនដែលបានទទួលការសិក្សាពីសាលាទំនើបតាមទស្សនៈជឿនលឿន ប៉ុន្តែស្ថិតក្រោមគំនាបទំនៀម ទម្លាប់ចាស់គំរិលរបស់មាតាបិតាអាណាព្យាបាលមួយចំនួន ធ្វើឱ្យយុវជនភាគខ្លះរងគ្រោះដោយគ្មានវិធីដោះស្រាយ។

រឿងផ្កាស្រពោន បានតែងនិពន្ធឡើងដើម្បីបង្ហាញពីស្ថានភាពរបស់នារីខ្មែរដែលឋិតនៅចន្លោះផ្នត់គំនិតចាស់និងទស្សនៈថ្មីនៃលោកទំនើបក្នុងការរើសគូស្រករតាមរយៈតួអង្គនាងវិធាវី។ ផលវិបាកដែលបណ្ដាលមកពីការប្រឈមមុខគ្នារវាងទស្សនៈនំមិនធំជាងនាឡិ (ការចាត់ចែងអនាគតកូនដោយមិនសួរចិត្តកូនជាមុន ដោយសម្លឹងមើលឃើញតែទ្រព្យសម្បត្តិហើយយល់ថា ទ្រព្យសម្បត្តិជាប្រភពតែមួយគត់នៃសុភមង្គលរបស់យាយនួនម្ដាយនាងវិធាវី) និងផ្នត់គំនិតថ្មីក្នុងការរើសគូស្រករដែលបង្កប់ក្នុងតួអង្គនាងវិធាវី ព្រមជាមួយគុណសម្បត្តិជាស្រីគ្រប់លក្ខណ៍ (នារីដែលមានលម្អទាំងព្រមពីធម្មជាតិ ជាកូនកតញ្ញូ លុះដោយគន្លងដំបូន្មានឪពុកម្ដាយ មានចំណេះវិជ្ជា មានកក្តីភាពចំពោះស្នេហាយ៉ាងស្មោះស្ម័គ្រ) ដែលអ្នកនិពន្ធផ្ដល់ឱ្យនាង បានធ្វើឱ្យបុប្ផាក្រពុំដ៏ស្រស់ស្អាតមួយទង ដែលជាទីប្រាថ្នានៃភូមរាទាំងពួងក្លាយ ទៅជាផ្កាស្រពោនទៅវិញ។ ក្នុងរឿងផ្កាស្រពោន អ្នកនិពន្ធបានឆ្លុះបញ្ចាំងពីឥទ្ធិពលនៃទំនៀមទម្លាប់និងប្រពៃណីដ៏ចាស់គំរិល (យូរលង់) ដែលមានទំនាក់ទំនងជាមួយគ្រួសារ (Bondage) ជាពិសេសទៅលើស្ត្រីខ្មែរ។ តួឯកស្ត្រីក្នុងរឿងជាជនរងគ្រោះដោយការនិយមឱ្យតម្លៃនៅក្នុងសម័យបុរាណដែលមានម្ដាយនាងជាតំណាង។ ក្នុងពេលវិវត្តដ៏ធំមួយនៃកម្ពុជា នាងវិធាវី ជាតួអង្គតំណាងអាកប្បកិរិយានិងសីលធម៌នៃប្រពៃណីរបស់ស្រីក្រមុំ ប៉ុន្តែការត្រិះរិះពិចារណារបស់ស្ត្រីសម័យថ្មីបានរីករាលដាលដោយការផ្លាស់ប្ដូររបស់សង្គម។ ទោះបីយ៉ាងណាក៏ដោយ នាងជាតួអង្គដែល

ស្ថិតនៅចន្លោះពិភពលោកពីរ គឺបុរាណ និងសម័យ។

ក្នុងរឿងផ្កាស្រពោន បញ្ហាជាច្រើនកើតឡើងជុំវិញរឿងស្នេហា។ ស្នេហានេះផ្តើមឡើងដោយសារការផ្សំផ្គុំរវាងចាស់ៗតាំងពីសាមីខ្លួននៅកុមារវ័យ។ ស្នេហានេះបានដុះដាលឡើងដោយចិត្តនិងចិត្ត ឯស្នេហាចិត្ត និងចិត្តនេះវិញជាស្នេហាមួយដែលឋិតនៅលើឧត្តមគតិនឹងនរ។ ស្នេហាចិត្តនិងចិត្តឥតត្រូវការពឹងផ្អែកលើប្រាក់កាស់លើបក្សពួក។ ទំនៀមទម្លាប់ខ្មែរបង្គាប់ឱ្យគូស្នេហ៍គោរពកោតខ្លាចប្រពៃណី។ គេមិនមិនត្រូវធ្វើខុសឬរំលោភលើប្រពៃណីឡើយ។ស្នេហានេះ ជាស្នេហាបែបប្រពៃណី ការជួបគ្នារបស់អ្នកទាំងពីរតែងប្រព្រឹត្តទៅតាមគន្លងចរិយាសាស្ត្រខ្មែរ ដោយខ្លាចក្រែងមានពាក្យនិន្ទាពីអ្នកដទៃជានិច្ច"...អញ្ជើញបងទៅដោយក្សេមក្សាន្តចុះៗខ្ញុំមិនហ៊ាននៅនិយាយតែពីរនាក់នឹងបងយូរពេកទេខ្លាចមានពាក្យនិន្ទាទៅថ្ងៃក្រោយ"[៦]។

ស្នេហានេះជាស្នេហាស្ថិតក្រោមគំនាបឥទ្ធិពលនៃទ្រព្យសម្បត្តិ។ ទុក្ខព្រួយនៃសេចក្តីស្នេហាបានប្រាកដឡើងជាដំបូងនាពេលដែល ប៊ុន ធឿន ធ្វើដំណើរត្រឡប់ទៅភូមិកំណើតពេលវ៉ាកងក្រោយពីបានទទួលសំបុត្រពីនាងសោភ័ណជាប្អូន "ឱគំនិតដែលតែងធ្វើឱ្យស្រមៃឃើញខ្លួនទៅរៀនឯប្រទេសក្រៅ ឱ្យបានជ្រៅជ្រះ! ឱ្យពាក្យដែលសច្ចាថាប្រុងនឹងចិញ្ចឹមគូសង្សារឱ្យបានសុខសំរាន្តឪពុកម្តាយអើយខ្ញុំសែនលំបាក !..."[៧]។ ឯនាងវិធាវី វិញក៏មិនចាញ់ ប៊ុនធឿន ដែរ នាងត្រូវទទួលរងទុក្ខព្រួយបារម្ភចំពោះស្នេហារបស់ខ្លួន ក្រោមសម្ពាធឥទ្ធិពល ទ្រព្យសម្បត្តិដែលបានចូលទៅពង្វក់ម្តាយជាទីគោរពស្រឡាញ់របស់នាង ៖

ឱគូសង្សារថ្មើមប្រម៉ាត់
កម្មអ្វីមកកាត់ឱ្យព្រាត់ខ្លាយ
ពីថ្ងៃនេះទៅបែកចេញឆ្ងាយ
ឱស្តាយសែនស្តាយ
ស្តាយខ្លួនក្មេង។
ម៉ែអើយមានសីលនៅពេញខ្លួន
ម្តេចឱ្យកូនសួនសោកសង្រេង
ម្តេចហ៊ានផ្តាច់កូនពីគូព្រេង
វង្វេងនេះព្រោះតែក្តីលោភ[៨]។

ស្នេហានេះ ក៏ស្ថិតក្រោមគំនាបឥទ្ធិពលសាសនាផងដែរ។ អបិយជំនឿក៏បានចូលរួមចំណែកយ៉ាង សកម្មក្នុងការបំបែកបំបាក់គូស្នេហ៍នេះដែរ។ ឥទ្ធិពលនៃពាក្យទំនាយរបស់ព្រះសង្ឃវត្តពោធិ៍បានបណ្តាលឱ្យមានផលវិបាកយ៉ាងអាក្រក់ ដោយធ្វើឱ្យយាយទួនជឿជាក់យ៉ាងងងឹតងងុលថា កូន

---

[៦] នូ ហាច *ផ្កាស្រពោន* ជ-ឯ-ម ទំព័រ១១។

[៧] -ដ- ទំព័រ១០។

[៨] នូ ហាច *ផ្កាស្រពោន* ជ-ឯ-ម ទំព័រ៨៧។

គាត់នឹងបានសោយសុខប្រកបដោយសុកមង្គលលើគំនរទ្រព្យសម្បត្តិ ដោយពុំបានពិចារណាឃើញពីទុក្ខប៉ុនភ្នំដែលនាងកំពុងទូល "ឱព្រះភិក្ខុអើយ! ទំនាយក្បួនតម្រានឹងពាក្យអត្ថាធិប្បាយតាមគម្ពីររបស់លោកដែលជាអ្នកទ្រទ្រង់ព្រះពុទ្ធសាសនា នៃព្រះបរមគ្រូនោះ បែរជានាំជនទាំងពីរដែលមានសេចក្តីស្នេហាទៅមកយ៉ាងធំបំផុតឱ្យខានជួបមុខគ្នាទៅវិញ ហាក់ដូចជាលោកជួយប្រានគូសង្សារនេះទម្លាក់ទៅរណ្តៅទុក្ខសង្រេង"[៩]។

ទ្រព្យសម្បត្តិជាកត្តាកំណត់ចិត្តគំនិតអាកប្បកិរិយាមនុស្សមួយយ៉ាងប្រត្យក្ស។ ពេលដែលចឹកប៊ុនថន ខាតជំនួញស្រូវដោយត្រូវទឹកលិចកណ្តាលទន្លេគំនិតសម្ភារនិយម បានប្រត្យក្សឡើងក្នុងខួរក្បាលយាយនួន។ គំនិតនេះបានជំរុញឱ្យគាត់សម្រេចចិត្តផ្តាច់កូនផ្តាច់ចៅ ដែលស្វាមីគាត់កាលនៅរស់ផ្តែផ្តាំទុកដាក់នាងវិជារី និងប៊ុនធឿនជាគូនឹងគ្នា "ចាន់អើយ ខ្ញុំក៏គិតនឹងផ្តាច់ដែរ តែមកតុះតុញមិនដឹងនឹងធ្វើដូចម្តេច។ នឹងធ្វើសំបុត្រទៅប្រាប់ចឹកប៊ុនថនភ្លាមទៅដូចជាឯងចិត្តអាក្រក់ពេក។ ឮតែគេខាតស្រូវភ្លាមក៏ថាផ្តាច់កូន ផ្តាច់ចៅភ្លាម"។

ទ្រព្យសម្បត្តិនេះ ជាបញ្ហាមួយដែលវិលជុំវិញសេចក្តីស្នេហា ធ្វើឱ្យមានដំណើរវិវឌ្ឍផ្លាស់ប្តូរ ចិត្តគំនិតតួអង្គនីមួយៗ ជះឥទ្ធិពលយ៉ាងខ្លាំងដល់សេចក្តីស្នេហានេះ។ "តាមរយៈសំបុត្រ ប៊ុនធឿន ផ្ញើដល់នាងវិជារី គេព្រមលះបង់នាងព្រោះយល់ថា ខ្លួនគេក្រមិនអាចផ្តល់សុកមង្គលដល់នាងបាន "...បងធ្លាក់ក្រហើយ។ លុះបងចេញធ្វើការទៅ ក៏មិនសង្ឃឹមបានប្រាក់ខែប៉ុន្មាន។ ហេតុនេះនាងកុំមានប្រទូសរាយ ទទឹងចិត្តម្តាយនាងដូច្នេះឱ្យសោះ...ណែស៊ិតដល់គេចាស់, ចាស់ដើងទៅ មុខជាបានជាពាណិជ្ជមួយយ៉ាងធំនៅប្រទេសកម្ពុជា។ចំណេះគេក៏មាន សម្បត្តិគេក៏មាន ដែលជាលក្ខណៈមួយអាចនាំឱ្យអូនបានសុខសំរាន្តទៅថ្ងៃក្រោយ។..." តាំងពីនោះមកគេបំភ្លេចនាងសូន្យឈឹងរហូតមិនដឹងថានាងស្លាប់ផង"។

តាមរយៈ ប៊ុន ធឿន ជាយុវជនមួយរូបនោះ លោក នូ ហាច យល់ថាទ្រព្យសម្បត្តិមានឥទ្ធិពលខ្លាំងលើផ្នត់គំនិត ការគិតពិចារណារបស់មនុស្ស ហើយជាអាទិ៍យុវវ័យតែម្តង។ ចំពោះយុវជនដែលកំពុងតែសិក្សា បញ្ហាទ្រព្យសម្បត្តិអាចជះឥទ្ធិពលខ្លាំងដល់ការសិក្សារបស់គេ អាចធ្វើឱ្យគេសម្រេចចិត្តលះបង់ការសិក្សាចោលដោយសារភាពទ័លក្រ។ ម្យ៉ាងវិញទៀត វាក៏មានឥទ្ធិពលខ្លាំងក្នុងរឿងស្នេហាផងដែរ។ បញ្ហាខ្វះខាត ការជួបឧបសគ្គក្នុងរឿងលុយកាក់អាចធ្វើឱ្យយុវជនលះបង់ស្នេហាដែលខ្លួនខំថែរក្សាទុកមកជាយូរបាន។

[៩]-ដ- ទំព័រ៥៣។

នៅក្នុងសង្គមខ្មែរ កត្តាមួយទៀត ដែលមាននាទីសំខាន់ក្នុងការកំណត់វាសនារបស់ស្នេហានោះ គឺការបំបិទសិទ្ធិកូនចៅក្នុងការរើសគូស្រករ។ ការបំបិទសិទ្ធិនេះសំដៅទៅលើការរៀបចំចាត់ចែងរបស់មាតាបិតាអាណាព្យាបាលដោយគ្មានសួរនាំយោបល់ពីកូនចៅជាសាមីខ្លួន មិនផ្តល់សិទ្ធិស្វ័យសម្រេចដល់កូនចៅក្នុងការរៀបចំវាសនាអនាគតផ្ទាល់ខ្លួន។បញ្ហានេះស្តែងឡើងតាមរយៈសកម្មភាពរបស់យាយនួន ម្តាយនាងវិធាវី ក្នុងការសម្រេចចិត្តលើកនាងឱ្យទៅនាយ ណៃស៊ិត។ យាយនួនមិនបានផ្តល់ឱកាសឱ្យនាងវិធាវី ក្នុងការដឹងព័ត៌មានពេលដែលយាយចាន់ នាងថូ ជាម្តាយនាយណៃស៊ិត មកសួរនាំសួរនាំស្តីដណ្តឹងនាង។ លុះបានសម្រេចហើយ ទើបគាត់ប្រាប់ឱ្យនាងដឹង និងត្រៀមខ្លួនចាំដល់ថ្ងៃរៀបការតែម្តង"ឯនិន្នាការទីពីរ គឺការរំលោភសិទ្ធិកូនក្នុងការកសាងគ្រួសារក៏ត្រូវបានលាតត្រដាងតាមរយៈយាយនួននេះដែរ។ តាមការបង្ហាញរបស់អ្នកនិពន្ធ យើងឃើញថា យាយនួនមិនត្រឹមតែមិនសួរយោបល់កូនប៉ុណ្ណោះទេ តែថែមទាំងលាក់មិនឱ្យដឹងពីដំណើរការ រៀបចំគ្រួសារជាមួយគូស្រករថ្មីនោះ"។

ប្រជាជាតិនីមួយៗតែងមានការប្រតិបត្តិសាសនាផ្សេងៗពីគ្នា ទៅតាមប្រពៃណីទំនៀមទម្លាប់ពីបុរាណកាលរៀងមក។ ជំនឿសាសនានេះមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្នត់គំនិត សតិអារម្មណ៍ និងជីវភាពសង្គម។ ក្នុងការរៀបចំគូស្រករទុកដាក់កូនចៅ ខ្មែរមានជំនឿយ៉ាងមុតមាំទៅលើការទស្សន៍ទាយព្យាករណ៍ពីសំណាក់ព្រះសង្ឃដែលជាតួអង្គសាវ័កតំណាងឱ្យព្រះពុទ្ធបរមគ្រូ ពីសំណាក់គ្រូហោរដែលចេះក្បួនតម្រាផ្សេងៗ ឬពីសំណាក់រូបបញ្ចាន់អារក្ខ អ្នកតាបង់បត់អរូបផ្សេងៗ។នៅក្នុងរឿងផ្កាស្រពោនឥទ្ធិពលព្រះពុទ្ធសាសនា និងជំនឿផ្សេងៗបានបង្ហាញខ្លួនយ៉ាងច្បាស់ក្នុងដំណើរការរៀបចំវាសនាអនាគតមនុស្សខ្មែរ ប៉ុន្តែជំនឿនេះគ្រាន់តែជាមធ្យោបាយមួយដែលរុញច្រានអ្នកដែលស្ថិតក្រោមឥទ្ធិពល ខ្លួនធ្លាក់ចុះទៅក្នុងជ្រោះជ្រៅ មិនអាចងើបឡើងមកមើលផ្ទៃមេឃពណ៌ខៀវប្រកបដោយសុទិដ្ឋិនិយមនេះ ហើយរឹតតែមិនអាចបង្កើតគ្រួសារមួយប្រកបទៅដោយសុភមង្គលបានឡើយ។

បញ្ហាមួយទៀត ដែលមានរូបរាងឡើងក្រោយពេលស្នេហាជួបឧបសគ្គ គឺការរក្សាកិត្តិយស។ កិត្តិយសនេះ ជាវត្ថុម្យ៉ាងដែលមនុស្សគ្រប់រូបត្រូវស្វែងរក និងរក្សាទុកមិនឱ្យបាត់បង់។ នៅពេលជួបប្រទះឧបសគ្គក្នុងរឿងស្នេហា បញ្ហាចំពោះមុខដែល ប៊ុនធឿនត្រូវរក្សាមិនឱ្យបាត់បង់នោះគឺ កិត្តិយស។

ដំណើររឿងផ្កាស្រពោន ប្រព្រឹត្តទៅតាមលក្ខខណ្ឌសង្គមសត្យានុម័តិ ដោយអ្នកនិពន្ធមិនបង្កើតស្ថានការណ៍ផ្សេងផ្ទាល់ខ្លួន ឬប្រើអន្តរាគមពីអច្ឆរិយភាពណាមួយដើម្បី

ស្រាយបញ្ហាដែលកាន់តែតានតឹងបន្តិចម្តងៗនោះទេ។ បញ្ហាដែលកើតឡើងក្នុងដំណើររឿង បង្ហាញពីសកម្មភាពជីវភាពសង្គមប្រចាំថ្ងៃក្នុងសម័យកាលរឿង ហើយវិវត្តទៅតាមផ្នត់គំនិតមនុស្សក្នុងសង្គមដែលគេកំពុងតែរស់នៅ។ ក្នុងខណៈដែលតួអង្គប៊ុនធឿនកំពុងតែជួបប្រទះបញ្ហាស្មុគ្រស្មាញដោយសារតែរឿងទ្រព្យសម្បត្តិនោះ បញ្ហាស្នេហាក៏ចោទឡើងជាមួយគ្នាដែរ ដែលបញ្ជាក់ឱ្យយើងឃើញពីតថភាពសង្គម នាសម័យអាណាព្យាបាលបារាំង។ ចំពោះមុខបញ្ហាស្នេហា ប៊ុនធឿន ជាមនុស្សប្រុសធម្មតាម្នាក់ពេលដែលដឹងថាខ្លួនគ្មានសមត្ថភាពថែរក្សាផ្តល់សេចក្តីសុខឱ្យអ្នកជាទីស្រឡាញ់បាន ក៏សម្រេចចិត្តចាកចេញពីនាង ទុកផ្លូវនាងកសាងស្នេហាថ្មីជាមួយបុរសម្នាក់ផ្សេងដែលជាទីពេញចិត្តរបស់ចាស់ទុំ ហើយឈប់រវីរវល់ជាមួយនាង។

ទំនៀមទម្លាប់ "នំមិនធំជាងនាឡិ" ដែលបន្សល់ទុកពីសម័យមុននៅតែប្រាកដខ្លួនយ៉ាងប្រត្យក្សក្នុងការជំរុញដំណើរការជីវភាពប្រចាំថ្ងៃ។ យាយនួនជាម្តាយមួយរូបនាសម័យនោះ គាត់ជាមនុស្សសម្ភារៈនិយមគិតគូរតែពីផលប្រយោជន៍ សេចក្តីសុខផ្ទាល់ខ្លួន និងក្រុមគ្រួសារ មិនបាននឹកនាដល់ខ្លឹមនៃពាក្យសម្តីរបស់ប្តីគាត់ដែលចែកឋានទៅហើយនោះទេ។ ពោលគឺគាត់ឱ្យតម្លៃថា កិត្តិយស សេចក្តីថ្លៃថ្នូរ គឺកើតឡើងដោយសារគំនរទ្រព្យសម្បត្តិ មាសប្រាក់ មិនមែនដោយការប្រព្រឹត្តល្អក្នុងការរស់នៅក្នុងសង្គម ការប្រកាន់ឥរិយាបថល្អ គោរពពាក្យសម្តីនោះទេ។

តាមរយៈរឿងផ្កាស្រពោន អ្នកនិពន្ធ នូ ហាច បានផ្តល់បទពិសោធន៍ជាច្រើនពីបញ្ហាស្នេហាតាមរយៈតួអង្គទាំងពីរ ប៊ុន ធឿន និង នាងវិធាវី ដោយបង្ហាញពីស្ថានភាពផ្សេងៗជាច្រើនជុំវិញរឿងស្នេហាដែលអ្នកនិពន្ធពុំបានរកមធ្យោបាយផ្សេងណាមួយដើម្បីជួយឱ្យស្នេហានេះបានសម្រេចតាមបំណងនោះទេ។ រឿងនេះស្តែងឱ្យឃើញពីទំហំទឹកចិត្តស្នេហារបស់តួអង្គពីររូប ដែលមានសម្ព័ន្ធភាពផ្លូវចិត្តជាមួយគ្នាយ៉ាងស្អិតរមួត តែមានទស្សនៈ ចិត្តគំនិតទីទៃពីគ្នាលើការកសាងគ្រួសារមួយឱ្យរុងរឿងថ្កុំថ្កើង និងប្រកបដោយសុភមង្គល។

## ២-លក្ខណៈនានានៃស្នេហា

(សេចក្តីស្រឡាញ់)

### ២-១ យុវជន និងស្នេហា

យុវជនក្នុងរឿងផ្កាស្រពោន ជាយុវជនដែលពាក់ព័ន្ធជាមួយរឿងស្នេហា។ អ្នកនិពន្ធ នូ ហាច និម្មិតយុវជន ទាំងអស់នេះឡើង ដើម្បីបង្ហាញពីប្រភេទផ្សេងៗនៃយុវជនដែលស្ថិតក្នុងវ័យកំពុងមានស្នេហា។

នាងវិធាវី ជាយុវនារីមួយរូបដែលមានរូបសម្បត្តិ ចរិយាសម្បត្តិ វិជ្ជាសម្បត្តិ ជាកូនកត្តញ្ញូ

ហើយមានទឹកចិត្តកក្តីចំពោះស្នេហា។ ទឹកចិត្តកក្តីនេះស្តែងឡើងតាមរយៈមរណភាពរបស់នាង។ ប៉ុន្តែមរណភាពរបស់នាងកើតឡើងពីភាពមិនចុះសម្រុងក្នុងគំនិតដែលច្របូកច្របល់ មិនដាច់ស្រេចរវាងកក្តីភាពចំពោះស្នេហា និងភាពកតញ្ញូចំពោះម្តាយ។ ផ្អែកលើមូលហេតុនេះ គេអាចយល់បានថា នាងវិធាវី ជានារីដែលគ្មានឆន្ទៈដាច់ខាតចំពោះស្នេហា ដោយសារនាងមិនហ៊ានសូម្បីតែធ្វើការតវ៉ាមតិ ឬ ផ្តល់យោបល់បង្ហាញហេតុផលចំពោះការសម្រេចរបស់ម្តាយនាង។ នាងមិនអាចបែងចែកទម្ងន់រវាងស្នេហា និងភាពកតញ្ញូឱ្យដាច់ស្រឡះពីគ្នាបាន។ ប្តីត្បិតតែនាងមានចរិតអសកម្មខ្លះចំពោះស្នេហាក៏ពិតមែន ក៏ប៉ុន្តែចរិតអសកម្មនេះជាគុណសម្បត្តិរបស់នាងក្នុងនាមជាស្ត្រីខ្មែរមួយរូបទៅវិញ។

ចំពោះយុវជន ប៊ុនធឿន ស្នេហារបស់គេគឺស្ថិតក្នុងចន្លោះគំនាបរវាងបញ្ហាទ្រព្យសម្បត្តិ និងការសិក្សា។ ប៊ុនធឿន ជាយុវសិស្សកំពុងស្ថិតក្នុងឆ្នាំប្រឡងឌីប្លូម ដែលត្រូវខិតខំយកចិត្តទុកដាក់រៀនសូត្រឱ្យខ្លាំងពូកែដើម្បីប្រឡងជាប់សញ្ញាបត្រ។ នៅពេលប្រឈមមុខជាមួយវិបត្តិសេដ្ឋកិច្ច ផ្ទួនគ្នានឹងវិបត្តិស្នេហា ប៊ុនធឿន ត្រូវធ្វើការសម្រេចចិត្តមួយដើម្បីដោះស្រាយបញ្ហាចំពោះមុខ។ ចំពោះវិបត្តិស្នេហា គេឃើញថា ប៊ុនធឿន ហាក់ធ្វើកិរិយាបែបហឺៗ មិនសូវអើពើនឹងវិវរល់ ហើយបែរជាសសេរសំបុត្រមួយសន្ទឹកឱ្យនាងវិធាវីឱ្យនាងប្តូរចិត្តពីរូបគេទៅស្រឡាញ់ណៃស៊ិតវិញ។ ម្យ៉ាងវិញទៀត ក្រោយពេលដឹងថានាងវិធាវីជិតដល់ថ្ងៃចូលរោងការ ប៊ុនធឿន មិនព្រមធ្វើសកម្មភាពជំទាស់ណាមួយដើម្បីអូសទាញទឹកចិត្តយាយនួនជាម្តាយនាងវិធាវី ឱ្យគាត់ផ្លាស់ចិត្តជាថ្មីវិញ គេបែរជាទៅដើរព្រៃរនាមរកត្រី រកឃ្មុំធ្វើព្រងើយដើម្បីកាត់ចិត្ត កាត់ថ្លើមពីស្នេហា។ កិរិយារបស់ ប៊ុនធឿន នេះ ធ្វើឱ្យមជ្ឈដ្ឋានខ្លះយល់ និងអាចចោទប្រកាន់ថា ប៊ុនធឿន គ្មានចិត្តស្រឡាញ់ស្មោះត្រង់ពិតប្រាកដចំពោះនាងវិធាវីទេ។ ការដែលគេស្រឡាញ់នាងវិធាវី នោះគឺគ្រាន់តែធ្វើទៅតាមសភាពធម្មតារបស់មនុស្សដែលជួបគ្នាក៏ស្រឡាញ់គ្នាទៅពេលជួបប្រទះឧបសគ្គក៏ពារែក ហើយលែងរវីរវល់ទៅ។

## អំពីទឹកចិត្តស្នេហារបស់នាងវិធាវីចំពោះ ប៊ុន ធឿន

អ្នកនិពន្ធ នូ ហាច និម្មិតនាងវិធាវី ឡើងជានារីខ្មែរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលគេតែងហៅថាជាស្ត្រីគ្រប់លក្ខណ៍។ នាងមានទាំងរូបសម្បត្តិ ទ្រព្យសម្បត្តិ វិជ្ជាសម្បត្តិ ចរិយាសម្បត្តិ កតញ្ញូ ស្តាប់បង្គាប់អ្នកមានគុណមានកក្តីភាពចំពោះស្នេហា។ លក្ខណៈសម្បត្តិរបស់នាង គួរតែជាប្រគពផ្តល់សុកមង្គលមិនចេះរីងស្ងួតដល់នាងតែផ្ទុយទៅ

វិញវាបែរជាប្រកពនាំទុក្ខយ៉ាងធ្ងន់ដល់នាងទៅវិញ។ គុណសម្បត្តិរបស់នាងកើតឡើងក្នុងសម័យអន្តរ កាលការវិវឌ្ឍន៍ពី លោកទស្សនៈបុរាណដែលមាតាបិតា អាណាព្យាបាលទាំងឡាយប្រកាន់ខ្ជាប់ទស្សនៈនំមិនធំដាងនាឡិ ក្នុងការរៀបចំចាត់ចែងគូស្រករកូនចៅ ទៅកាន់លោកទស្សនៈទំនើបដែលផ្តល់សេរីភាពដល់កូនចៅមានសិទ្ធិរើសយកគូស្រករ ដែលខ្លួនពេញចិត្ត មានសិទ្ធិបដិសេធអ្នក ដែលខ្លួនមិនពេញចិត្តដែលយល់ថាមិនអាចរួមរស់កសាងគ្រួសារមួយប្រកបដោយសុភមង្គលរួមគ្នាបាន។

## ២-២ សេចក្តីស្នេហារបស់ឪពុកម្តាយចំពោះបុត្រធីតា

ក្រៅពីរឿងរ៉ាវស្នេហារបស់យុវជន រឿងផ្កាស្រពោនបានបង្ហាញពីទឹកចិត្តស្នេហារបស់មាតាបិតា អាណាព្យាបាលខ្មែរ ចំពោះកូនចៅទៀតផង។ ក្នុងរឿងនេះ បានបង្ហាញពីសន្តានទឹកចិត្ត ការណែនាំទូន្មានប្រៀនប្រដៅ សេចក្តីសន្តោសប្រណីតាមរបៀបផ្សេងៗពីគ្នារបស់អ្នកជាឪពុកម្តាយ ដែលមានកម្រិតជីវភាពរស់នៅផ្សេងគ្នា មានការអប់រំពីមជ្ឈដ្ឋានដទៃពីគ្នា។

យាយនួនជាស្ត្រីមេម៉ាយចំណាស់ មានទ្រព្យសម្បត្តិស្តុកស្តម្ភ មានការយកចិត្តទុកដាក់ហួងហែងកូនស្រីតែមួយរបស់គាត់ជាខ្លាំង។ ចិកប៊ុនថន ជាឪពុករបស់ ប៊ុនធឿន គាត់ជាអ្នកជំនួញម្នាក់ដែលឱ្យតម្លៃលើចំណេះវិជ្ជា បានផ្តល់ឱកាសដល់កូនប្រុសគាត់បានរៀនសូត្រជ្រៅជ្រះ ទោះបីបើការសិក្សា នោះត្រូវចំណាយសោហ៊ុយច្រើនក៏ដោយ។ តាមរយៈចិកប៊ុនថន នេះគេអាចមើលឃើញពីជ្រុងមួយនៃសង្គមខ្មែរសម័យមុនដែលផ្តល់ឱកាសដល់កូនប្រុសច្រើនជាងកូនស្រីក្នុងការទទួលការសិក្សាពីមជ្ឈដ្ឋានសាលារៀន។

រីឯចឹកណៃស៊ាន និងនាងជូ ឪពុកម្តាយនាយណៃស៊ិតវិញ ជាចៅកែជំមួយនៅក្រុងបាត់ដំបង។ ដោយសារតែការជាប់រវល់ស្វែងរកទ្រព្យសម្បត្តិ អ្នកទាំងពីរពុំមានឱកាសគ្រប់គ្រាន់សម្រាប់ផ្តល់ការស្រឡាញ់ដល់កូនប្រុសសំណព្វម្នាក់នេះទេ។ ដើម្បីបំពេញសេចក្តីខ្វះខាតនេះពួកគាត់បានផ្តល់ការទំយើហួសហេតុបណ្តោយតាមអំពើចិត្តរហូតដល់កូនប្រុសក្លាយជាមនុស្សដើរប្រព្រឹត្តអំពើផ្តេសផ្តាស ក្អើតកើន អមនុស្សធម៌។ ពេលឃើញកូនប្រុសជ្រុសខ្លួនក្នុងផ្លូវខុស ហួសសមត្ថភាពកែប្រែ គាត់ក៏តាំងរកកូនស្រីអ្នកស្រុកដែលមិនដឹងពីប្រវត្តិកូនគាត់ឱ្យមកទទួលរងគ្រោះថ្នាក់ជំនួសគាត់ម្តង ហើយនារីអភ័ព្វនោះគឺនាងវិធាវី កូនយាយនួនតែម្តង។

ជារួមមក ឆ្លងតាមរយៈរឿងផ្កាស្រពោន គេអាចមើលឃើញថាទាំងស្ត្រីមេម៉ាយសល់ទ្រព្យ ឪពុកម្តាយអ្នកជំនួញខាតមធ្យម និងឪពុកម្តាយជាចៅកែមានការស្រឡាញ់

កូនចៅតាមរូបភាពផ្សេងៗពីគ្នា។ ស្ត្រីមេម៉ាយច្រើនតែស្រឡាញ់កូន ឃុំគ្រង កូនហួសហេតុដោយបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាងរបស់កូន ចូលចិត្តប្រើអំណាចផ្ដាច់ការចំពោះកូនចៅមើលឃើញ និងឱ្យតម្លៃលើទ្រព្យសម្បត្តិមាក់ងាយចំណេះវិជ្ជា ដូច យ៉ាង យាយនួនម្ដាយនាងវិធារី។ ឪពុក ម្ដាយដែលធ្លាប់បានទទួលការអប់រំ ច្រើនតែមានអធ្យាស្រ័យដល់កូនចៅ ផ្ដល់ឱកាស ដល់កូនចៅ ដើម្បីស្វែងរកកសាងអនាគតផ្ទាល់ខ្លួនតាមរយៈឪពុកប៊ុនធឿន ដែលផ្ដល់លទ្ធភាពគ្រប់បែបយ៉ាងដល់ ប៊ុនធឿន ក្នុង ការសិក្សាស្វែងរកវិជ្ជាដាក់ខ្លួន។ រីឯឪពុក ម្ដាយ ជាអ្នកជំនួញធំដុំ ច្រើនតែភ្លេចខ្លួនមិនបានផ្ដល់ភាពកក់ក្ដៅដល់កូនចៅដោយ មូលហេតុជាប់រវល់ខ្លាំងក្នុងមុខជំនួញ ឬដោយសារអាង ថា កូនគាត់មានប្រាក់ចាយវាយគ្រប់គ្រាន់ ហើយ មិនចាំបាច់ខ្វល់ខ្វាយ ពេកដូចជាឪពុកម្ដាយនាយណៃស៊ិតនេះឯង។

### ៣- ចរិយាសាស្ត្រសង្គមខ្មែរ និង ផលវិបាក

ចរិយាសាស្ត្រ មានថ្នាក់ពាក្យជានាម មានប្រភពពីភាសាបាលី សំស្ក្រឹត មានន័យថា ជាគម្ពីរឬក្បួនខ្នាតដែលចែងអំពីចរិយាឬចរិតមនុស្ស។ សង្គមខ្មែរតាំងពីបុរាណមកបានបង្កើតក្បួនខ្នាតជាច្រើនធ្វើជាក្រិត ជាម៉ែត្រសម្រាប់វាស់តម្លៃទឹកចិត្តអាកប្បកិរិយាមនុស្ស សម្គាល់ថា អ្នកនេះជាមនុស្សល្អ អ្នកនោះជាមនុស្សអាក្រក់។ ក្បួនខ្នាតប្រភេទនេះច្រើនតែបង្កើតឡើងដោយក្រុមមនុស្សថ្នាក់ខ្ពស់ ឬក្រុមមនុស្សមានវ័យច្រើនក្នុងសង្គមដើម្បីធ្វើជាតង្កៀបអប់រំ ហាត់ពត់សន្ដានចិត្តមនុស្សឱ្យដើតាមគន្លងផ្លូវ (ល្អ) ដែលគេបាន កំណត់ជាគោលប្រតិបត្តិក្នុងគោលដៅបម្រើផលប្រយោជន៍ក្រុមខ្លួន។ ផ្នែកខ្លះនៃក្បួនច្បាប់ នេះមិនបានបម្រើដល់ផលប្រយោជន៍របស់មនុស្សទូទៅឡើយ ថ្វីត្បិតតែមើលពីក្រៅទៅវាមានទម្រង់ រូបរាងល្អក៏ដោយតែវាបង្កប់នូវអត្ថន័យបំបាក់ ស្មារតីមនុស្សមិនឱ្យមានគំនិតម្ចាស់ការលើខ្លួនឯងឱ្យពឹងផ្អែកតែទៅលើអ្នកដទៃជាមេ ដឹកនាំលើអ្នកកាន់អំណាច ដូចជា ពាក្យ ពងមាន់កុំដល់នឹងថ្ម នំមិនធំជាងនាឡិ ងើយស្កកឱនដាក់គ្រាប់ជាដើម។ ក្បួនខ្នាតមួយ ចំនួនក៏ក្លាយខ្លួនជាពាក្យជូនប្រជាប្រិយ ជាសុភាសិតទៅតាមការនិយមរបស់មនុស្សតាមសម័យកាលហើយអាចរក្សាអត្ថិភាព ដល់សព្វថ្ងៃឯមួយចំនួនទៀតក៏បាត់បង់ទៅដោយគ្មានប្រជាប្រិយ។

### ការប្រកាន់ទស្សនៈនំមិនធំជាងនាឡិ ក្នុងការចាត់ចែងគូស្រករកូនចៅ

ក្បួនចរិយាសាស្ត្រដែលជិតជាប់ក្នុងផ្នត់គំនិតសង្គមខ្មែរនេះ ជាកត្តាលីករជំរុញការរាំងស្ទះស្ត្រីខ្មែរមិនឱ្យមានការរីកចម្រើន ទាំងលើផ្នែកចំណេះដឹង ស្មារតី ទាំងក្នុងវិស័យការងារក្នុងសង្គមរហូតមានពាក្យជំណៀលថា ស្ត្រីបង្វិលចង្រ្កានមិនជុំ។ ច្បាប់

ចរិយាសាស្ត្រនេះ មានអត្ថិភាពនិងជះឥទ្ធិពលខ្លាំងលើសង្គមខ្មែរ តាំងពីសម័យបុរាណ នោះរហូតមកដល់សម័យកាលនៃរឿងផ្កាស្រពោននេះ។

តាមរយៈតួអង្គយាយនួន ជាម្ដាយ នាងវិធាវី បង្ហាញឱ្យយើងឃើញពីសង្គមចាស់ទុំផ្ដាច់ការក្នុងការទុកដាក់កូនចៅ។ ទង្វើរបស់យាយនួនក្នុងការចាត់ចែងផ្ដាច់នាងវិធាវី ពីប៊ុនធឿន ឱ្យទៅនាយណៃស៊ិតបង្ហាញពីការប្រើអំណាចផ្ដាច់ការតាមទស្សនៈ"នំមិនធំជាងនាឡិ" ក្នុងនាមជាម្ដាយ ទៅលើកូន ចៅ "ឱម៉ែអើយ! ម៉េចឃើញតែទ្រព្យសម្បត្តិ ម៉េចមិនមើលលក្ខណៈមនុស្ស ម៉េចក៏មិនស្នើចិត្តកូនផង? បើបានទុក្ខឬសុខ យ៉ាងណា ក៏នៅលើរូបកូនទាំងអស់ទេតើ" ។

ជាទូទៅស្ត្រីមេម៉ាយខ្មែរក្នុងវ័យចំណាស់ដូចនោះ ច្រើនតែជាអ្នកកាន់ឧបោសថ តែថាធម៌អាថ៌នោះពុំ បានធ្វើឱ្យគាត់ បានស្ងប់ឡើយ នៅពេលដែលគាត់ពុំបាន រៀបចំទុកដាក់កូនចៅបានរួចរាល់។ សេចក្ដី ស្នេហាជាពិសេសលើបុត្រី តែងធ្វើឱ្យគាត់ មិនអាចចូលស៊ប់បានក្នុងជំរៅធម៌អាថ៌។ តែ អ្វីដែលអាក្រក់ជាងនោះទៅទៀត គឺទស្សនៈផ្ដាច់ការ និងទ្រព្យសម្បត្តិនិយមរបស់គាត់ ក្នុងការទុកដាក់កូនចៅ។ សេចក្ដីស្នេហា របស់គាត់ចំពោះ កូន គឺសេចក្ដីប្រាថ្នាចង់ឱ្យ កូនបានសុខលើគំនរទ្រព្យសម្បត្តិគឺទស្សនៈសុកមង្គលស្ថិតលើទ្រព្យសម្បត្តិ រួចដោយសេចក្ដីភ័យខ្លាចមិនបានសម្រេចបំណងនោះ គាត់ក៏តាំងខ្លួនជាអ្នកត្រួសត្រាយ ឬត្រួតត្រារៀបចំអនាគតឱ្យកូនក្នុងនាមជាអ្នកមានគុណ មានសិទ្ធិជាចាស់ ចេះជាង ជានាឡិ ជាពុម្ពដែលកូនតូចធំត្រូវតែតាម ។

យាយនួន ជានិមិត្តរូបតំណាងស្ត្រីជាម្ដាយក្នុងសម័យនោះដែលនៅតែប្រកាន់ទស្សនៈ "នំមិនធំជាងនាឡិ" ក្នុងការរៀបចំគូស្រករ កូនចៅឱ្យប្រព្រឹត្តទៅតាមគន្លងឱវាទរបស់គាត់ជាម្ដាយ ជាអាណាព្យាបាលមានសិទ្ធិសម្រេច គ្រប់យ៉ាងក្នុងការចាត់ចែងវាសនាអនាគតកូនចៅ ដោយពុំចាំបាច់សួរយោបល់ពីសាមីខ្លួនឡើយ។ កិរិយាបែប នេះថែមទាំងអាចនាំសេចក្ដីគ្រោះថ្នាក់មកឱ្យកូនចៅ នាំសេចក្ដីទុក្ខសោក ការស្ដាយក្រោយចំពោះទង្វើខុសឆ្គង ដែលកន្លងផុតរបស់ខ្លួនទៀតផង។ ការនិយមតែលើទ្រព្យសម្បត្តិមិនយល់ដល់ចិត្តកូនចៅក្នុងការរើសគូគ្រងតម្រូវឱ្យអ្នកធ្វើទទួលការបាត់បង់យ៉ាងធំដែលអ្នកជាមាតាបិតា អាណាព្យាបាល ទាំងឡាយមិនប្រាថ្នាជួប។ ការបំបិទសិទ្ធិសេរីភាពកូនចៅក្នុងការជ្រើសរើសគូស្រករជាប្រការមួយគួរជៀសវាង ព្រោះការធ្វើបែប នេះមិនបាននាំអ្វីជាផលល្អដល់អ្នកជាមា តាបិតាអាណាព្យាបាល ឬបុត្រធីតាឡើយ លទ្ធផលបានត្រឹមតែភាពសោកាដូចជាយាយនួនតែប៉ុណ្ណោះ។

ម្ដាយប្រភេទយាយទួន នេះ អ្នកនិពន្ធខ្មែរសម័យមុនបានរំលេចឱ្យសង្គមឃើញរួចមកហើយ តាមរយៈតួអង្គយាយម្ដាយនាងទាវ ដែលលទ្ធផលចុងក្រោយរបស់គំនិតទិដ្ឋិមានះរបស់គាត់ គឺមរណភាពរបស់កូនស្រី និងការសោកស្ដាយដែលហួសពេលកែប្រែ។

## *ការប្រកាន់ទស្សនៈស្រីគ្រប់លក្ខណ៍ក្នុងសង្គមខ្មែរ*

ពាក្យ លក្ខណ៍ ឬលក្សណ៍ មានថ្នាក់ពាក្យជានាម មានន័យថា លក្ខណៈ។ ស្ត្រីគ្រប់លក្ខណ៍ ស្ត្រីដែលបរិបូរណ៍ដោយលក្ខណៈល្អ។ នៅក្នុងច្បាប់ស្រីរបស់ព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គឌួងចែងអំពីមង្គលប្រាំបីប្រការដែលជាលក្ខណ៍របស់ស្ត្រី «នេះនឹងសម្ដែង បរិយាយចារចែង ដើមបទអដ្ឋ- ហិឋានេហិ សុចរិតាឥត្ថីលក្ខណាមង្គលច្នេះពិត។»ច្បាប់នេះ ព្រះរាជករអង្គឌួង ទ្រង់និពន្ធឡើងជិតមួយរយឆ្នាំ មុនរឿងផ្កាស្រពោន បង្ហាញពីលក្ខណៈប្រាំបីយ៉ាងរបស់ស្ត្រីត្រូវប្រតិបត្តិ គឺស្រីជាស្រីត្រង់ ស្រីគាប់ ស្រីប្រាជ្ញ ស្រីស្អាត ស្រីស្មោះ ស្រីស្លូត ស្រីស្មើ។

ជិតមួយរយឆ្នាំក្រោយមកអ្នកនិពន្ធ ហាច បង្ហាញឱ្យឃើញពីស្ថានភាពស្ត្រីខ្មែរដែលរស់ក្រោមឥទ្ធិពលនៃចរិយាសាស្ត្រសង្គមនេះតាមរយៈតួអង្គនាងវិធាវី ដែល ប្រកាន់ខ្ជាប់ចរិយាសាស្ត្រស្ត្រីខ្មែរក្នុងដំណាក់កាលមួយដែលសង្គមខ្មែរ កំពុងវិវឌ្ឍពីលោកទស្សនៈបុរាណទៅរកភាពទំនើបជឿនលឿនតាមបែបបស្ចិមប្រទេស។ ការប្រកាន់ខ្ជាប់តាមក្បួនចរិយាសាស្ត្រគ្រប់យ៉ាងនេះ ផ្ដល់ផលវិបាកយ៉ាងខ្លាំងដល់នាងវិធាវីធ្វើឱ្យនាងវិធាវីក្លាយជាមនុស្សដែលមានទំនាស់ជាច្រើនក្នុងខ្លួន។ ទំនាស់ក្នុងខ្លួននាងវិធាវី មានជាអាទិ៍ ៖

**ទំនាស់រវាងគំនិត និងសម្រស់**

**ទំនាស់រវាងចរិតសុភាពរាបសាស្រគត់ស្រគំ និងមជ្ឈដ្ឋានសង្គម**

**ទំនាស់រវាងភាពកតញ្ញូ និងភក្ដីភាព**

ក្នុងរឿងផ្កាស្រពោនរបស់លោក នូ ហាច លក្ខណៈសម្បត្តិល្អរបស់នាងវិធាវីបានត្រូវរងសម្ពាធតឹងរ៉ឹងបែបប្រពៃណីខាងលើនេះយ៉ាងឥតខ្ចោះ ហើយបានជាធ្វើឱ្យនាងសុខចិត្តខាំមាត់ សង្កត់ចិត្តគោរព ម្ដាយក៏ត្រូវតែធ្វើឱ្យបានរក្សាភក្ដីភាពស្នេហាក៏ត្រូវតែធ្វើឱ្យបាន។

រឿងផ្កាស្រពោនតាមរយៈនាងវិធាវីចង្អុលបញ្ជាំងឱ្យឃើញពីសង្គមបរិយាកាសមួយមិនផ្ដល់ឱកាសដល់ នារីដែលប្រកាន់ខ្ជាប់តាមចរិយាសាស្ត្រខ្មែរ មានឱកាសរស់នៅប្រកបដោយភាពសុខដុមរមនា សុខក្សេមក្សាន្តក្នុងសុភមង្គលសមទៅតាមកិរិយាប្រព្រឹត្តរបស់នាងឡើយ។ ជាការតបស្នងចំពោះភាពកតញ្ញូ គឺការបំបែកបំបាក់ពីគូស្នេហ៍ចំពោះភក្ដីភាពគឺការចាកចោល ការលះបង់ដោយគ្មានទឹកស្រណោះ ចំពោះភាពស្រគត់

ស្រគំ គឺការរុកគួនមិនឱ្យជួបមនុស្សល្អ តាម បំណងប្រាថ្នា ចំពោះរូបឆោមលោមពណ៌ ស្រស់ស្អាត គឺការនិន្ទាត្រេកត្រអាល នឹង លំអ ការចេះដឹងខុសត្រូវ គឺការបៀមទុក្ខលាក់ក្នុង ចិត្តរហូតថ្ងៃចុងក្រោយ។

ជារួមមក នារីដែលប្រកាន់ខ្ជាប់តាម ក្បួនចរិយាសាស្ត្រ ឬដែលហៅថាស្ត្រីគ្រប់ លក្ខណ៍ក្នុងសម័យកាលបែបនោះត្រូវ ទទួល លទ្ធផលចុងក្រោយដូចនាងវិធាវី នេះ ឯង។

## សន្និដ្ឋាន

ជារួមមកការ បង្ហាញពីជំនឿរបស់ មនុស្សខ្មែរនាសម័យចុងសម័យអាណាព្យា បាលបារាំង បានផ្តល់ជាប្រយោជន៍ចូលរួម ចំណែកក្នុងការកែលម្អភាពអសកម្មក្នុងជីវ ភាពសង្គម ដែលកំពុងជះឥទ្ធិពលមិនល្អប៉ះ ពាល់ដល់ ស្ថានភាពជីវភាពគ្រួសារនីមួយៗ ដែលកំពុងតែលង់លក់ក្នុងជំនឿទាំងនោះ។ ឆ្លងកាត់តាមការបង្ហាញទាំងនេះរបស់អ្នក និពន្ធ មនុស្សដែលកំពុងរស់ក្នុងសម័យបច្ចុ-ប្បន្នបានទទួលការសិក្សាអប់រំតាមបែប ទំនើបមានលក្ខណៈ វិទ្យាសាស្ត្រគួរធ្វើការ គិតគូរពិចារណាឡើងវិញលើបញ្ហាជំនឿ អសកម្មទាំងនេះ ដើម្បីជៀសវាងលទ្ធផល មិនល្អដែលបានធ្លាក់លើរូបនាងវិធាវី ក៏ដូច ជាអ្នកដទៃទៀតតាំងពីពេលមុនដរាបរៀង មក។

មរណភាពរបស់នាងវិធាវី ដែលរង គ្រោះដោយគំនាបសង្កត់ពីមជ្ឈដ្ឋានជុំវិញ ខ្លួន ក្នុងរឿងរៀបចំវាសនាអនាគតរបស់នាង ពិសេសឥទ្ធិពលរបស់ម្តាយនាងដែលតាំងខ្លួនជាម្តាយ ជាអ្នកមានគុណចេះរៀបចំចាត់ ចែងវាសនាឱ្យនាង ដោយបំបិទសិទ្ធិមិនឱ្យ នាងអាចសម្រេចចិត្តក្នុងការយល់ព្រម ឬមិន យល់ព្រមទទួលយកបុរសណាម្នាក់មកធ្វើ ជាគូអនាគត។ មរណភាពនេះស្តែងឱ្យឃើញ ពីសភាពមិនចុះសម្រុងគ្នា រវាងអារម្មណ៍ ផ្សេងៗនៅក្នុងខ្លួននាងវិធាវី ហើយគ្មានវិធី ដោះស្រាយ។ មរណភាពនេះបង្កើតនូវភាព សោកសង្រេង មិនត្រឹមតែក្នុងដំណើររឿង ប៉ុណ្ណោះទេ តែក៏ដល់មជ្ឈដ្ឋានអ្នកអានផង ដែរ។ នារីខ្មែរមួយចំនួនដែលជួបប្រទះបញ្ហា ស្រដៀងគ្នានេះ ក៏បានជ្រើសរើសយក វិធីធ្វើ បាបខ្លួនឯងរហូតដល់ថ្នាក់ធ្វើអត្តឃាតដើម្បី គេចឱ្យផុតពីបញ្ហាចំពោះមុខ។ តែមរណ ភាពនេះក៏ជាប្រទីបមួយជួយបំភ្លឺដល់មាតាបិតា អាណាព្យាបាលមួយចំនួនដែលប្រកាន់ ទិដ្ឋិមានះរឹងរូសក្នុងការរៀបចំគូស្រករកូន ចៅឱ្យភ្ញាក់គំនិតឡើង ធ្វើការពិចារណាលើ បញ្ហានេះសារជាថ្មីឡើងវិញ។

ការសិក្សាពីស្នាដៃនេះ បានចូលរួម ចំណែកជាគតិមួយក្នុងការជួយផ្តល់យោបល់ ក្នុងការគិតគូរចាត់ចែង រៀបចំវាសនាអនាគតបុត្រធីតារបស់មាតាបិតា អាណាព្យា បាលទាំងឡាយមុននឹងធ្វើការសម្រេចចិត្តអ្វី

មួយត្រូវចេះពិភាក្សា ប្តូរយោបល់ជាមួយសមាជិកគ្រួសារ ពិសេសសាមីខ្លួនផ្ទាល់។ ក្នុងនាមជាអ្នកទទួលខុសត្រូវផ្ទាល់លើវាសនាអនាគតរបស់ខ្លួន សាមីជនមានសិទ្ធិគ្រប់គ្រាន់ និងពេញលេញក្នុងការធ្វើការសម្រេចចិត្តយល់ព្រមទទួលឬបដិសេធទាំងស្រុងក្នុងដំណើរទៅកាន់អាពាហ៍ពិពាហ៍។ គេមិនត្រូវប្រកាន់ឥរិយាបថអៀនប្រៀនជ្រុលហួសហេតុមិនព្រមបញ្ចេញទស្សនៈ យោបល់ ការយល់ឃើញសេចក្តីត្រូវការរបស់ខ្លួនឱ្យចាស់ទុំជាឪពុកម្តាយ អាណាព្យាបាលដឹងនោះឡើយ។ ប្រការនេះជាកត្តាសំខាន់មួយកំណត់សេចក្តីសុខ សុភមង្គលរបស់ខ្លួន។ ក្រៅពីនេះ ស្នាដៃនេះអាចរួមចំណែកផ្តល់ជាវិធីសាស្រ្តតែងនិពន្ធស្នាដៃប្រលោមលោក ដល់អ្នកនិពន្ធជំនាន់ក្រោយឱ្យមានភាពសម្បូរបែបក្នុងការនិម្មិតស្នាដៃរបស់ខ្លួន។

# ឯកសារពិគ្រោះ

## ស្នាដៃបោះពុម្ពផ្សាយ និងនិក្ខេបបទ


*ល.រ អ្នកនិពន្ធ ឈ្មោះសៀវភៅ ពេងពុម្ព ឆ្នាំ*

*១. ក្រុមអ្នកចងក្រង ៖ សំរាវជ្រាវជីវប្រវត្តិអ្នកនិពន្ធខ្មែរ ? ១៩៨៦*

*៣. គីន ណាន ៖ ក្រមុំចូលម្លប់និងពិធីរើសគូស្រករ ?១៩៨២*

*៤. គឹមសែត ៖ ប្រវត្តិអក្សរសាស្ត្រ ? ?*

*៥. ឃីង ហុកឌី ៖ ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ  ដែ◌ិតៀនស ល់គារមាតតាន១៩៩៧*

*៦. ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី១៩, បណ្ណាគារអង្គរ,២០០៧*

*៧. ឃីង ហុក ឌី, មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី២០, បណ្ណាគារអង្គរ,២០០៧*

*៨. ឃីម សាគុណ ៖ សិទ្ធិមនុស្សតាមរយៈអក្សរសិល្ប៍ខ្មែរ ?១៩៨២*

*៩. ឃឹម សំឌិ ៖ប្រវត្តិអក្សរសាស្ត្រខ្មែរ ?១៩៦១*

*១០. ឃួន សុខម្ភៈ ប្រវត្តិអ្នកនិពន្ធខ្មែរ ? ?*

*១១. ង៉ុយ ៖ ច្បាប់ក្រមង៉ុយ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧២,២៥១៦*

*១២. ជួន ណាត ៖ វចនានុក្រមខ្មែរភាគ១-២ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៧*

*១៣. (ព្រះអង្គ) ឌួង ៖ ច្បាប់ស្រី ពុទ្ធសាសនបណ្ឌិត្យ ១៩៦២,២៥០៥*

*១៥. ត្រឹង ង៉ា,ប្រវត្តិសាស្ត្រខ្មែរ, ភាគ១ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤*

*១៦. ត្រឹង ង៉ា ៖ ប្រវត្តិសាស្ត្រខ្មែរ ភាគ២ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ, ១៩៧៤,២៥១៨*

*១៩. ធ សោ ៖ លក្ខណៈទីពីកក្នុងអក្សរសិល្ប៍ និងសិល្បៈខ្មែរ មេរៀនសរសេរដៃ ២០០២*

*២០. ហ៊ុន គឹមសៀ ៖ មូលដ្ឋានដើម្បីយល់អក្សរសាស្ត្រ ? ?*

*២១. ពៅ សាមី ៖ លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*

*២២. ពៅ សាមី ៖លក្ខណៈទំនេរនៃអក្សរសិល្ប៍និងសិល្បៈ*

*២៣. ពៅ សាមី ៖ តថនិយមក្នុងអក្សរសិល្ប៍ខ្មែរសតវត្សទី២០*

*២៤. ពៅ សាមី ៖ មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ ប្រើប្រាស់ផ្ទៃក្នុងសាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៧*

*២៥. រស់ ចន្ត្រាបុត្រ ៖ អំពីស្នេហា សារពត៌មានមហាជន ១៩៧១*

*២៦. លាង ហ័បអាន ៖ សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ភាគ១ ?១៩៦៧*

*២៧. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ១ ?១៩៦៦*

*២៨. លាង ហ័បអាន ៖ សិក្សាអត្ថបទ ភាគ២ ?១៩៦៦*

២៩. លាង ហាប់អាន ៖ ប្រជុំវិញ្ញាសាតែងសេចក្តីគំរូសំរាប់ថ្នាក់ទី៥.៤.៣ ទំនើប ?
៣០. លាង ហាប់អាន ៖ សិក្សាសង្ខេបរឿងកុលាបប៉ៃលិន ??
៣១. លី ធាមតេង ៖ អ្នកនិពន្ធខ្មែរដែលមានឈ្មោះល្បី បណ្ណាល័យអប្សរា សមាគមអ្នកនិពន្ធខ្មែរ ១៩៧២
៣២.លី សុមុនី, កំណាព្យខ្មែរ, ក្រសួងអប់រំយុវជន និង កីឡា, ២០០២
៣៣. វ៉ាន់ឌី កាអុន ៖ វិភាគទាននៃក្នុងការសិក្សាអក្សរសិល្ប៍ខ្មែរ ??
៣៤. វ៉ាន់ឌី កាអុន ៖ក្បួនចិត្តសាស្ត្រ ?១៩៧៣
៣៥. វ៉ាន់ឌី កាអុន ៖វិភាគទានក្នុងការសិក្សាប្រាកដនិយមនិងអណ្តែតអណ្តូងនិយម ?១៩៧៣
៣៦. វ៉ាន់ឌី កាអុន ៖សង្គមសាស្ត្រ ?១៩៧៣
៣៧. ស៊ន សំណាង (E.d.) ៖ ខេមរវិទ្យា ចំណេះដឹងអំពីអតីតកាល និង ការរួមវិភាគទានក្នុងការស្តារ និង ស្ថាបនាប្រទេសកម្ពុជាឡើងវិញ ភាគ២ រោងពុម្ពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៩
៣៨. សម្ព័ន្ធអ្នកសារពត៌មាន រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩៣ ??
៣៩. សមាគមអ្នកនិពន្ធខ្មែរ ៖ ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធសមាជិកនៃសមាគម ១៩៧០
៤០. សមាគមអ្នកនិពន្ធបទភ្លេង នឹងទំនុកច្រៀង ៖លក្ខន្តិកៈ ? ១៩៦២
៤១. សោម សុមុនី ៖ អក្សរសិល្ប៍ពាក្យរាយខ្មែរ និក្ខេបបទថ្នាក់បណ្ឌិត, សំណេរដៃ, ?
៤២. សែម សូរ ៖ វិជ្ជានិពន្ធន៍ខ្មែរចម្រុះ បណ្ណាគារភ្នំពេញ, ១៩៦៣
៤៣. ស៊ុំ ឈុំប៊ុន ៖ តួអង្គក្នុងអក្សរសិល្ប៍ទំនើបខ្មែរ ពីទសវត្សទី៤០ ដល់ទី៦០ និក្ខេបបទថ្នាក់បណ្ឌិត, ?
៤៤. ស៊ុំ ឈុំប៊ុន ៖ អក្សរសិល្ប៍ខ្មែរ សម័យទំនើប មេរៀនសរសេរដៃ, ២០០២
៤៥. ស៊ុំ ឈុំប៊ុន ៖ គោលសង្ខេបនៃការសិក្សាប្រវត្តិអក្សរសិល្ប៍ខ្មែរ មេរៀនសរសេរដៃ, ២០០២
៤៦. អ៊ុក ចួន ៖ ចំណោទ និងសំពាយបញ្ហាក្នុងអក្សរសិល្ប៍ខ្មែរ សកព, ១៩៨៨
៤៧. អ៊ុក សាម៉ន ៖ សិក្សាកថារឿងទុំ-ទាវ បណ្ណាគារភ្នំពេញ, ១៩៦៦,២៥០៨
៥៤. Klairung Amratisha: The Cambodian Novel,A study of its Emergence and Development ?1998
៧៩. អក្សរសាស្ត្រ-មនុស្សសាស្ត្រ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ លេខ១៩ ត្រីមាសទី៣ ឆ្នាំ២០០២

*៨០. ឯកសារ ៖ សន្និសីទជាតិស្ដីពី ការបណ្ដុះបណ្ដាលធនធានមនុស្សនៅកម្ពុជា ៖ តុល្យការ និង ចក្ខុវិស័យ  រាជបណ្ឌិតសភាកម្ពុជា ២០០០*

**អត្ថបទរឿង**

*ល.រ ឈ្មោះអ្នកនិពន្ធ ឈ្មោះអត្ថបទ ផ្សាយពី រោងពុម្ព កាលបរិច្ឆេទ*

*៨២. គឹម ហាក់ ទឹកទន្លេសាប ? ១៩៣៦*

*៨៣. ឃីង ហុក ឌី, ទាវឯក, បណ្ណាគារអង្គរ,២០០៥។*

*៨៤. ញ៉ុក ថែម កុលាបប៉ៃលិន គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ក្រ.អ.យ.ក. ២០០១,២៥៤៥*

*៨៥. នូ ហាច ផ្កាស្រពោន ក្រសួងសិក្សាធិការជាតិ រោងពុម្ពរស្មី១៩៦០.២៥០៣*

*៩០. នូ ហាច មាលាដួងចិត្ត មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌ខ្មែរ១៩៨១*

*៩២. នូ ហាច មាលាដួងចិត្ត ឯកសារប្រើប្រាស់ផ្ទៃក្នុង សាលាគរុវិជ្ជាជាន់ខ្ពស់ ១៩៨៩*

*៩៣. រីម គីន សូផាត  បណ្ណាគារ សេង ង៉ួនហួត ភ្នំពេញ ១៩៦៥,២៥០៧*

*៩៤. រីម គីន នាងសមាភារី បណ្ណាល័យជាតិ ភ្នំពេញ ២០១៣*

*៩៥. សោម ទុំទាវ  ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧១,២៥១៤*

*៩៦. ស្ហេក ស្ពៀ រ៉ូមេអូ និង ស៊ុលីយែត ប្រែសម្រួលដោយ ហង្ស ធុនហាក់ រោងពុម្ពសារពត៌មាននគរធំ ១៩៧១*

*៩៧. ចៅកក្ដីឌក ហង្សយន្ត ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៩៨,២៥៤២*

*៩៨. ប៉ូល វិរហ្សីនី  ប្រែសម្រួលដោយ ហង្ស ធុនហាក់ ??*

# បច្ចុប្បន្នភាពនៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីចិននៅកម្ពុជា

ដោយៈ បណ្ឌិត **ជា វណ្ណី**
ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និងយេនឌ័រ
នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា
Email : Vannykhim2003@yahoo.com

ទំនាក់ទំនងរវាងកម្ពុជា-ចិន បានកើតឡើងរាប់ពាន់ឆ្នាំមកហើយ ហើយលំហូរវប្បធម៌នៃប្រទេសចិនចូលមកក្នុងសង្គមខ្មែរ ក៏មានតាំងពីយូរលង់មកហើយដែរ។ យ៉ាងណាមិញ ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិចិន ដែលជាគ្រឹះនៃវប្បធម៌ចិនមួយដែរនោះ ក៏ត្រូវបានប្រជាជនចិនដែលបានមករស់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាអ្នកជាប់សែស្រឡាយចិននៅកម្ពុជា បាននិងកំពុងប្រតិបត្តិពិធីបុណ្យនេះជារៀងរាល់ឆ្នាំ ហើយពីមួយឆ្នាំទៅមួយឆ្នាំ សន្ទុះនៃការអបអរបុណ្យចូលឆ្នាំថ្មីនៃវប្បធម៌ចិននៅកម្ពុជា ក៏បានវិវឌ្ឍស្របទៅនឹងចរន្តសន្ទុះសេដ្ឋកិច្ចផងដែរ។

នារដូវកាលបុណ្យចូលឆ្នាំថ្មីប្រពៃណីចិនចូលមកដល់ ភ្លេងឡុកមុងសាយបានឮខ្ទរខ្ទារគ្រប់ទិសទី ចង្កៀងគោមក្រហមត្រូវបានដាក់តាំងព្រោងព្រាតនៅតំបន់ផ្សារ និងគេហដ្ឋានមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសរាជធានីភ្នំពេញ។ ចំណែកហាងលក់ទំនិញមួយចំនួនទៀតសោត ក៏មានដាក់តាំងផ្កាពណ៌លឿង និងបិទក្រដាសក្រហមនៅលើទ្វារ និងជញ្ជាំង ដែលនេះបញ្ជាក់ប្រាប់ជាសញ្ញាថា រដូវកាលបុណ្យចូលឆ្នាំប្រពៃណីចិនចាប់ផ្តើមហើយ ហើយនៅកម្ពុជាពិធីបុណ្យចូលឆ្នាំចិនត្រូវបានប្រារព្ធធ្វើយ៉ាងទូលំទូលាយ។ បើទោះបីជាពិធីបុណ្យចូលឆ្នាំចិនមិនស្ថិតនៅក្នុងថ្ងៃសម្រាកដែល

កំណត់នៅក្នុងច្បាប់ក៏ដោយ ប៉ុន្តែគេសង្កេតឃើញជាទូទៅថា ប្រជាពលរដ្ឋខ្មែរភាគច្រើន ទាំងអ្នករកស៊ី និងមន្ត្រីរាជការបានឈប់សម្រាកពីការងារនៅក្នុងឱកាសបុណ្យចូលឆ្នាំចិននេះផងដែរ។

**តើប្រទេសណាខ្លះដែលទទួលឥទ្ធិពលនៃការប្រារព្ធពិធីបុណ្យចូលឆ្នាំចិន?**

ពិធីចូលឆ្នាំថ្មីប្រពៃណីចិន ត្រូវបានប្រារព្ធធ្វើឡើងនៅតាមតំបន់នានា ដែលមានប្រជាជនចិនរស់នៅច្រើន។ គេចាត់ទុកពិធីបុណ្យនេះជាពិធីបុណ្យដ៏សំខាន់មួយសម្រាប់ជនជាតិចិន និងជនជាតិដទៃទៀតដែលឥទ្ធិពលវប្បធម៌ចិនបានជះសាយភាយទៅដល់ដូចជា ប្រទេសវៀតណាម កូរ៉េ និងម៉ុងហ្គោល ជាដើម។ ចំណែក ឯជនជាតិជប៉ុន នៅមុនឆ្នាំ១៨៧៣ ក៏ធ្លាប់បានប្រារព្ធពិធីបុណ្យចូលឆ្នាំចិននេះ ទៅតាមប្រពៃណីរបស់ខ្លួនដែរ ហើយក្រៅពីនៅទឹកដីចិនដីគោក ក៏មានដូចជា ហុងកុង ម៉ាកាវ តៃវ៉ាន់ ផងដែរ។ ប្រទេសផ្សេងទៀតដែលមានប្រជាជនចិន កូនចៅកាត់ចិន (សែស្រឡាយចិន) ដែលនិយមប្រារព្ធពិធីនេះដែរ តែមិនមែនជាបុណ្យប្រពៃណីជាតិនោះ មានដូចជា សិង្ហបុរី ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ កម្ពុជា គឺឱ្យតែប្រទេសនានាក្នុងពិភពលោកដែលមានប្រជាជនចិនរស់នៅ គឺគេតែងតែរៀបចំប្រារព្ធពិធីបុណ្យនេះ និងមានលក្ខណៈខុសៗគ្នាពីតំបន់មួយទៅតំបន់មួយផងដែរ។

**តើពិធីបុណ្យចូលឆ្នាំចិននេះ មានប្រវត្តិយ៉ាងដូចម្តេច និងមានការអនុវត្តយ៉ាងណាខ្លះនៅក្នុងសង្គមកម្ពុជា?**

ពិធីបុណ្យចូលឆ្នាំចិន ឬហៅម្យ៉ាងទៀតថា ពិធីបុណ្យនិទាឃរដូវ គឺជាពិធីបុណ្យប្រពៃណីជាតិរបស់ប្រទេសចិន ដែលតែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ និងមានរយៈពេល៣ថ្ងៃ។ បើតាមទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិចិន ពិធីបុណ្យនេះ ចាប់ផ្តើមនៅថ្ងៃទីមួយនៃខែទីមួយតាមចន្ទគតិ (ភាសាចិនថា៖ pinyin៖ zhēng yuè) ក្នុងប្រតិទិនចិន ហើយបញ្ចប់ទៅវិញនៅថ្ងៃទី១៥ ដែលគេហៅថ្ងៃនេះថា ពិធីបុណ្យបង្ហោះគោម។

ពិធីបុណ្យចូលឆ្នាំចិន ត្រូវបានចាត់ទុកជាថ្ងៃដ៏មានសារសំខាន់សម្រាប់ប្រជាជនចិន និងអ្នកជាប់ខ្សែស្រឡាយចិន ហើយវាក៏បានមានឥទ្ធិពលទៅលើប្រទេសជិតខាងផងដែរ ជាពិសេសចំណងវប្បធម៌ជាមួយប្រជា

ជនដែលជនជាតិចិនធ្វើអន្តរកម្មជាមួយ ដូចជា តៃវ៉ាន់ ជនជាតិកូរ៉េ ជនជាតិម៉ុងហ្គោល ជនជាតិប៊ូតង់ ជនជាតិវៀតណាម និងអតីតជនជាតិជប៉ុននាមុនឆ្នាំ១៨៧៣។

ពិធីបុណ្យចូលឆ្នាំចិន ក៏បានប្រារព្ធធ្វើផងដែរនៅក្នុងប្រទេសមួយចំនួនដូចជា សិង្ហបុរី ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ កម្ពុជា ក៏ដូចជាប្រទេសដទៃទៀតនៅលើពិភពលោក ដែលមានប្រជាជនចិនរស់នៅភាគច្រើន គឺ ប្រទេសស្ថិតនៅក្បែរសមុទ្រចិន។ ពិធីបុណ្យនេះ បានត្រូវផ្លាស់ប្តូរកម្រិត ហើយក្លាយទៅជាផ្នែកមួយនៃវប្បធម៌ប្រពៃណីរបស់ប្រទេសទាំងនោះ។ យ៉ាងណាមិញនៅក្នុងប្រទេសកម្ពុជា ទោះបីជាពិធីបុណ្យចូលឆ្នាំចិនមិនមែនជាថ្ងៃបុណ្យដែលត្រូវបានអនុញ្ញាតិឱ្យឈប់សម្រាកជាផ្លូវការក៏ដោយ ក៏ប្រជាជនកម្ពុជាជាច្រើននៅតែប្រារព្ធពិធីនេះយ៉ាងទូលំទូលាយ។

បើតាមប្រវត្តិសាស្ត្រ ការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីនេះ បានកើតឡើងនៅប្រទេសចិនតាំងពីជាង២០០០ឆ្នាំមុនគ.ស. មកម៉្លេះ និងមានរឿងព្រេងនិទានចិនតំណាលថា ការចាប់ផ្តើមនៃពិធីបុណ្យចូលឆ្នាំចិន បានផ្តើមឡើងជាមួយការវាយប្រយុទ្ធប្រឆាំងជាមួយសត្វក្នុងទេវកថាមានឈ្មោះថា **នៀន** (Nian) ដែលមានខ្លួនជាសត្វគោ និងក្បាលជាតោ ដែលតែងតែចូលក្នុងភូមិខាំសម្លាប់អ្នកភូមិនៅចុងរដូវត្រជាក់ ដែលកំណត់ការមកដល់ឆ្នាំថ្មី។ ពាក្យ **នៀន** ក្នុងភាសាចិន ក៏មានន័យថា **ឆ្នាំ** ដែរ។ ដូច្នេះ នៅពេលរដូវត្រជាក់ត្រូវបានបញ្ចប់ វាជាសញ្ញាបញ្ជាក់ថា ពេលគ្រោះកាចនិងទុរ្ភិក្សចាប់ផ្តើមកើតឡើងហើយ។ នៅថ្ងៃទីមួយក្នុងឆ្នាំថ្មី នៀនបានមកកាប់សម្លាប់ពួកបសុសត្វ សូម្បីតែអ្នកភូមិក៏ដោយ ជាពិសេសគឺពួកក្មេងៗ ហើយដើម្បីការពារខ្លួន អ្នកភូមិបានដាក់ចំណីអាហារនៅមុខផ្ទះរបស់ពួកគេជារៀងរាល់ដើមឆ្នាំ។ គេមានជំនឿថា បន្ទាប់ពីនៀនបានស៊ីចំណីអាហារដែលពួកគេដាក់ឱ្យរួចហើយ វានឹងមិនធ្វើបាប កាប់សម្លាប់ប្រជាជនទៀតទេ។

គ្រាមួយ អ្នកភូមិបានរកឃើញថា នៀនមានភាពភ័យខ្លាចជាមួយនឹងសំឡេងកងរំពង ខ្លាចភ្លើង និងខ្លាចពណ៌ក្រហម ហើយពណ៌ក្រហមក៏បានក្លាយជានិមិត្តរូបនៃសុភមង្គល និងសំណាងល្អ។

ហេតុនេះហើយនៅពេលដែលឆ្នាំថ្មីមកដល់ អ្នកភូមិនាំគ្នាបំពាក់គោមពណ៌ក្រហម និង បិតក្រដាសពណ៌ក្រហមនៅតាមទ្វារ និង បង្អួចផ្ទះរៀងៗខ្លួន ហើយអ្នកភូមិក៏បាន ប្រើផាវ ដើម្បីបណ្ដេញនៀនឱ្យទៅឆ្ងាយ ផងដែរ។ បន្ទាប់ពីពេលនោះមក នៀនពុំ បានមកក្នុងភូមិម្ដងទៀតឡើយ។ នៅចុង ក្រោយ **ហុងជុនឡាវស៊ូ** ជាព្រះសង្ឃ**សាសនា**តាវបុរាណម្នាក់ បានចាប់សត្វនៀន នោះ ហើយសត្វនៀនក៏ខាចទៅជាយាន ជំនិះរបស់ព្រះសង្ឃហុងជុនឡាវស៊ូទៅ។



រូបភាពពីGoogle ស្ដីពីសត្វនៀននៃប្រវត្តិចូលឆ្នាំចិន

នៅក្នុងឆ្នាំថ្មីមកដល់ មេគ្រួសារនឹង ប្រមូលកូនចៅ ដើម្បីដឹងថា មានអ្នកស្លាប់ ឬរស់ប៉ុន្មាននាក់ បន្ទាប់ពីសត្វនៀនចូល យាយីក្នុងភូមិ។ មកដល់ពេលបច្ចុប្បន្ននេះ ឆ្នាំថ្មីវាលែងជាពេលត្រូវខ្លាចរអាទៀត ហើយ តែវាជាពេលដែលក្រុមគ្រួសារជួប ជុំគ្នាដើម្បីបង្កើតសំណើចភាពកក់ក្ដៅ និង សុភមង្គលដែលជាទូទៅប្រជាជនចិន ឬ អ្នកជាប់សែស្រឡាយចិន បានប្រារព្ធធ្វើ ពិធីអបអរឆ្នាំថ្មីនៅថ្ងៃទីមួយនៃឆ្នាំថ្មី តាម ប្រតិទិនចន្ទគតិ ឬចន្លោះចុងខែមករា និង ដើមខែកុម្ភៈ តាមប្រតិទិនសុរិយគតិ។ បើ តាមការសង្កេតជាទូទៅ បុណ្យចូលឆ្នាំចិន គឺមានគោលគំនិតធំៗ៣ ដែលទី១គឺជាការ ជួបជុំគ្នាក្នុងរង្វង់ក្រុមគ្រួសារ ឬទៅជួបជុំ គ្នានៅស្រុកកំណើត២ គឺការដឹងគុណអ្នក ដែលបានស្លាប់ទៅនិងដឹងគុណចាស់ទុំ ដែលនៅរស់ និងទី៣ គឺជាការចែករំលែក គ្នា គឺការចែករំលែកនំចំណីនិងទ្រព្យធន ខ្លះ(នៅពេលសែនព្រេនរួច) ដល់ញាតិមិត្ត ឬអ្នកខ្សត់ខ្សោយ។

ការប្រារព្ធបុណ្យចូលឆ្នាំថ្មី ដើម្បី ឧទ្ទិសដល់វិញ្ញាណដីដូនជីតា កុងម៉ា និង អាទិទេព ហើយវាជាពេលដែលក្រុមគ្រួ សារដែលនៅឃ្លាតឆ្ងាយពីគ្នា ត្រូវត្រឡប់ មកជួបជុំគ្នាវិញ គឺឆ្នាំ២០២២នេះ ថ្ងៃទី៣១ ខែមករា គឺជាថ្ងៃសែនធ្ងងឆ្នាំ។ ពេលសែន ធ្ងងឆ្នាំនេះ គេតែងតែធ្វើម្ហូបអាហារជា

ច្រើនមុខយ៉ាងបរិបូរណ៍ ដើម្បីសែនដូនតា ហើយគេជប់លៀងជួបជុំបងប្អូនហូបបាយជាមួយគ្នា ដើម្បីសុខសប្បាយក្នុងគ្រួសារ ដ្បិតមួយឆ្នាំមានតែម្ដង។

ដើម្បីអបអរឆ្នាំថ្មី មុនថ្ងៃចូលឆ្នាំថ្មីមកដល់ ជនជាតិចិន និងអ្នកជាប់ខ្សែស្រឡាយចិននៅកម្ពុជា គេនាំគ្នាទិញសម្លៀកបំពាក់ថ្មីៗ កាត់សក់ សងបំណុលដែលជំពាក់គេ ក្នុងគោលបំណងចាប់ផ្ដើមឆ្នាំថ្មីឱ្យបានស្រស់ស្រាយ និងបានដើររកទិញរបស់របរគ្រឿងតុបតែងមានផ្កាភ្លី មានដើមផ្កាអង្គារសីល ផ្កាស្បៃរឿង ដើមក្រូច បន្លែត្រីសាច់ និងផ្លែឈើ ដើម្បីទុកត្រៀមទទួលឆ្នាំថ្មី ក៏ដូចជាការបោសសម្អាតផ្ទះសម្បែងដើម្បីបណ្ដេញឧបទ្រពចង្រៃចេញពីផ្ទះ និងរៀបចំតុបតែងផ្ទះឱ្យមានហុងស៊ុយ ឬសំណាងល្អ ហើយសម្រាប់អ្នកកាន់ព្រះពុទ្ធសាសនា មួយថ្ងៃមុនចូលឆ្នាំ គេតែងតែរៀបចំសែនដូនតា ដោយអ្នកខ្លះសែននៅផ្ទះ ខ្លះសែននៅព្រះវិហារ ហើយខ្លះសែនទាំងនៅផ្ទះទាំងនៅព្រះវិហារ គឺអាស្រ័យលើទម្លាប់នៃគ្រួសារនីមួយៗ។

ក្រោយពីសែនហើយ សមាជិកគ្រួសារនីមួយៗតែងតែបរិភោគអាហារជុំគ្នា និងចែកអាំងប៉ាវដែលជាក្រដាសពណ៌ក្រហមដើម្បីនាំសំណាងឱ្យគ្នាទៅវិញទៅមក ដោយអាំងប៉ាវនោះ មានសារជូនពរនៅផ្នែកខាងក្រៅ និងលុយនាំសំណាងនៅផ្នែកខាងក្នុង (អាំងប៉ាវ មកពីពាក្យ **អាំង** គឺក្រហម **ប៉ាវ** គឺខ្ចប់ គឺដើម្បីខ្ចប់លុយឱ្យក្មេងៗនាំលាភ នាំសំណាង និងនាំភាពសុខសប្បាយដល់ពួកគេ។ ឥឡូវគេធ្វើអាំងប៉ាវជាពាងកញ្ចប់បួនជ្រុង ដើម្បីដាក់លុយឱ្យទៅបុគ្គលដែលគេចង់ឱ្យ ជាពិសេសអ្នកដែលមានគ្រួសារហើយ ដល់ពេលចូលឆ្នាំគឺត្រូវជូនអាំងប៉ាវដល់ចាស់ទុំ ដើម្បីជូនពរបានសុខភាពល្អ អាយុវែង និងសុខសប្បាយក៏ដូចជាផ្ដល់ដល់ក្មេងៗដែលមាននៅក្នុងគ្រួសារ។ ចំណែកនៅតាមបណ្ដាក្រុមហ៊ុនក៏ដូចគ្នាដែរ គឺថៅកែ ឬប្រធានក្រុមហ៊ុនតែងតែផ្ដល់អាំងប៉ាវដល់បុគ្គលិក ដើម្បីឱ្យមានលាភ មានសិរី មានជោគមានជ័យ និងមានសំណាងល្អ។ សូមបញ្ជាក់ថា ការជួបជុំគ្រួសារនៅថ្ងៃបុណ្យចូលឆ្នាំប្រពៃណីចិន សមាជិកនៃគ្រួសារ ម្នាក់ៗរីករាយជួបជុំគ្នាយ៉ាងសប្បាយត្រេកអរដោយមានសំឡេងជូនពរជ័យថា« **កុងស៊ីហ្វាឆាយ**» គឺ«**កុង ស៊ី**» មានន័យថា អបអរសាទរ

ចំណែក «**ហ្វាឆាយ**» មានន័យថា ជូនពរឱ្យរកស៊ីមានបាន។ **កុងស៊ីហ្វា ឆាយ** «រីករាយថ្ងៃចូលឆ្នាំថ្មី» មានការជូនអាំងប៉ាវ មានការបរិភោគអាហារជុំគ្នា និងមានការលេងល្បែងស៊ីសងជាដើម ដ្បិតជនជាតិចិន និងអ្នកជាប់សែស្រឡាយចិនមួយចំនួនយល់ថា ការលេងល្បែងស៊ីសងនៅថ្ងៃចូលឆ្នាំថ្មីនេះ គេជឿជាក់ថា អាចបង្កើតសំណាងល្អ។

## អំពីការសែន

ចំពោះរបៀបរៀបចំសែនរបស់ជនជាតិចិន និងអ្នកមានសែស្រឡាយចិននៅកម្ពុជា មានទម្លាប់រៀបចំសែនដោយមានក្រាលកន្ទេល ឬដាក់នៅលើតុដែលមានជើងធូបកុងម៉ានៅទីនោះ ហើយមានជើងធូបអ្នកតានៅមិនឆ្ងាយពីគ្នានោះទេ ដោយមានរៀបចំមុខម្ហូប នំចំណី គេសជ្ជៈ និងផ្លែឈើ អាស្រ័យទៅតាមការពេញចិត្តរបស់សាមីខ្លួន។ តែលក្ខណៈពិសេសម្យ៉ាងក្នុងអំឡុងពេលសែនពិធីបុណ្យចូលឆ្នាំចិន គឺការជ្រើសរើសយកមុខម្ហូប បង្អែម និងផ្លែឈើណាដែលគេមានជំនឿថានាំលាភសំណាង និងមានភាពចម្រុងចម្រើនដល់ក្រុមគ្រួសារពេញរយៈពេល១ឆ្នាំ ហើយមុខម្ហូបនិងផ្លែឈើដែលនាំលាភសំណាងនោះមានដូចជា៖ ជ្រូកខ្វៃ ត្រី គាវ សាយ៉ មីសរសៃវែង ក្រូចឃ្វិច និងផ្លែក្រូច។ ចំណែកបង្អែមមាន ដូចជា នំឡើង (នំពងទាដុត) និង នំអុីជាដើម។

***ជ្រូកខ្វៃ***៖ ជនជាតិចិននៅខ្មែរ និងអ្នកជាប់សែស្រឡាយចិន គេនិយមសែនជ្រូកខ្វៃ ព្រោះតំណាងឱ្យការរកស៊ីធូរធារហូបឆ្ងាញ់ ដេកស្រួល។ ការសែនជ្រូកខ្វៃ គេត្រូវសែនជ្រូកខ្វៃដោយដាក់ជ្រូកបែរមុខចូលក្នុងផ្ទះ គឺមានន័យថា ការរកលុយពីក្រៅចូលក្នុងផ្ទះ ដូច្នេះការដាក់សែនជ្រូកខ្វៃបែរមុខចូលក្នុងផ្ទះ ប្រៀបដូចជ្រូកបោលយកលុយ នាំលាភចូលផ្ទះ។ ជ្រូកជាមិត្តសំឡាញ់របស់ប្រជាជនចិន ប៉ុន្តែអ្នកកើតឆ្នាំជ្រូកមួយចំនួន គេមិនសែនជ្រូកខ្វៃទេ ព្រោះគេមានអារម្មណ៍ថាជារូបខ្លួនឯងដោយជំនួសមកវិញនូវការសែនមាន់ ទា ឬត្រី។ ជនជាតិចិន ឬខ្មែរកាត់ចិនមួយចំនួនតែងកាត់យកផ្នែកសំខាន់ៗនៃជ្រូកខ្វៃ ទៅឆ្អើរភ្លើងឱ្យក្រៀម ទុកគ្រាន់ដាក់នៅកន្លែងរកស៊ី ដោយពួកគេមានជំនឿថា វានឹងអាចនាំលាភដល់ការប្រកបរបររកស៊ី ដូចជា៖

ខួរជ្រូក(ខួរគឺតំណាងឱ្យប្រាជ្ញា ស្មារតី និងភាពឈ្លាសវៃ មានគំនិតថ្មីៗក្នុងការរកស៊ីឈ្នះគេក្នុងឆ្នាំថ្មីជាដើម) ត្រចៀកជ្រូក (គេជឿថាត្រចៀកគឺជាសរីរាង្គមួយដែលអាចឮដំណឹងផ្សេងៗ ជិតឬឆ្ងាយ ហើយបើអ្នករកស៊ីវិញ គឺគេចាំស្ដាប់ដំណឹងដែលភ្ញៀវមករក) ច្រមុះជ្រូក (ជ្រូកតែងប្រើច្រមុះរបស់វាសម្រាប់ហិតក្លិន និងដើម្បីឈ្ងុសឈ្ងុលរកចំណី ប្រៀបដូចជាអ្នកជួញដូរដែលត្រូវខិតខំស្វះស្វែងរកអតិថិជនរបស់ខ្លួនដូច្នោះដែរ) ក្រចកជើងទាំងបួន(ក្រចកជើងទាំងបួនរបស់ជ្រូក ត្រូវគេជឿថាអាចនាំឱ្យមុខរបររកស៊ីដើរឆ្ពោះទៅមុខ ព្រោះជ្រូកអាចដើរទៅមុខបានក៏ដោយសារតែជើងទាំង៤នេះ និងម្យ៉ាងទៀតពេលដែលជ្រូកខ្ទេដេក គឺជើងខាងមុខរបស់វាបត់ចូលប្រៀបដូចជាកាយនាំទ្រព្យដល់ម្ចាស់ផ្ទះ) រីឯកន្ទុយជ្រូក (ជ្រូកប្រើកន្ទុយសម្រាប់បក់ដេញរុយ ឬសត្វល្អិតជាដើម ដូច្នេះ អ្នករកស៊ីទុកកន្ទុយជ្រូកសម្រាប់ឱ្យវាដេញឧបសគ្គ និងឧបទ្រពចង្រៃនានាចេញពីហាងលក់ដូរ)។

**ត្រី៖** ក្នុងភាសាចិន ពាក្យ«ត្រី» មានន័យថា «ភោគផលច្រើន»។ ជនជាតិចិនចូលចិត្តមានភោគផលទ្រព្យសម្បត្តិច្រើននៅចុងឆ្នាំ ដូច្នេះគេនឹងមានលទ្ធភាពរៀបចំពិធីចូលឆ្នាំថ្មីនៅឆ្នាំក្រោយកាន់តែអធិកអធម និងសប្បាយជាងមុន។ «ត្រី» ត្រូវបានចម្អិនជាច្រើនរបៀបដូចជា ស្ងោរ ចំហុយ និងអាំង។ មុខម្ហូបត្រីរបស់ចិនពេញនិយមជាងគេបំផុតគឺ ត្រីរីចំហុយ ត្រី West Lake ជាមួយនឹងស្ពៃជ្រក់ និងម្ទេសក្រហម ត្រីចំហុយជាមួយទឹកខ្មេះ និងត្រីស្ងោរ។ ដូច្នេះត្រីគឺជានិមិត្តរូបផ្ដាញភាពរុងរឿងនៅថ្ងៃចូលឆ្នាំចិន។

**គាវ៖** ប្រវត្តិសាស្ត្រជាង១៨០០ឆ្នាំ « គាវ» គឺជាមុខម្ហូបទំនៀមទម្លាប់បុរាណចិនដែលទទួលទាននៅថ្ងៃចូលឆ្នាំសាកល។ ទំនៀមទម្លាប់នេះមានការពេញនិយមក្នុងប្រទេសចិន ជាពិសេសប្រទេសចិនភាគខាងជើង។ គាវធ្វើឡើងដោយជនជាតិចិនដែលមានរូបរាងដូចមាសតម្លឹងរបស់ចិនជំនាន់ដើម ហើយវាមិនមានរាងជាក្ដារបន្ទះ ទូក និងរាងពងក្រពើជាដើម។ តាមរយៈការបកស្រាយរបស់រឿងព្រេងបុរាណចិនឱ្យដឹងថា ការទទួលទាននំគាវកាន់តែច្រើនក្នុងអំឡុងពេលចូលឆ្នាំថ្មី គឺជាការបង្កើតលុយកាក់កាន់តែច្រើន។

«នំគាវ» គឺជានំដែលរួមមានសាច់ចិញ្ច្រាំរួមទាំងបន្លែស្ថិតក្នុងម្សៅ ដែលគេធ្វើជារាងដុំមាសតម្ងឹងបុរាណចិន។ នំគាវមានច្រើនរសជាតិអាស្រ័យលើស្នូលសាច់ចិញ្ច្រាំរបស់វាដូចជា ស្នូលសាច់ជ្រូក បង្គា ត្រី មាន់ គោ និង ស្នូលបន្លែ។ ស្នូលនំគៀវទាំងនេះអាចចម្អិនជាច្រើនរបៀបគឺ ស្ងោរ ចំហុយ ចៀន និងដុត។

**សាយ៉៖**«សាយ៉» ជាភាសាចិនគឺ ធុនវ៉ែន ជាភាសាអង់គ្លេស Spring Rolls ឈ្មោះប្រើប្រាស់សព្វថ្ងៃ ដោយសារតែវាត្រូវបានទទួលទានក្នុងអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីចិន ឬបុណ្យនិទាឃរដូវ។ មុខម្ហូបមួយប្រភេទនេះពេញនិយមនៅតំបន់មួយចំនួននៃភាគខាងកើតប្រទេសចិនដូចជា ខេត្ត ជាំងស៊ី ជាំងស៊ូ សៀងហៃ ហ្វូយ៉ែន គ័ងហ្សូ ឈិនចិន និងហុងកុង។សាយ៉ គឺជាមុខម្ហូបរបស់ចិនកាតាំង ដែលមានរាងមូលទ្រវែង(ស៊ីឡាំង) មានស្នូលនៅខាងក្នុងដូចជាបន្លែ សាច់ ឬស្នូលរសជាតិផ្សេងទៀត ដែលត្រូវបានខ្ចប់ក្នុងម្សៅរួចចៀនជាការស្រេច។ បន្ទាប់ពីចម្អិនរួចរាល់ វាមានពណ៌លឿងឆ្អិនឆ្អៅប្រៀបបីដូចជាដុំមាសដ៏មានតម្លៃ។

**មីសរសៃវែង៖** «មីសរសៃវែង» ជានិមិត្តរូបតំណាងឱ្យភាពយូរអង្វែង។ សរសៃរមីដ៏វែងនេះមិនត្រូវបានកាត់ទេ ដើម្បីបញ្ជាក់ថា អ្នកទទួលទាននឹងមានសុខភាពបរិបូរណ៍ រស់នៅជាច្រើនឆ្នាំទៅមុខទៀត។ មីសរសៃត្រូវបានគេចម្អិនជាច្រើនរបៀបដូចជា ស្ងោរ ស្រុស និងឆា។

**ផ្លែឈើ៖** ផ្លែឈើដែលត្រូវដាក់សែន និងទទួលទាននាអំឡុងពេលចូលឆ្នាំចិន មានដូចជា ក្រូចឃ្វិច ក្រូចថ្លុង និងផ្លែក្រូចធម្មតា។ មូលហេតុដែលជនជាតិចិនជ្រើសរើសផ្លែឈើប្រភេទផ្លែក្រូចទទួលទាននៅថ្ងៃចូលឆ្នាំចិន ព្រោះផ្លែក្រូចជាភាសាចិនគឺ «ឆេងឆង» មានន័យថា «ជោគជ័យ»។ ក្រៅពីនេះផ្លែក្រូចមានរាងមូល និងពណ៌សំបកក្រៅប្រៀបដូចជាមាសក្រហមឆ្អិនឆ្អៅ ជានិមិត្តរូបតំណាងឱ្យទ្រព្យសម្បត្តិ។



*រូបភាពបង្ហាញពីរបៀបរៀបចំសែន និង សំណែនក្នុងពិធីបុណ្យចូលឆ្នាំចិន*

*សូមបញ្ជាក់ផងដែរថា មុននឹងពិធីបុណ្យចូលឆ្នាំចិនមកដល់ គេមានប្រាព្ធពិធីសែនមុនបុណ្យនេះ ចំនួន៥ឬ៦ថ្ងៃ មុនថ្ងៃសែនចូលឆ្នាំចិន គឺការសែនដកជើងធូប ដែលការសែននេះគេមានរៀបចំសែន ដូចពិធីសែនចូលឆ្នាំចិនផងដែរ។*

***ពិធីសែនដកជើងធូប ឬបុណ្យសែនអរគុណទេវតា*** *ត្រូវបានប្រជាជនចិន ឬកូនខ្មែរកាត់ចិន តែងតែប្រារព្ធឡើងជារៀងរាល់ចុងឆ្នាំចាស់ ពោលគឺមុនសែនចូលឆ្នាំចិនរយៈពេល ៥ ថ្ងៃទៅ ៦ ថ្ងៃ។*

*ឆ្នាំនេះដែរ ពិធីដកជើងធូបត្រូវធ្វើឡើងចំថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ហើយការសែននោះទៀតសោត គេមានវេលាសែនអាស្រ័យទៅតាមទីតាំងនៃផ្ទះផងដែរ ដូចជាឆ្នាំនេះ ពេលវេលាសែនដកជើងធូបល្អគឺ៖ បើផ្ទះបែរទៅកើតនិងត្បូង ត្រូវសែនម៉ោង ០៦:៥១នាទីព្រឹក បើផ្ទះបែរទៅជើងនិងទៅលិច ត្រូវសែនម៉ោង ០៧:១៤នាទីព្រឹក តែបើមិនបានធ្វើតាមម៉ោងពេលវេលាហុងស៊ុយនេះទេ គឺធ្វើយ៉ាងណាកុំឱ្យហួសថ្ងៃទី២៦នេះ។*

## គ្រឿងសែន

*.**សែនទេវតាមុខផ្ទះ** ៖ មានដូចជា តែក្តៅ៣កែវ ស្រាស៣កែវ សាស៊ៃ១ឈុត (មាន់ស្ងោរ សាច់ជ្រូកស្ងោរ ពងទាស្ងោរ) តាមលទ្ធភាព ផ្លែឈើ៣មុខ(ប៉ោម សារី ចេក) ស្ករគ្រាប់១កូនចាន ទៀនក្រហម១គូ អុជធូបម្នាក់៣សរសៃរ ក្រដាសសែនទេវតាមុខផ្ទះ១ឈុត។*

*. **សែនទេវតាជំនាងផ្ទះ**៖មានដូចជា តែក្តៅ៥កែវ ស្រាស៥កែវ សាស៊ៃ១ឈុត (មាន់ស្ងោរ សាច់ជ្រូកស្ងោរ ពងទាស្ងោរ) តាមលទ្ធភាព ជ្រូកខ្វៃ១ក្បាល (បើមានលទ្ធភាព ហាមជ្រូកកណ្តុរ ឬជ្រូកប្រលាក់គ្រឿងហិល។) ផ្លែឈើ៥មុខ (ប៉ោម សារី ក្រូចខ្វិច ស្រកានាគ និងចេក) ស្ករគ្រាប់១កូនចាន ទៀនក្រហម១គូ (អាចប្រើទៀនចាស់ដែលនៅសល់បាន)ធូបម្នាក់៥សសៃរ និងឈុតក្រដាសសែនជំនាងផ្ទះ។*

*. ទេវតាចង្ក្រាន មានដូចជា៖ តែក្តៅ៣កែវ ស្រាស៣កែវ (បើដាក់សាស៊ៃ បានដាក់ស្រាស) សាស៊ៃ១ឈុត(មាន់ស្ងោរ សាច់ជ្រូកស្ងោរ ពងទាស្ងោរ) តាមលទ្ធភាព ផ្លែឈើ៣មុខ (ប៉ោម សារី ចេក ) ស្ករគ្រាប់១កូនចាន ទៀនក្រហម១គូ អុជធូប*

ម្នាក់៣សរសៃរ ក្រដាសសែនទេវតាចង្រ្កាន១ឈុត។

. ***កន្ទែងទេវតាផ្សេងៗ*** *ដូចជា កុងម៉ាទេវតា គួនកុងទេវតា ព្រះម៉ែ គឺតែក្តៅ៣កែវ ស្រាស៣កែវ (បើដាក់សាស៊ៃ បានដាក់ស្រាស) សាស៊ៃ១ឈុត (មាន់ស្ងោរ សាច់ ជ្រូក ស្ងោរ ពង ទា ស្ងោរ) តាមលទ្ធ-ភាព ផ្លែឈើ៣មុខ(ប៉ោម សារី ចេក ) ស្ករគ្រាប់១កូនចាន ទៀនក្រហម១គូ អុជធូបម្នាក់៣សរសៃ។*

***ការសំអាត*** *គឺចាប់ផ្តើមសំអាតពីទីតាំងខាងក្រោម ទីតាំងទី១ គឺទេវតាមុខផ្ទះ ទីតាំងទី២ គឺទេវតាយាមផ្ទះ ទីតាំងទី៣ គឺទេវតាជំនាងផ្ទះ ទីតាំងទី៤ គឺកន្ទែងកុងម៉ា កន្ទែងទេវតាផ្សេងៗ និងទីតាំងទី៥ គឺទេវតាចង្រ្កាន។*

## គ្រឿងដែលត្រូវប្តូរចេញ

***១.ផេះក្នុងកំប៉ុងដើងធូបៈ*** *ដំបូងត្រូវដកជើងធូប៣សរសៃ ដែលអ្នកគិតថាស្អាតជាងគេ ទុកមួយកន្លែង លើកលែងតែកន្ទែងជំនាងផ្ទះមួយគត់ ដែលត្រូវដក៥សរសៃទុក។ បន្ទាប់មកដកជើងធូបទាំងអស់ ចេញមកដាក់ថង់ជំមួយ ហើយចាក់ផេះក្នុងកំប៉ុងជើងធូបចេញ ទុកប្រហែលជា១០ភាគរយនៃផេះចាស់នៅបាតកំប៉ុង យកលុយមួយសន្លឹក (ក្រដាសប៉ុន្មានក៏បានដែរ) បត់ឱ្យតូចជាបួនជ្រុង ដាក់ចូលក្នុងកំប៉ុង ចាក់គ្រាប់ពូជចូលក្នុងកំប៉ុង ចាក់ផេះថ្មីចូល (ជាផេះ មិនមែនប្រភេទខ្សាច់ទេ ក៏មិនមែនជាប្រភេទកំទេចថ្មអ្វីដែរ គឺជាផេះតែម្តង) ចាក់បំពេញកំប៉ុងប្រហែល៩០ភាគរយ សល់១០ភាគរយ យកផេះមាសចាក់បំពេញពីលើ ជូតកំប៉ុងឱ្យស្អាត និងយកជើងធូបដែលដកទុកពីមុន មកដោតឱ្យចំកណ្តាលជាការស្រេច។*

***២.គីមហួយៈ*** *ផ្ទះខ្លះមានដាក់ ខ្លះមិនមានដាក់ទេ គឺមិនចោទជាបញ្ហាអ្វីនោះទេ។ គីមហួយ ត្រូវដូរថ្មីដូចគ្នា តែយើងត្រូវមើលគ្រាប់បាល់នៃគីមហួយនោះមានប៉ុន្មានគ្រាប់ ដូរថ្មីមិនត្រូវតិចជាងចំនួនគ្រាប់បាល់ចាស់នោះទេ អាចស្មើចាស់ ឬច្រើនជាង។*

***៣.កំណាល់ជើងធូប*** *ឬកំណាល់លោកតា ផ្ទះខ្លះមានដាក់ ផ្ទះខ្លះមិនមានដាក់ទេ តែបើអាចដាក់បានគឺល្អ។ កំណាល់ជើងធូបត្រូវរាបស្មើ មិនត្រូវមានខ្ពស់ទាបនោះទេ ហើយក៏មិនត្រូវខ្ពស់ជាងកំណាល់*

រូបសំណាក់ទេវតាដែរ តែអាចដាក់ស្មើគ្នាបាន។

**៤.អំពូលក្រហម ឬអំពូលម្ទេស** បើដាច់ត្រូវដូរចេញ តែបើមានលទ្ធភាពគឺគេដូរថ្មីទាំងអស់ ទោះបីជាអំពូលនោះមិនដាច់ក៏ដោយ ដ្បិតពន្លឺវាមិនសូវភ្លឺ បើដូរថ្មីវាភ្លឺស្អាត ឆ្នាំថ្មីអាចជួបហេង ជួបមនុស្សល្អៗជាច្រើន។

នៅក្នុងឆ្នាំ២០២២នេះ គេមានជំនឿថា គ្រឿងដែលដោះដូរខាងលើ និងជើងធូបចាស់ៗ លើកលែងតែអំពូលក្រហម ឬអំពូលម្ទេស គេមិនឱ្យយកទៅចោលនៅក្នុងទឹកទន្លេនោះទេ គឺត្រូវដុតដោយភ្លើងដោយដុតនៅចន្លោះម៉ោង ៦:៤៦យប់ដល់ម៉ោង ៧:៣៥នាទី។

ចាប់ពីថ្ងៃសែនដកជើងធូបនេះ រហូតដល់ថ្ងៃសែនចូលឆ្នាំចិន គេមិនចាំបាច់អុជធូបទេនោះ ហើយគ្រឿងសំណែនដែលសែននោះ ក៏អាចលើកឡើងបានដូចគ្នា មិនបាច់ទុកនោះទេ។



រូបភាពពនៃរបៀបសែនដកជើងធូប

## អំពីជំនឿផ្សេងៗរបស់ជនជាតិចិនក្នុងថ្ងៃចូលឆ្នាំចិន

ក្នុងពិធីបុណ្យចូលឆ្នាំចិន គេមានការគោរពប្រតិបត្តិនូវជំនឿផ្សេងៗជាច្រើន ក្នុងនោះមានការបិទយ័ន្តនៅមុខផ្ទះ មានការដុតផាវ មានការឡុកម៉ុងសាយ មានការសែនព្រេន មានការដុតក្រដាស ដុតធូបនៅព្រះវិហារ ការនាំយកអំពៅខ្មៅ និងស្ទីកមៀន និងការតាំងផ្កាអង្គារសីល ផ្កា

ស្បែរឿង និងដើមក្រូចនាំសំណាងនៅក្នុងផ្ទះជាដើម។

ជំនឿនៃការតាំងលម្អដើមផ្កាអង្គារសីល និងដើមក្រូចនេះ ជនជាតិចិនតែងជឿថាគេនឹងទទួលបានលាភជ័យសំណាង ក្នុងឆ្នាំថ្មី ព្រោះផ្កាអង្គារសីល ពណ៌របស់វាត្រូវបានតំណាងឱ្យពណ៌មាស ជាពណ៌ដែលនាំមកនូវទ្រព្យសម្បត្តិ ភាពរុងរឿង និងហេងៗក្នុងឱកាសឆ្នាំថ្មី។ រីឯដើមក្រូច ត្រូវតែមានផ្លែខ្ចីខ្លះ ទុំខ្លះ ហើយស្លឹកវិញត្រូវមានសភាពចំណាស់បន្តិចៗ ផ្លែក្រូចត្រូវមានកញ្ចុំផ្លែថ្មី ដែលមានន័យថា លុយនិងសំណាង នឹងហូរចូលក្នុងគ្រួសារ ឬកន្ទ្វេងរកស៊ី ក្នុងឱកាសចូលឆ្នាំថ្មី និងលាភសំណាងពេញមួយឆ្នាំ។ គេក៏និយមយកអាំងប៉ាវពណ៌ក្រហមមកចងព្យួរលើដើមផ្កាអង្គារសីលដែរ ព្រោះពណ៌ក្រហម ក៏ជាពណ៌ដែលប្រជាជនចិន ជឿជាក់ថាជាពណ៌នាំលាភសំណាងដូចគ្នា។



រូបភាពនៃការតាំងផ្កាអង្គារសីល និងការតាំងលក់ដើមក្រូច

ក្រៅពីជំនឿលើមុខម្ហូបអាហារ នំចំណី ផ្លែឈើ ជនជាតិចិននិងអ្នកជាប់សែស្រឡាយចិននៅកម្ពុជា ក៏មានការជឿលើការឡុកម៉ុងសាយ ដែលជារបាំប្រពៃណីចិនមួយដែលអ្នកសម្តែងពាក់ក្រណាត់ខ្មៃជារូបសត្វតោ ហក់លោតចុះឡើងនៅលើបង្គោលដែក ហើយធ្វើត្រាប់តាមកាយវិការសត្វតោពិតៗ និងមានបញ្ចូលនូវក្បាច់ គុណពិសេសៗជាច្រើនទៀត អមដោយអ្នកវាយស្គរលាន់ទ្រហឹងអឺងកងឱ្យស៊ីទៅនឹងចង្វាក់នៃការលោតផ្លោះរបស់តោដែល

មានឫទ្ធិខ្លាំងក្លា អាចបណ្ដេញ ឬកម្ចាត់ការៈ អាក្រក់ឧបទ្រពចង្រៃទាំងពួង ដើម្បីនាំមកនូវសិរីសួស្ដី នាំលាភនាំជ័យក្នុងឆ្នាំថ្មី។ ចំពោះការរាំម៉ុងសាយនេះ ក្នុងតួខ្លួនម៉ុងសាយមួយ គេត្រូវការឱ្យមានអ្នកសម្ដែងចំនួនពីរនាក់ ដោយម្នាក់នៅក្បាលតោ និងម្នាក់ទៀតនៅកន្ទុយតោ ហើយអ្នកឡកម៉ុងសាយ គេមិនងាយនឹងឃើញមុខទេ ព្រោះគ្របជិតដោយសម្លៀកបំពាក់តោ។

តាមរយៈអ្នកសិក្សាស្រាវជ្រាវផ្នែកវប្បធម៌ចិនបានឱ្យដឹងថា ប្រពៃណីទំនៀមទម្លាប់នេះ គឺជនជាតិចិនបានធ្វើតៗគ្នាទៅតាមការនិទានតគ្នារបស់ដូនតា ឬកុងម៉ាពីមួយជំនាន់ទៅមួយជំនាន់ដែលគេជឿថា ការឡកម៉ុងសាយជាការនាំហុងស៊ុយលើករាសី បណ្ដេញឧបទ្រពចង្រៃក្នុងឆ្នាំចាស់ចេញឱ្យអស់ ហើយនាំមកនូវសំណាងល្អក្នុងឆ្នាំថ្មី។ ជំនឿនេះមិនមែនមានតែពលរដ្ឋសាមញ្ញនោះទេ សូម្បីតែអ្នកជំនួញក្រុមហ៊ុនធំៗមួយចំនួនក៏មានជំនឿនេះដូចគ្នានិងបានធ្វើពិធីឡកម៉ុងសាយដែលមានភាពទំនើបនិងអស្ចារ្យ ដែលធ្វើឱ្យមានការទាក់ទាញដល់អ្នកទស្សនាថែមទៀតផង និងរំពឹងថា នឹងធ្វើឱ្យការរកស៊ីរបស់ពួកគេទទួលបានជោគជ័យ និងរីកចម្រើនជាលំដាប់។



រូបភាពពី Google ស្ដីពីការឡកម៉ុងសាយនៅក្នុងពិធីបុណ្យចូលឆ្នាំចិន

## ជំនឿ និងត្រណមក្នុងថ្ងៃបុណ្យចូលឆ្នាំចិន

តាមប្រវត្តិសាស្ត្រចិន មានជំនឿលើការគោរពបុណ្យចូលឆ្នាំថ្មីយ៉ាងខ្ជាប់ខ្ជួន។ គេមានត្រណមជាច្រើន នៅក្នុងអំឡុងចូលឆ្នាំបីថ្ងៃ ជាពិសេសថ្ងៃទី១ ឬហៅថា ឈឺអឺច។ ក្នុងរយៈពេល៣ថ្ងៃនេះ គេចាត់ទុកជាថ្ងៃពិសេសបំផុតដែលមិនត្រូវធ្វើអ្វីល្អក់កករនាំឱ្យប៉ះពាល់ដល់មង្គល ឬដល់ឆ្នាំថ្មីឡើយ។ គេត្រូវធ្វើឱ្យមានការសប្បាយ

រីករាយនាំសិរីសួស្តីដល់ខ្លួននិងក្រុមគ្រួសារ។ ត្រណមមួយចំនួនមិនត្រូវឱ្យកើតមានក្នុងពិធីបុណ្យចូលឆ្នាំចិនគឺ៖

**- ត្រណមមិនយំ៖** ក្នុងអំឡុងបុណ្យចូលឆ្នាំថ្មី ជនជាតិចិនមានត្រណមមិនឱ្យកើតរឿងយំសោកសៅទេ ពីព្រោះវាអាចនាំមកនូវរឿងអពមង្គលដល់ឆ្នាំថ្មីរហូតពេញមួយឆ្នាំ។ ត្រណមនេះសូម្បីតែកូនចៅដែលរឹងរូសឬធ្វើខុស ក៏ឪពុកម្តាយឬមនុស្សចាស់មិនវាយឬប្រៀនប្រដៅដែរ គឺអត់ទ្រាំរហូតដល់ចប់ថ្ងៃប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីសិន ។

**-ត្រណមមិនឱ្យបែកចាន ឬកែវ៖** ក្នុងថ្ងៃនេះគេមានការប្រយ័ត្នប្រយែងចំពោះការកាន់ចាន ឬកែវ ព្រោះបើមានបង្កឱ្យប្រេះស្រាំ ឬធ្លាក់បែក គឺជាការនាំឱ្យបាត់បង់ជោគលាភ ហើយជីវិតក្នុងឆ្នាំនោះនឹងជួបតែរឿងប្រេះឆាពុំសូវមានសេចក្តីសុខឡើយ។

**តែងខ្លួនស្អាតៗ តែមិនគួរកក់សក់៖** ការស្លៀកពាក់ខោអាវថ្មី និងតែងខ្លួនស្អាតបាទជារឿងសំខាន់បំផុតសម្រាប់មនុស្សគ្រប់រូបក្នុងថ្ងៃទទួលឆ្នាំថ្មី។ ទោះបីយ៉ាងណាក្នុងអំឡុងពេលនេះ គេមានត្រណមមួយ គឺហាមកក់សក់ ប៉ុន្តែកន្លែងដទៃៗទៀតអាចធ្វើការសម្អាតបានធម្មតា ពីព្រោះថាការកក់សក់គេមានជំនឿថាហាក់បីដូចជាការលាងជម្រះជោគសំណាងចេញពីខ្លួនដូច្នោះដែរ។ ចំពោះសម្លៀកបំពាក់ពណ៌ក្រហមជាទីពេញនិយមបំផុត ដែលគេប្រើសម្រាប់ស្លៀកពាក់ក្នុងអំឡុងចូលឆ្នាំចិន។ ពណ៌នេះគេចាត់ទុកជាពណ៌ផ្លូវហេងនាំជោគលាភ និងសិរីសួស្តី។ សម្រាប់ក្មេងៗឬមនុស្សនៅលីវ គេតែងឱ្យអាំងប៉ាវ ដែលជាកញ្ចប់លុយពណ៌ក្រហម ព្រមទាំងក្រដាសប្រាក់ថ្មីៗ ដើម្បីទទួលជោគលាភសម្រាប់ឆ្នាំថ្មីផងដែរ។

**ហាមចូលបន្ទប់របស់អ្នកដទៃ៖** ការចូលទៅរកនរណាម្នាក់ក្នុងបន្ទប់ដេករបស់គេក្នុងថ្ងៃបុណ្យចូលឆ្នាំចិន ចាត់ទុកថាជាជោគសំណាងអាក្រក់។ ដូច្នេះទោះបីអ្នកមានជំងឺក៏ដោយ បើមានសាច់ញាតិមកសួរសុខទុក្ខ ក៏ចាំបាច់ត្រូវចេញមកអង្គុយក្នុងបន្ទប់ទទួលភ្ញៀវដែរ។

**មិនគួរប្រើកាំបិត ឬកន្ត្រៃក្នុងថ្ងៃបុណ្យចូលឆ្នាំថ្មី៖** ព្រោះគេមានជំនឿថានេះជាការកាត់ជោគលាភ ហើយបើមាន

មុតដៃជើងផង គឺកាន់តែជួបរឿងអាក្រក់ថែមទៀត។

ក្រៅពីត្រណមខាងលើនេះមានត្រណមជាច្រើនទៀតដូចជា៖

-មិនត្រូវឈ្លោះប្រកែកគ្នា(នាំឱ្យកើតមានទុក្ខសោកពេញ១ឆ្នាំ)

-មិនត្រូវកាត់សក់ ក្រចកដៃ (ព្រោះនាំក្តីឈឺចាប់ដល់សមាជិកគ្រួសារ) ។

-មិនត្រូវប្រមូលលុយពីអ្នកជំពាក់បំណុល(មានន័យថាអ្នកនឹងត្រូវស្វែងរកអ្នកជំពាក់បំណុលក្នុងឆ្នាំថ្មីពេញ១ឆ្នាំ) ។

- មិនត្រូវទិញសៀវភៅពេលចូលឆ្នាំចិនទេ ព្រោះពាក្យ «សៀវភៅ» ជាភាសាចិនគឺ «ហ្ស៊ូ» មានន័យថា «បាត់បង់» ។

ដូច្នេះសរុបសេចក្តីមក ពិធីបុណ្យចូលឆ្នាំចិននៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ គឺតែងតែប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ហើយពីមួយឆ្នាំទៅមួយឆ្នាំជនជាតិចិននិងប្រជាពលរដ្ឋខ្មែរជាប់សែស្រឡាយចិននៅក្នុងប្រទេសកម្ពុជា បាននាំគ្នាប្រារព្ធពិធីចូលឆ្នាំចិនកាន់តែច្រើនឡើងៗ។ បើតាមសមាគមខ្មែរចិន ធ្លាប់បានអះអាងថា ជនជាតិចិននិងជនជាតិខ្មែរជាប់សែស្រឡាយចិនដែលកំពុងរស់នៅកម្ពុជាសព្វថ្ងៃ មានចំនួនប្រមាណជាជាងមួយលាននាក់ ដែលចំនួននេះមិនច្រើនប៉ុន្មានទេ ប៉ុន្តែបើផ្អែកលើទិដ្ឋភាពជាក់ស្តែងវិញ ពលរដ្ឋខ្មែរច្រើនជាងចំនួននេះឆ្ងាយណាស់ បាននាំគ្នាប្រារព្ធពិធីបុណ្យចូលឆ្នាំចិន។ នៅពេលបុណ្យចូលឆ្នាំចិនម្តងៗនៅតាមដងផ្លូវនានា ការធ្វើចរាចរណ៍ហាក់មានសភាពស្ងាត់ជ្រងំខុសប្លែកពីធម្មតា ពីព្រោះប្រជាជនភាគច្រើនរវល់អបអរពិធីចូលឆ្នាំចិននៅតាមគេហដ្ឋានរៀងៗខ្លួន។ ក្រុមហ៊ុន និងហាងលក់ទំនិញភាគច្រើននៅតាមដងវិថីសំខាន់ៗនៅទីក្រុងភ្នំពេញបានបិទទ្វារ។ សាលាឯកជនបានប្រកាសពីការឈប់សម្រាក រីឯសាលារដ្ឋដែលមិនមានការឱ្យឈប់សម្រាក ក៏មិនសូវមានកូនសិស្សទៅរៀន ពោលគឺបើទោះបីជាថ្ងៃចូលឆ្នាំចិនមិនមែនជាថ្ងៃឈប់សម្រាកក៏ដោយ ក៏វាហាក់ដូចជាមានសភាពស្ងប់ស្ងាត់ រហូតដល់ពិធីចូលឆ្នាំចិនត្រូវបានបញ្ចប់ ទើបមានដំណើរការជាធម្មតាឡើងវិញ។

ជាការកត់សម្គាល់កន្លងមកឃើញថា នៅពេលចូលឆ្នាំចិន ជនជាតិចិននិងពលរដ្ឋខ្មែរដែលជាប់សែស្រឡាយចិននៅ

ក្នុងប្រទេសកម្ពុជា តែងតែនាំគ្នាអុជផាវ មានផាវតូច ផាវធំ និងផាវខ្វះលាន់ឮដូចផ្ទុះអាវុធក៏មាន ហើយការអុជផាវបន្ទឺសំឡេងខ្លាំងៗនៅអំឡុងពេលដែលមានការសែនព្រេនក្នុងឱកាសចូលឆ្នាំចិននេះ គេមានជំនឿថា គឺជាការបង្អាញពីភាពទាក់ទាញ ប្រមូលចូលនូវលាភសំណាង និងបញ្ជាក់ថា ថ្ងៃចូលឆ្នាំថ្មីបានមកដល់ហើយ។

កាលពីមុន នៅប្រទេសកម្ពុជា ការអុជផាវនៅអំឡុងពេលបុណ្យចូលឆ្នាំចិនត្រូវបានគេធ្វើឡើងជារៀងរាល់ឆ្នាំ។ ក៏ប៉ុន្តែក្រោយៗមក ការប្រើប្រាស់ផាវទាំងនោះត្រូវបានហាមឃាត់ ដោយអាជ្ញាធររាជធានីភ្នំពេញ និងអាជ្ញាធរនៅតាមបណ្ដាខេត្តនានា បានចេញបំរាមមិនឱ្យផុតផាវនោះទេ។ សម្រាប់ទីក្រុងភ្នំពេញដែលបណ្តុំទៅដោយពលរដ្ឋខ្មែរសែស្រឡាយចិន ជាទីដែលមានការសែនច្រើនបំផុតនៅកម្ពុជានោះ អាជ្ញាធរក្រុងតែងតែបានចេញសេចក្តីជូនដំណឹងជិតមួយសប្តាហ៍មុនចូលឆ្នាំថ្មីប្រពៃណីចិន គឺហាមដាច់ខាតមិនឱ្យផុតផាវ ផុតកាំជ្រួច ឬបង្កសំឡេងផ្ទុះគ្រប់ប្រភេទនោះទេ និងក៏មានការចាត់វិធានការយ៉ាងម៉ឺងម៉ាត់មិនឱ្យមានការនាំផាវ កាំជ្រួច ឬជាតិផ្ទុះគ្រប់ប្រភេទតាមច្រកចេញចូល ដោយមានការត្រួតពិនិត្យដកហូតវត្ថុទាំងអស់ខាងលើ ដែលកំពុងលក់នៅក្នុងប្រទេសផងដែរ។

ទោះជាយ៉ាងនេះក្តី ការផុតផាវដែលបង្កសំឡេងផ្ទុះក្តួងក្តាំង និងមានការរំខាននោះ ត្រូវគេសម្គាល់ឃើញថានៅតែមានខ្វះៗនៅឡើយ ហើយកន្លងមកក៏ធ្លាប់មានកើតឡើងផងដែរ គឺការផុតធូបសែនព្រេន ឬផុតផាវនេះ បានបង្កឱ្យមានហានិភ័យនៃការឆាបឆេះដោយអគ្គិភ័យដែលបង្កឡើងនូវសោកនាដកម្មគួរឱ្យសង្វេគផងដែរ។

សូមបញ្ជាក់ថា សម្រាប់ឆ្នាំ២០២២ នេះ នៅថ្ងៃចន្ទទី៣១ ខែមករាខាងមុខនេះ ថ្ងៃដ៏មង្គលដែលជនជាតិចិននិងពលរដ្ឋខ្មែរសែស្រឡាយចិននៅក្នុងប្រទេសកម្ពុជាទន្ទឹងរង់ចាំនោះនឹងមកដល់ គឺថ្ងៃសែនចូលឆ្នាំថ្មីប្រពៃណីចិន ដែលជាថ្ងៃទទួលបាននូវមុខមាត់ថ្មី សំណាងថ្មី ជាថ្ងៃជម្រះចោលនូវរឿងរ៉ាវអពមង្គលពីឆ្នាំចាស់ និងទទួលយកនូវអ្វីៗដែលល្អនៅក្នុងឆ្នាំថ្មីផងដែរ។

*សូមជូនពរឆ្នាំថ្មី សូមមានសុខភាពល្អ មានសំណាងល្អ និងចៀសផុតពីអពមង្គលទាំងឡាយ!*

*កុងស៊ីហ្វាឆាយ!*

# ការអប់រំ និង សុខភាព

ដោយៈ បណ្ឌិត **សូ សុធីរ**

មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ

នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Email: sosuthy@mail.com

## ១-សញ្ញាណទូទៅនៃទំនាក់ទំនង ហេតុផល

គេបានទទួលស្គាល់តាំងពីសម័យលោកHippocrates ដែលថាលក្ខខណ្ឌសង្គមបង្កើតបែបបទជីវិតនៅក្នុងបរិស្ថានដែលមនុស្សអាចរស់នៅឬស្លាប់។ ប្រហែល២៣០០ឆ្នាំមកហើយ លោក Hippocrates, Horace Mann បានផ្តល់យោបល់ថា ការអប់រំអាចបម្រើជាឧបករណ៍ សម្រាប់ជួសជុលជំងឺសង្គម (Education might serve as a tool for repairing social ills)។ គាត់សង្កេតឃើញថា ការអប់រំជាសមនីយកម្មដ៏ធំធេង ដោយផ្តល់ឱ្យមនុស្សនូវចំណេះដឹង និងបំណិនបច្ចេកទេសចាំបាច់ ដើម្បីរស់នៅ។ នៅពេលដែលលោកMann បាននិយាយយោងទៅដល់ប្រាក់ចំណូល និងកិត្យានុភាពសង្គមនោះ ការអប់រំ បង្ហាញពីកម្លាំងសមភាពក្នុងសុខភាព។

| | |
|---|---|
| កើត | c. 460 BC Kos, Ancient Greece |
| ស្លាប់ | c. 370 BC (aged c. 90) Larissa, Ancient Greece |
| មុខរបរ | Physician គ្រូពេទ្យទូទៅ |
| សកករាជ | Classical Greece |
| គោរម្យងារ | The Father of Western Medicine |



រូបភាពទី១៖ ជីវប្រវត្តិសង្ខេប និងរូបភាពរបស់លោក Hippocrates

## ២- សុខភាព ការអប់រំ និងភាពក្រីក្រ

(Health, Education, and Poverty)

មុនពេលស្រាវជ្រាវរកយន្តការនីមួយៗ វាជារឿងសំខាន់ ដើម្បីពិចារណាលើកត្តាបរិស្ថាន ដល់កំណើនតិចតួចខាងសុខភាព និងការអប់រំៗ សុខភាពនិងការអប់រំទន់ខ្សោយ ជាបញ្ញត្តិដែលផ្សារភ្ជាប់គ្នា។ ឪពុកម្ដាយ ដែលមានកំណើតជាជនជាតិដើមដែលមិនមានសញ្ញាបត្រអប់រំខ្ពស់ទំនងជាមានកូន ដែលមានសុខភាពនិងការអប់រំទាបជាង និងមានហានិភ័យនៃការបោះបង់ការសិក្សានៅមធ្យមសិក្សា។ កត្តាដែលបានរួមចំណែកដល់អត្រាបោះបង់ការសិក្សាកម្រិតខ្ពស់ក្នុងចំណោមកុមារទាំងឡាយ ដូចជាការចូលរៀននៅសាលា ដែលបានផ្ដល់មូលនិធិតិចតួច មានលក្ខខណ្ឌការរំលោភបំពាន ជីវភាពរស់នៅខ្ពស់ និងកត្តាសុខភាព និងបរិស្ថាននៅច្រើនទៀត។

ឧទាហរណ៍: អន្តរាគមន៍ក្នុងការកាត់បន្ថយជាតិសំណ អាចជួយកែលម្អក្នុងសុខភាព និងការទទួលបានការអប់រំសម្រាប់កុមារ ប៉ុន្តែយើងគួរផ្ដោតលើចំណុចកម្មវិធីជាតិសំណ ជាភ្នាក់ងារហេតុ សម្រាប់កំណែលម្អដែលបានសង្កេតទាំងសុខភាព ទាំងការអប់រំ មិនគ្រាន់តែជាការអប់រំបន្ថែមដែលទទួលបានដោយកុមារក្នុងកម្មវិធីកាត់បន្ថយនោះទេ។ ម្យ៉ាងវិញទៀត ប្រសិនបើកុមារទទួលបានអន្តរាគមន៍អប់រំ ដែលនាំឱ្យគេបញ្ចប់ការសិក្សាពីមធ្យមសិក្សា ដែលបុគ្គលទំនងជាទទួលបានការងារដែលមានគុណភាព និងពេញចិត្តនឹងប្រយោជន៍នៃការធានារ៉ាប់រងខាងសុខភាព រចនាបថជីវិត មិនសូវមានជំងឺ ស្រ្តេស ផ្ទះស្នាក់នៅល្អៗ និងប្រយោជន៍សង្គមដែលនាំឱ្យមានសុខភាព។ នៅក្នុងករណីចុងក្រោយ វាជាការអប់រំ មិនមែនអន្តរាគមន៍ ដែលមានសារៈសំខាន់ដល់ផលិតកម្មសុខភាព។

## ៣-ភាពតានតឹងអារម្មណ៍ (Stress)




**Figure 1** Selected plausible pathways through which education works to improve health.

រូបភាពទី២៖ ដំណើរសកម្មភាពជម្រើសភាពទំនងតាមការងារអប់រំ ដើម្បីកែលម្អសុខភាព

ការរស់នៅដ៏លំបាក និងជំងឺបេះដូងបាននាំឱ្យមានការយល់ខុសច្រើន ដែលទាក់ទងគ្នានឹងការ អប់រំ ដែលនាំឱ្យមានបែបបទជីវិតដ៏តានតឹង។ តាមពិតទៅ មនុស្ស ដែលមានការអប់រំ និងទ្រព្យសម្បត្តិច្រើន មានភាពតានតឹងអារម្មណ៍ក្នុងជីវិតគេ។ ទោះជា

យ៉ាងនេះក្តី មនុស្សដែលមានសញ្ញាបត្រខ្ពស់ មានការងារធ្វើច្រើន មានការព្រួយបារម្ភ អំពីលុយកាក់ សុខភាព ពេលទំនេរ ឬបញ្ហា ជាមួយកូនចៅ កាន់តែតិចដែរ។ ការស្ទង់មតិ ស្ទ័យរបាយការណ៍ ក៏បានផ្តល់យោបល់ថា អ្នកទាំងឡាយដែលមានការអប់រំច្រើន មាន កំហឹងកម្រិត ការព្រួយចិត្ត ការឈឺ និងកត្តា ផ្សេងទៀត ដែលជ្រៀតជ្រែកគុណសម្បត្តិនៃ ជីវិតជាអត្តនោម័ត ជាងអ្នកទាំងឡាយដែល មានការអប់រំតិច។ ជាចុងបញ្ចប់ អ្នក ទាំងឡាយណា ដែលមានការអប់រំកាន់តែ ច្រើន ទំនងជាមានការងារល្អ សុភវិនិច្ឆ័យ គ្រប់គ្រងជីវិតកាន់តែខ្ពស់ និងកម្រិតការគាំ ទ្រពី សង្គមកាន់តែខ្ពស់ ដែលផ្សារភ្ជាប់សុខ ភាពស្ទ័យរបាយការណ៍ និងមុខងាររូបវន្ត កាន់តែខ្ពស់ជាងមុន។

ក្រៅពីជំងឺសម្ពាធឈាមខ្ពស់ ជំងឺទឹក នោមផ្អែម និងការបង្អាក់ដោយប្រព័ន្ធស៊ាំ ស្ត្រេសក៏អាចមានការខូចផ្នែកអុកស៊ីតកម្ម ដែលបង្កើនអត្រាកោសិកាដែលនាំឱ្យមនុស្ស ឆាប់ចាស់ និងលទ្ធភាពបង្កើនហានិភ័យនៃ ជំងឺមហារីក។ ការសិក្សាដំបូងនៅក្នុងវិស័យ នេះ ជ្រើសរើសយកប្រធានបទបំបាត់ស្ត្រេស និងប្រៀបធៀបវាទៅនឹងប្រធានបទជាមួយ កុមារដែលមានជំងឺធ្ងន់ ដើម្បីជានាអះអាង អវិកលចំពេងក្នុងជំងឺស្ត្រេស ដែលបាន បង្ហាញប្រាប់ដោយខ្លួនឯង។ បន្ទាប់មក គេក៏ បានសិក្សាសញ្ញាសម្គាល់នៃភាពចាស់នៃ កោសិកា ដែលគេហៅថា ធីឡូមៀ(Telom-ere) ចំពោះអំណះអំណាងថា តើមានការផ្តុំ គ្នារវាងស្ត្រេសដែលមាននៅក្នុងខ្លួន និងកោ សិកាដែលនាំឱ្យមានភាពចាស់ក្នុងប្រព័ន្ធ ស៊ាំ។ គេរកឃើញថា ប្រធានបទដែលមាន កម្រិតខ្ពស់នៃស្ត្រេស ដែលមាននៅក្នុងខ្លួន បង្ហាញការផ្លាស់ប្តូរក្រូម៉ូសូម ដែលស្របគ្នា នឹងជីវសាស្ត្រ ដែលទាក់ទងនឹងកម្រិតទាប ជាង។ មាតាបិតា ដែលមានជំងឺធ្ងន់ ទំនងជា រងការឈឺចាប់ពីជំងឺសេនេទិក និងទំនងជា ចាស់មុនអាយុ។

ការសិក្សាជាបន្តបន្ទាប់ បានជម្នះ ដែនកំណត់នេះ តាមការសិក្សាកូនក្មេះ ដែលមានកម្រិតអប់រំផ្សេងគ្នា។ ក្រុមអ្នក ស្រាវជ្រាវនេះ បានអះអាងពីប្រសិទ្ធភាពនៃ របកគំហើញដែលថា ស្ត្រេស បានបង្កើនឱ្យ មានកោសិកាវ័យចាស់។ អ្នកនិពន្ធទាំងនេះ រកឃើញថា ភាពចាស់បានកើនឡើងនៅក្នុង ចំណោមកូនក្មេះ ដែលក្រីក្រជាង និងមាន ការអប់រំតិចជាង ត្រូវបានពន្យល់ តាមអត្រា កំណើននៃការជក់បារីនិងភាពធាត់ អត្រា លំ ហាត់ប្រាណកាន់តែតិច។ នៅពេលដែលអ្នក និពន្ធទាំងនេះ មិនបានដោះស្រាយឱ្យបាន ពេញលេញនូវកត្តាហានិភ័យនៃស្ត្រេស ចិត្ត សង្គមនោះ ការសិក្សាបានលើកឡើងនូវលទ្ធ ភាពដែលថាកត្តាហានិភ័យខាងអាកប្ប កិរិយា និងស្ត្រេស មានការផ្សារភ្ជាប់គ្នា។

តាមការសិក្សាមួយចំនួនទៀត ប្រធានបទជាមួយនឹងទម្រង់ផ្សេងៗនៃជំងឺស្ត្រេស រួមបញ្ចូលទាំងជំងឺស្ត្រេសដែលកើតមានក្នុងការងារ ត្រូវបានគេរកឃើញថា មានកម្រិតខ្ពស់ជាងនៃការខូចខាត DNA និងកម្រិតសម្ពាធឈាមខ្ពស់ជាងនៃចំណុចសម្គាល់សម្រាប់ជំងឺមហារីក។ ការខូចខាតនេះ ត្រូវបានគេគិតថាកើតឡើង នៅពេលដែលមានចម្លើយតបនឹងជំងឺស្ត្រេសធ្ងន់ធ្ងរ បណ្តាលឱ្យមានការបញ្ចេញខាងសរីរៈនៃជាតុគីមីអុកស៊ីដកម្ម នៅក្នុងចរន្តឈាម។ ការវិភាគរងនៃទិន្នន័យទាំងនេះ ត្រូវបានគេឃើញថាបំណិនដោះស្រាយដោយជោគជ័យប្រកបដោយប្រសិទ្ធភាពពុទ្ធិ ផ្សារភ្ជាប់នឹងកម្រិតខូចខាតDNAទាបជាង។ ការទទួលបានការអប់រំកាន់តែកើនឡើង ផ្សារភ្ជាប់នឹងបំណិនដោះស្រាយដោយជោគជ័យប្រកបដោយប្រសិទ្ធភាព និងទំហំការងារសង្គមនោះ វាជាទំនងជាពិតដែលថា ការអប់រំអាចកាត់បន្ថយឧប្បត្តិហេតុនៃជំងឺ។

### ៤-ជំហរ ឬវណ្ណៈសង្គម (Social Standing)

ទ្រឹស្តីអត្តសញ្ញាណសង្គម អះអាងថា បុគ្គល ទំនងជាចាត់ថ្នាក់មនុស្សផ្សេងទៀតទៅតាមមូលដ្ឋានលក្ខណៈពិសេស ដូចជាការទទួលបានការអប់រំជាមធ្យោបាយនៃស្វ័យប្រៀបធៀប។ ភាពខុសគ្នាតាមជំហរទំនាក់ទំនងថា តើយោងទៅតាមទ្រព្យសម្បត្តិតិច ឬការអប់រំតិចអាចជាប្រភពនៃកំហឹងការច្រណែនឬក៏ស្ត្រេស។ ប្រវត្តិសាស្ត្ររបស់មនុស្សដ៏យូរអង្វែងនៃសង្គ្រាមបង្ហូរឈាមដែលបានប្រយុទ្ធគ្នា ដើម្បីវណ្ណៈសង្គម ដូចជា បដិវត្តន៍របស់ពួកខ្មែរក្រហម ផ្តល់យោបល់ថា សញ្ចេតនាអាចមានទាំងឥទ្ធិពលទាំងផលផ្ទាល់ទៅលើសុខភាព និង មរណភាព។ គេបានអះអាងថាការសម្តែងចេញក្នុងសម័យទំនើបនៃជំហរសង្គមទាបជាងរួមបញ្ចូលទាំងការរំខានខាងសរីរសាស្ត្រ ខាងក្នុងនិងបទឧក្រិដ្ឋ។ សម្មតិកម្មទាំងនេះ ត្រូវបានទាញចេញពីការសិក្សាខាងបរិស្ថានវិទ្យារួមបញ្ចូលគ្នា ដោយបានវាយតម្លៃទៅលើផលនៃអសមភាពប្រាក់ចំណូលទៅលើមរណភាព និងបទឧក្រិដ្ឋ ប៉ុន្តែ ឥឡូវនេះ គេបានគាំទ្រតាមមូលដ្ឋានដ៏រឹងមាំជាងនៃរង្វាស់ផលសម្រេច និងការរៀបចំការស្រាវជ្រាវ។

គំនិតដែលថា ស្ថានភាពសង្គមជះឥទ្ធិពលដល់សុខភាពបានបង្ហាញពន្លឺតាមការសិក្សាកម្មកររបស់រដ្ឋាភិបាលនៅប្រទេសអង់គ្លេស។ ការសិក្សាទាំងនេះ បានបង្ហាញថា ក្នុងចំណោមមនុស្សដែលមានការងារល្អនៅក្នុងផ្នែករដ្ឋាភិបាលតែមួយ និងសមភាពចំពោះការថែទាំសុខភាព វណ្ណៈខាងមុខរបរគឺនៅតែផ្សារភ្ជាប់នឹងភាពច្រាសគ្នានូវមរណភាពមុនកាលកំណត់។ គួរឱ្យភ្ញាក់ផ្អើលថែមទៀត សុខភាពទាំងនេះ មានវិសាលភាព

ចំពោះកម្មករ ដែលប្រើកម្លាំងកាយ សូម្បីតែអ្នកទាំងឡាយដែលមានការងារកម្រិតខ្ពស់ ក៏មានហានិភ័យនៃមរណភាពមុនកាលកំណត់ធំធេងជាងអ្នកទាំងឡាយ ដែលមានការងារប្រកបដោយកិត្យានុភាពបំផុត។ អត្រាស្រដៀងគ្នា គឺត្រូវបានគេរកឃើញជាបន្តបន្ទាប់សម្រាប់ប្រាក់ចំណូល និងការអប់រំ និង អត្រាភាពខុសគ្នាទាំងនេះ ត្រូវបានគេសង្កេតឃើញនៅក្នុងខុសគ្នាយ៉ាងទូលំទូលាយនៃបរិបទសេដ្ឋកិច្ច និងវប្បធម៌។ តាមពិតទៅ វាអាចធ្វើទៅបានដែលថា កិត្យានុភាពនៅក្នុងសង្គមកើតមាន តាមរយៈកម្រិតអប់រំ ជាកត្តាកំណត់ដ៏សំខាន់ថែមទៀតនៃអាយុសង្ឃឹមរស់ ជាងបំណិនដែលបានទទួលនៅក្នុងឆ្នាំនៃការអប់រំនីមួយៗ។

របកគំហើញទាំងនេះ ត្រូវបានគេបញ្ជាក់តាមការសិក្សាទៅលើសត្វ។ វានរជាតិដែលមានជំហរសង្គមទាប ត្រូវបានវាស់វែងតាមផ្នែកដោយទំហំនៃសត្វ និងអាកប្បកិរិយាគ្របដណ្តប់ មានកម្រិតខ្ពស់ជាងនៃកូឡេស្តេរ៉ូល និងកម្រិតខ្ពស់ជាងនៃទ្រនាប់ស្ត្រេស។ ពេលដែលភាពលុបរបស់បុរសត្រូវបានគេបំបាត់ចោលនោះ ការធ្វើតេស្តនៅមន្ទីរពិសោធរបស់មនុស្សនៅក្រោមបង្គាប់ត្រូវបានកែលម្អ។ ជាតិលុបដែលអំណាចត្រូវបានប្រដែងជាប្រចាំបង្ហាញនូវលទ្ធផលផ្ទុយ ប៉ុន្តែ ឋានានុក្រមវានរជាតិដែលមានលក្ខណៈមនុស្សបំផុត ដូចគ្នាជាខ្លាំងទៅនឹងឋានានុក្រមវានរជាតិមិនមែនជាមនុស្ស ដែលមានស្ថិរភាពជាងពពួកដែលមិនមានស្ថិរភាព។

ការអនុវត្តនៃការស្រាវជ្រាវជំហរសង្គម សម្រាប់គោលនយោបាយអប់រំ គឺមិនច្បាស់លាស់ទេ។ គ្រប់សង្គមមនុស្សទាំងអស់សុទ្ធតែមានឋានានុក្រម ហើយឋានានុក្រមខ្ពស់និងទាប អាចមានដែនកំណត់ប្រសើរតាមអ្នកទាំងឡាយ ដែលស្ថិតនៅក្នុងបរិស្ថានជិតៗ តាមចម្ងាយទំនាក់ទំនងសង្គមរវាងសមាជិកសង្គម ដែលមានបំផុតនិងក្របំផុត។

## ៥-កង្វះអន្តរកម្មស្និទ្ធស្នាលក្នុងសង្គម

(Social Deprivation)



រូបភាពទី៣៖ ការផ្លាស់ប្តូរនៃអាយុសង្ឃឹមរស់ជាមួយការទទួលបានការអប់រំក្នុងចំណោមមនុស្សប្រុស

កុមារដែលឪពុកម្តាយ មានការអប់រំតិចតួច និងក្រីក្រ ផលនៃកង្វះភាពស្និទ្ធស្នាលនៅក្នុងសង្គមបង្ហាញតាំងតែពីដើមដំបូងនៃជីវិត។ សិក្សាស្រាវជ្រាវរបស់Harlow (១៩៦២) ទៅលើចំណងស្និទ្ធស្នាលរបស់សត្វ បង្ហាញថា ភាពលំបាកខាងចិត្តសង្គមរបស់បុគ្គលអាចចាប់ផ្តើមជាមួយនឹងឪពុកម្តាយ ដែល

មានភាពក្រីក្រ។ ឧ.ស្វាដែលមានកង្វះភាពស្និទ្ធស្នាល ទំនងជាមានភាពអមិត្ត និងនាំទៅរកហានិភ័យជាង និងប្រើប្រាស់ជាតិអាកុលនៅក្នុងស្ថានភាពពិសោធ។ បញ្ហាទាំងនេះបង្ហាញថា ផលចម្លើយតបយ៉ាងជិតស្និទ្ធជាមួយស្វា ដែលចិញ្ចឹមដោយមេសិប្បនិម្មិតដែលមានរោម ចិញ្ចឹមដោយទឹកដោះគោ បានទទួលទទួលជោគជ័យជាងស្វាទាំងឡាយ ដែលត្រូវបានចិញ្ចឹមដោយមេដែលធ្វើពីលួសសំណាញ់។

បញ្ហាទាំងនេះ អាចចាប់ផ្តើមកើតមានឡើងនៅមុនពេលកើត។ បញ្ហាអាកប្បកិរិយា ត្រូវបានគេសង្កេតឃើញផងដែរ នៅក្នុងចំណោមកូនសត្វស្វា ដែលកើតមានស្រ្តេសតាមការបង្ខំខាងរាងកាយយ៉ាងយូរក្នុងអំឡុងពេលមានផ្ទៃពោះ។ ដូចគ្នាដែរ មនុស្សដែលត្រូវបានចិញ្ចឹមនៅក្នុងមណ្ឌលកុមារកំព្រាដែលមមាញឹកជាមួយនឹងចំណងទាក់ទងសង្គមតិចតួច ទំនងជាមានមិត្តភក្តិតិចតួច និងបង្ហាញនូវជំងឺសង្គមកាន់តែច្រើនឡើង។ Nicolae Ceausescu បានពឹងផ្អែកជាខ្លាំងលើកុមារកំព្រា ដើម្បីជួយប៉ូលិសសម្ងាត់រ៉ូម៉ានី (Romanian Secret Police) ពីព្រោះពួកគេមានទំនាក់ទំនងសង្គមតិចតួច ហើយគាត់បានវិនិច្ឆ័យយ៉ាងត្រឹមត្រូវថា ពួកគេនឹងអាចសម្លាប់មនុស្សដោយឥតមានវិប្បដិសារី។

តាំងពីកើតរហូតដល់ស្លាប់ ភាពក្រីក្រប្រឈមមុខទៅនឹងឧបសគ្គសង្គម និងចិត្តសាស្ត្រមួយចំនួនដែលជាញឹកញាប់រួមបញ្ចូលទាំងការធ្វេសប្រហែស ការរំលោភបំពាន ការមិនបានចូលរៀនសូត្រ ការធ្វើបាបគ្នា បញ្ចប់ការសិក្សាទាប ប្រាក់ឈ្នួលទាប ហើយជាញឹកញាប់ ការងាររចម្រុះ។ រឿងនេះមិនមែនជាសញ្ញាមជ្ឈដ្ឋានចិត្តសាស្ត្រសុខភាព ដែលកុមារ ឬមនុស្សចាស់អាចលូតលាស់ទេ។ កង្វះផ្នែកសេដ្ឋកិច្ច និងអប់រំ ដូចផ្នែកទាំងនេះ គឺផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងទ្រនាប់ជីវគីមីយ៉ាងច្រើននៅក្នុងវ័យកុមារភាព ដែលអាចនាំទៅដល់ជំងឺបេះដូង នាពេលក្រោយមកក្នុងជីវិត។ ព្រឹត្តិការណ៍កុមារ ភាពជាច្រើន ដូចជា ការប៉ះថ្នាំលាប ដែលមានជាតិសំណ និងការបំពាន គឺមិនអាចត្រឡប់ថយក្រោយមួយភាគធំ និងជះឥទ្ធិពលរួមគ្នាដល់ការអភិវឌ្ឍពុទ្ធិ និងសុខភាព។ ថ្នាំលាបដែលមានជាតិសំណត្រូវបានគេស្គាល់យូរមក ជាជាតិពុលដល់សរសៃប្រសាទ ហើយសូម្បីតែបរិមាណដ៏តិចតួចនៃជាតិសំណ ក៏បណ្តាលឱ្យមានការប៉ះពាល់ដល់អាយឃ្យូ(IQ)ដែរ។ ដូចគ្នានេះដែរ កុមារដែលរងការឈឺចាប់ ពីការបំពានខាងផ្នែកចិត្តរំភើប និងរាងកាយ ត្រូវបានគេបង្ហាញថា មានរចនាសម្ព័ន្ធខួរក្បាលតូចជាងកុមារដទៃទៀត។

វាអាចធ្វើទៅបាន ដែលថា បណ្តាញសង្គមខ្សោយជាង ជាសញ្ញាសម្រាប់កង្វះខាតអន្តរកម្ម នៅក្នុងវ័យកុមារភាព និងថា

ភាពភ័យរន្ធត់បែបនេះ គឺហេតុផលបឋម ដែលជាមូលហេតុបណ្ដាញសង្គមខ្សោយ ផ្សារភ្ជាប់ទៅនឹងសុខភាពខ្សោយ។ យ៉ាងណាក៏ដោយ វាទំនងជាថាបណ្ដាញសង្គមខ្សោយ គឺជាកត្តាហានិភ័យឯករាជ្យផងដែរ សម្រាប់សុខភាពខ្សោយ។

កង្វះអន្តរកម្មសង្គម និងបណ្ដុំសញ្ចេតនារបស់គេនៃកំហឹង និងអរិភាព ដូចជាកត្តាស្ត្រេសចិត្តសាស្ត្រផ្សេងទៀត គឺផ្សារភ្ជាប់គ្នាទៅនឹងអត្រាដ៏ខ្ពស់នៃជំងឺបេះដូង ជំងឺធ្ងង ជំងឺសួត និងជំងឺទឹកនោមផ្អែម។ ទោះជាមានការពិចារណាក៏ដោយ ហានិភ័យ និងកំហឹង អាចពន្យល់បានមួយផ្នែកដល់សីលធម៌ខ្ពស់ជាងមុន។ មនុស្សដែលមានការអប់រំទាប បង្កឱ្យមានស្នាមរបួសច្រើនជាសំខាន់ និងបង្ហាញថាមានការជក់បារី និងផឹកគ្រឿងស្រវឹងយ៉ាងច្រើន។ ទិន្នន័យ ដែលទទួលបានពីកម្មវិធីសាលាមត្តេយ្យPerry អះអាងថា អត្រានៃបទឧក្រិដ្ឋ របួស និងមរណភាព នៅក្នុងចំណោមអ្នកទាំងឡាយដែលទទួលបានការអប់រំតិច។

ការពិសោធព្រាវនៅក្នុងកម្មវិធីសាលាមត្តេយ្យPerry បង្ហាញថា កង្វះខាតអន្តរកម្មសង្គមដើមវ័យកុមារភាពទាំងនេះ មានខ្វះ មិនអាចត្រឡប់បានទេ ចំពោះអន្តរាគមន៍ដើមវ័យទាំងនេះ។ ត្រឹមវ័យប្រាំឆ្នាំមាន៦៧ភាគរយនៃកុមារនៅក្នុងក្រុមពិសោធ ដែលទាក់ទងទៅនឹង២៨%នៃកុមារ នៅក្នុងក្រុមគ្រប់គ្រង មានIQ ដែលបានវាស់វែងធំជាង៩០។ ត្រឹមអាយុ៤០ អ្នកទាំងឡាយដែលនៅក្នុងក្រុមអន្តរាគមន៍ គឺមាន១/៣ ទំនងជាត្រូវបានចាប់ខ្លួនចម្រុះ ហើយមានមួយភាគបី ទំនងជារកប្រាក់ចំណូលបានច្រើនជាង២ម៉ឺនដុល្លារក្នុងមួយឆ្នាំ។ ទាក់ទងនឹងអ្នកទាំងឡាយ ដែលមិនបានទទួលអន្តរាគមន៍ បុរសដែលបានទទួលអន្តរាគមន៍មានចំនួនប្រហែលជាពីរដង ទំនងជាចិញ្ចឹមកូនរបស់គេ ទំនងជាប្រើប្រាស់គ្រឿងញៀនតិចតួច ហើយទំនងជារាយការណ៍នូវទំនាក់ទំនងយ៉ាងពេញចិត្តជាមួយកូនរបស់គេ។ ហេតុដូច្នោះហើយ អន្តរាគមន៍ បានបង្ហាញនូវការផ្លាស់ប្ដូរអន្តរជំនាន់នៃជំងឺសង្គម។

ដូចគ្នានេះដែរ ការសាកល្បងអាយុដែលមិនបានរៀបចំព្រាវក្នុងចំណោមកុមារ ១៥៣៩ បង្ហាញថា ការចាប់ខ្លួននៅអាយុ២០ឆ្នាំ បានថយចុះនៅក្នុងចំណោមកុមារ ដែលបានរៀបចំចំពោះក្រុមអន្តរាគមន៍កុមារមុនចូលមត្តេយ្យសិក្សា មានទំនាក់ទំនងកុមារបានទទួលបានអន្តរាគមន៍ នៅមត្តេយ្យសិក្សាមានវិសាលភាពតិចជាង។ ពេលណាអត្រានៃជំងឺសង្គម ត្រូវបានកាត់បន្ថយតាមឧទាហរណ៍ទាំងពីរនេះ គេបានស្គាល់ថា តើប្រយោជន៍នៃអន្តរាគមន៍មត្តេយ្យសាលាទាំងនេះ បានពង្រីកវិសាលភាពដល់រង្វាស់សុខភាពផ្សេងទៀតដែរឬទេ។

ចុងបញ្ចប់ មានភស្តុតាងដែលថា អន្តរាគមន៍សង្គមផ្សេងទៀត ជួយកាត់បន្ថយ ដល់ជំងឺសង្គមផងដែរ។ តាមការពិសោធ បែបធម្មតាមួយ Castello *et al.*(២០០៣)បាន ពិនិត្យឃើញផលនៃការបើកកាស៊ីណូទៅ លើអត្រាជំងឺសង្គមនៅក្នុងជនជាតិអាម៉េរិក ដើមស្តីពីការអភិរក្ស។ ការសិក្សាអង្កេតបាន សិក្សាស្រាវជ្រាវទៅលើអត្រានៃការធ្វើរោគ វិនិច្ឆ័យសុខភាពផ្លូវចិត្តក្នុងចំណោមកុមារ ១៤២០នាក់នៅក្នុងសហគមន៍ យោងទៅតាម កម្រិតប្រាក់ចំណូលមុនពេល និងក្រោយពេល Casino ដែលបានបែងចែកឡើងវិញនូវបរិ មាណដ៏ច្រើននៃលុយកាក់ ចំពោះជនជាតិ គ្រួសារអាម៉េរិកដើម ដែលបានចុះបញ្ជី ដោយកុលសម្ព័ន្ធ។ ក្រោយពេលតាមដាន អស់រយៈពេល៨ឆ្នាំ លទ្ធផលដែលបង្ហាញអ ត្រានៃចរិយា និងជំងឺប្រឆាំង ដូចជា ការ បំពានខាងរាងកាយក្នុងចំណោមគ្រួសារ ដែលទើបមានថ្មីៗ បានធ្លាក់ទៅដល់កម្រិត ដែលគេមើលឃើញថាគ្រួសារអ្នកមានមុន ពេលមានអន្តរាគមន៍។ ម្យ៉ាងវិញទៀត អត្រា នៃចរិយា និងជំងឺប្រឆាំងជំទាស់ នៅតែមាន កម្រិតខ្ពស់ក្នុងចំណោមគ្រួសារទាំងឡាយ ដែលមិនទាន់ទទួលបានការចែកចាយប្រាក់ ចំណូល។

វិសាលភាពដែលថាការទទួលបាន ការអប់រំ ជួយកែលម្អបណ្តាញសង្គម និង កាត់បន្ថយជំងឺសង្គមនោះ គេនៅតែរំពឹងថា អន្តរាគមន៍ការអប់រំ ដើម្បីកែលម្អសុខភាព តាមរយៈចិត្តរំភើបអវិជ្ជមានដែលបានកាត់ បន្ថយ និងកត្តាហានិភ័យអាកប្បកិរិយាដែល បានកែលម្អ។

## ៦-កត្តាហានិភ័យអាកប្បកិរិយា

(Behavioral Risk Factors)

ផលរួមគ្នានៃការជក់បារី ការហូបចុក មិនគ្រប់គ្រាន់ និងកង្វះលំហាត់ប្រាណ ត្រូវ បានគេគិត ដើម្បីពន្យល់កន្លែងមួយចន្លោះ ១២% និង៥០%នៃបន្សំរវាងការទទួលបាន ការអប់រំ និងមរណភាព។ ប្រហែល ៤៤ភាគ រយនៃបុរសស្បែកស ដែលឥតមានសញ្ញាបត្រ សិក្សាជាន់ខ្ពស់ និង៣២ភាគរយនៃបុរស ស្បែកសដែលមានសញ្ញាបត្រសិក្សាជាន់ ខ្ពស់ បានរាយការណ៍ថា ជាអ្នកជក់បារី។ ថ្វីបើភាពលើសលុបនៃការជក់បារី មាន កម្រិតទាបក្នុងចំណោមជនជាតិអេស្ប៉ាញ ជនជាតិអាម៉េរិកស្បែកខ្មៅ និងស្ត្រីនោះ ភាគ រយនៃការកាត់បន្ថយការជក់បារី មានភាព ប្រហែលនឹងចំនួនប្រជាជនទាំងនេះក្នុង ចំណោមអ្នកទាំងឡាយដែលមានសញ្ញាបត្រ សិក្សាជាន់ខ្ពស់ ដែលទាក់ទងទៅនឹងអ្នក ទាំងឡាយដែលមិនមានសញ្ញាបត្រសិក្សា ជាន់ខ្ពស់។

គេបានគូសបញ្ជាក់ថា មនុស្សភាគ ច្រើន ដោយមិននិយាយពីកម្រិតនៃការអប់រំ បានដឹងថាការជក់បារី ការផឹកគ្រឿងស្រវឹង

និងការហូបចុកអាហារ ដែលមានខ្លាញ់ច្រើន គឺមិនមានសុខភាពទេ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការកាត់បន្ថយការជឿតាមព្រេងវាសនា ការអប់រំ អាចបង្ហាញជារួមចំពោះព័ត៌ មាន ដែលបង្ការឱ្យមានសុខភាពត្រូវធ្វើជារឿងធម្មតា។ ការអប់រំ អាចជួយកែលម្អការវាយតម្លៃព័ត៌មានបានប្រសើរ។ មនុស្សទំនងជាហូបអាហារដែលមានសុខភាព ប្រសិនបើពួកគេខ្លាញ់ដែលជ្រាប និងមានជាតិកូឡេស្តេរ៉ូល ធ្វើឱ្យស្ទះសរសៃឈាមក្រហម និងហ្នឹងអាចយល់ដឹងនូវសរសៃឈាមក្រហមទាំងនេះជំនួសឱ្យជំនួសការមានសញ្ញាណអរូបី និងមានភាពមិនច្បាស់លាស់ ដែលសារជាតុទាំងនេះ មានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ មនុស្សដែលមានការអប់រំល្អប្រសើរ អាចយល់ដឹងពីតុល្យភាពព័ត៌មានសុខភាព ប្រឆាំងនឹងសារពើឧស្សាហកម្មជាតិស្រវឹង ថ្នាំជក់ និងអាហារឆ្អិនស្រាប់។

នៅពេលដែលការទទួលបានការអប់រំ ជួយឱ្យមានកំណើនប្រាក់ចំណូលនោះវាក៏ជួយឱ្យមានផលជាវិជ្ជមាន ទៅលើអាកប្បកិរិយាសុខភាព តាមរយៈចល័តភាពកាន់តែខ្ពស់ទៅលើអ្នកជិតខាងអាហារដោយសុខភាព អាចរកបាននៅតាមហាងទំនិញ និងការប្រើប្រាស់ មានលក្ខណៈតាមនិយាម។ ដោយមានអត្រាបទឧក្រិដ្ឋកាន់តែទាប អ្នកជិតខាងដែលមានទ្រព្យសម្បត្តិច្រើនជាងមុន ក៏ផ្តល់ឱកាសសម្រាប់ការហាត់ប្រាណផងដែរ។ ការសិក្សានៅទីកន្លែងចម្រុះ ដែលមានការគ្រប់គ្រងព្រាវ និងមានចំនួនច្រើន វាយតម្លៃដល់សុខភាព បទឧក្រិដ្ឋ និងផលសង្គមផ្សេងទៀតនៃអ្នកជានា សម្រាប់ការស្នាក់នៅ ដែលអនុញ្ញាតឱ្យអ្នកទទួល អាចផ្លាស់ចេញពីទីលំនៅ ដែលមានចំណូលទាប។ ៥ឆ្នាំក្រោយពេលការសិក្សាដោយព្រាវ អ្នកទាំងឡាយ ដែលទទួលបានបណ្ណជានា មានការកាត់បន្ថយភាពជាត់ និងកំណែលំអក្នុងការរស់នៅវែងសុខភាពផ្លូវចិត្ត ដែលទាក់ទងអ្នកទាំងឡាយ ដែលមិនបានទទួលបណ្ណបានជានា។

ជាចុងបញ្ចប់ការសិក្សាទៅលើទស្សនវិស័យនៃទំនាក់ទំនង ដែលថាមនុស្សបង្កើតជីវិតរបស់ពួកគេ បានផ្តល់យោបល់ថា ការតមអាហារ ដែលមានកំណែលំអ និងលំហាត់ប្រាណ ព្រមទាំងការជក់បារីដែលបានកាត់បន្ថយ និងអត្រាភាពជាត់ គឺមានការរីកចម្រើន។ នោះ គឺថានៅពេលដែលបុគ្គលម្នាក់អភិវឌ្ឍទំនាក់ទំនងជាមួយដៃគូដែលមិនជក់បារី ឬមិនផឹកសុរា គេទំនងជាមិនសូវជក់បារី ឬផឹកសុរានោះដែរ។ ដូច្នោះហើយ ផលនៃការទទួលបានការអប់រំ ទៅលើកត្តាហានិភ័យនៃអាកប្បកិរិយា បង្ហាញឡើងនូវភាពអាចផ្លាស់ប្តូរបាន ចំពោះមិត្តភក្តិដែលមានការអប់រំតិច។

## ៧-កត្តាហានិភ័យខាងសេនេទិក

( Genetic Risk Factors )

លក្ខណៈពិសេសនៃបុគ្គល ត្រូវបាន កំណត់តាមបន្សំនៃសមត្ថភាពខាងសែន និង ឥទ្ធិពលនៃបរិស្ថាន។ សមត្ថភាពសេនេទិក ដែលជះឥទ្ធិពលដល់អាកប្បកិរិយាសុខភាព អាចជះឥទ្ធិពលដល់ភាពជោគជ័យផងដែរ នៅឯសាលារៀន។ ជាឧទាហរណ៍ ការសិក្សា ទៅលើកូនភ្លោះ ផ្តល់យោបល់ថា សមត្ថភាព មនុស្ស ដើម្បីដោះស្រាយជាមួយនឹងស្ត្រេស ត្រូវបានកំណត់ជាផ្នែក តាមកត្តាសេនេទិក។ ជាងនេះទៀត លទ្ធភាពនៃព្រឹត្តិការណ៍ជីវិត ដែលទទួលបាន ថាជាស្ត្រេស នៅក្នុងកន្លែង ដំបូង មានការផ្សារភ្ជាប់គ្នាមួយផ្នែកទៅនឹង កត្តាសេនេទិក។

បរិស្ថាន ក៏ជះឥទ្ធិពលដល់តួនាទី ផងដែរ។ នៅពេលដែលកូនភ្លោះ ត្រូវបាន ចិញ្ចឹមតាមផ្នែកបង្ហាញភាពស្របគ្នា តាម រង្វាស់នៃIQ និងប្រាក់ចំណូលនោះ កូនភ្លោះ ដែលមានកត្តាសេដ្ឋកិច្ចសង្គមលំបាក ត្រូវ បានគេរកឃើញថា មានហានិភ័យខាងជំងឺ បេះដូង ជាងកូនភ្លោះដែលមិនបានចិញ្ចឹម នៅក្នុងភាពក្រខ្សត់។ ការសិក្សាស្រាវជ្រាវ ទៅលើកូនភ្លោះ បានផ្តល់យោបល់យ៉ាងរឹង មាំថា រង្វាស់នៃស្ថានភាពសុខភាព និងសម ត្ថភាពពុទ្ធិ គឺត្រូវបានកំណត់ដោយបរិស្ថាន មួយផ្នែកធំ។ ជាអកុសល ការសិក្សាទាំងនេះ មិនអាចបង្កើតនូវការប៉ាន់ប្រមាណដែលគួរ ឲ្យទុកចិត្តនៃការរួមចំណែកនៃសែនកត្តា បរិស្ថាន ឬក៏អន្តរកម្មនៃកត្តាទាំងពីរនេះទេ។

ទី១ កូនភ្លោះ ដែលចិញ្ចឹមដោយ ឡែកពីគ្នា នៅក្នុងបរិស្ថានដូចគ្នា នៅក្នុង ស្បូន ហើយជួនកាលបរិស្ថានតែមួយ នៅ ក្នុងវ័យកុមារភាព ដែលទាំងពីរនាក់ គឺជាការ ទស្សន៍ទាយដ៏រឹងមាំនៃធម្មចរិយាមនុស្ស ចាស់ តាមស្ថានភាពសេដ្ឋកិច្ចសង្គម (SES) និងជំងឺសង្គម។ ព្រោះហេតុដូច្នោះហើយ បើ ប្រៀបធៀបកូនភ្លោះដែលជាមនុស្សចាស់ ត្រូវបានចិញ្ចឹមដោយឡែកនោះ ជារឿង លំបាក ដើម្បីដោះស្រាយផលសេនេទិក ពី ផលនៃបរិស្ថាន នៅក្នុងដើមវ័យកុមារភាព។ ជាឧទាហរណ៍ ជាតិអាកុលនៅក្នុងផ្ទៃហើយ និងជាតិសំណក្នុងថ្នាំលាប ជាកត្តាហានិភ័យ សម្រាប់ពន្យឺតការអភិវឌ្ឍ ហើយនិងផ្សារ ភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការទទួលបាន ការអប់រំរបស់ឪពុកម្តាយ។

ទី២ ស្ទើរតែទាំងអស់នៃការរួមចំណែក ខាងសេនេទិក ដែលគួរឱ្យទុកចិត្តបាន ចំពោះការអប់រំសុខភាព ត្រូវបានគេកំណត់ ថា ចំណែកខាងសេនេទិកដ៏ច្រើន។ ការ បង្ហាញនៃសែនទាំងនេះ បានទទួលឥទ្ធិពល យ៉ាងខ្ពស់តាមកត្តាបរិស្ថាន នៅក្នុងបែបបទ នៃចម្លើយតបនៅកម្រិតនេះ។ ចូរពិចារណា លើការពិសោធសម្មតិកម្ម ដែលក្នុងនោះ ក្រុមនៃគក៏មានលក្ខណៈព្រាវៗ ចំពោះ លក្ខខណ្ឌប្រកបដោយឧត្តមគតិ និងក្រុម

ម្ដាយ មានលក្ខណៈក្រីក្រ ចំពោះកុមារភាព ដែលមានភាពឃោរឃៅ។ ក្នុងចំណោម កុមារដែលមានឪពុកម្ដាយគួរជាទីស្រឡាញ់ និងការចិញ្ចឹមប្រកបដោយឧត្ដមគតិនោះ សេនេទិកនឹងដើរតួនាទី ជាចម្បងក្នុងការ កំណត់ថាតើកុមារណាមួយ ទទួលបានលទ្ធផល ល្អ នៅសាលារៀន និងនៅបានយូរអង្វែង និងមានភាពរុងរឿង។ ក្នុងចំណោមកុមារ ដែលឪពុកម្ដាយ និងមិត្តភក្ដិ មានចរិតបំពាន កុមារ ចូលចិត្តគ្រឿងញៀន អាហារមិនមាន សុខភាព រងជាតិពុលសំណ និងរៀននៅសា លាមិនល្អនោះ កម្រិតនៃការបង្ហាញចំពោះ លក្ខខណ្ឌបរិស្ថានវិជ្ជមាន នឹងជាកត្តាកំណត់ ចម្បងនៃអាយុវែង និងភាពរុងរឿង។ នៅ ក្នុងស្ថានភាពខាងក្រោយនេះ សេនេទិក នឹងដើរតួនាទីតិចតួចក្នុងការពន្យល់ការ ទទួលបានការអប់រំ។

នៅក្នុងការសិក្សាទៅលើកូនភ្លោះ បែបនវានុវត្តន៍ Turkheimer *et al.* (2003) បាន កំណត់តេស្ដ គម្រោងសម្មតិកម្ម ដែលប្រើ ប្រាស់ការវិភាគតាមជីវមាត្រ។ គេបានសិក្សា ទៅលើការរួមចំណែកនៃ

-សេនេទិក

-បរិស្ថានរួម

-បរិស្ថានដោយឡែកលើIQ ដែលត្រូវ បានវាស់វែងដោយមាត្រដ្ឋានបញ្ញារបស់ Wechsler សម្រាប់កុមារ ដែលមានអាយុ៧ ឆ្នាំ។គំរូរបស់គេបានសិក្សាអន្តរកម្មនៃលក្ខណៈ ពិសេសទាំង៣នេះ និងស្ថានភាពសេដ្ឋកិច្ច សង្គម ដោយប្រើប្រាស់ទិន្នន័យជាតិ។ ការ សិក្សាទស្សនវិស័យនេះ រាប់បញ្ចូលទាំងស្ត្រី មានផ្ទៃពោះចំនួន៤៨,១៩៧នាក់ និងកុមារ ចំនួន៥៩,៣៩៧នាក់។ រង្វាស់ស្ថានភាព សេដ្ឋកិច្ចសង្គម ផ្អែកលើរង្វាស់ផ្សំគ្នានៃការ ទទួលបានការអប់រំ មុខរបរ និងប្រាក់ចំណូល។ បំណងរបស់គេ គឺត្រូវវាស់វែង អន្តរកម្មរវាង សេណូទីប (Genotype) និងលក្ខខណ្ឌបរិស្ថាន។ ពួកគេបានពន្យល់លទ្ធភាពថា SES ត្រូវបាន កំណត់ខាងសេនេទិក តាមការរាប់បញ្ចូល ផលចម្បងអថេរមធ្យមនៅក្នុងគំរូរបស់គេ។ ពួកគេបានរកឃើញថា ក្នុងចំណោមគ្រួសារ ក្រីក្រ IQ ត្រូវបានកំណត់ស្ទើរតែទាំងស្រុង តាមបរិស្ថាននៅក្នុងវ័យកុមារភាព។ ម្យ៉ាង វិញទៀត នៅក្នុងចំណោមគ្រួសារអ្នកមាន ទ្រព្យសម្បត្តិ សែនត្រូវបានកំណត់ពីការ ទស្សន៍ទាយទាំងស្រុងនៃIQ។ តាមពិតទៅ សេចសេចក្ដីសន្និដ្ឋាននៃការសិក្សានេះអាស្រ័យ ទៅលើការសន្មតដែលថាស្ថានភាពសេដ្ឋកិច្ច សង្គម គឺជារង្វាស់តំណាងគ្រប់គ្រាន់នៃភាព ឃោរឃៅទល់នឹងបរិហានកុមារភាពប្រកប ដោយឧត្ដមគតិ។

ការសិក្សាមួយទៀតបែបបង្ខំ ទៅលើ កូនចិញ្ចឹមជនជាតិកូរ៉េ ដែលមានលក្ខណៈ ព្រាវៗ ចំពោះគ្រួសារដែលមានស្ថានភាព សេដ្ឋកិច្ចសង្គមផ្សេងៗគ្នា ត្រូវបានសិក្សានា ពេលចុងក្រោយនៃជីវិត។ ការអប់រំ និងលទ្ធផល

សុខភាព ត្រូវបានប្រៀបធៀបទៅនឹងមាតាបិតាថ្មី និងកូនៗរបស់គេ។ ជាក់ស្តែង កុមារកូរ៉េ ត្រូវបានចិញ្ចឹមនៅក្នុងគ្រួសារមិនមែនអាស៊ី ទំនងជាស្ថិតក្នុងស្ថានភាពប្រសើរនៅក្នុងសង្គម និងប្រើប្រាស់ឥទ្ធិពលលើការអភិវឌ្ឍ។ យ៉ាងណាក៏ដោយ កូនចិញ្ចឹម ដែលមាតាបិតាមានការអប់រំប្រសើរ ពិតជាទទួលបានលទ្ធផលល្អប្រសើរនៅសាលារៀន បន្តការសិក្សាទៅមុខ និងមានសុខភាពល្អប្រសើរតាមការរស់នៅជាងកូនចិញ្ចឹមដែលមានមាតាបិតាដែលមានការអប់រំតិច។ ជាងនេះទៀត កូនចិញ្ចឹមដែលល្អ ទំនងជាមិនជក់បារី មិនផឹកសុរា ដោយបានផ្តល់ភស្តុតាងយ៉ាងរឹងមាំថា កត្តាហានិភ័យខាងអាកប្បកិរិយានឹងមិនមានបន្តមរតកទៀតទេ។

ជារួមមក ទាំងកត្តាសែននិងកត្តាបរិស្ថានជះឥទ្ធិពលដល់លក្ខណៈពិសេសនៃបុគ្គលដែលមានសារៈសំខាន់ក្នុងការកំណត់ទាំងស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពសុខភាពនាពេលក្រោយនៅក្នុងជីវិត។ បញ្ហារៀបចំការសិក្សាបង្កើតឱ្យមានភាពលំបាកនៅក្នុងការកំណត់គុណភាពផលនៃសែនចំពោះសុខភាព។ ទោះជាយ៉ាងណាក៏ដោយ ទាំងភស្តុតាងបែបវិទ្យាសាស្ត្រ នៅពេលថ្មីៗនេះ និងតក្កភាពផ្តល់យោបល់ថា កត្តាសែននឹងជាកត្តាកំណត់ដ៏សំខាន់នៃសុខភាពនៅក្នុងចំណោមកុមារទាំងឡាយ និងជាកត្តាកំណត់ដ៏ទន់ខ្សោយថែមទៀតនៅក្នុងចំណោមកុមារក្រីក្រ។ ព្រោះហេតុដូច្នោះហើយ សមត្ថភាពបញ្ញា នឹងទំនងជាមានសុទិដ្ឋិនិយម នៅពេលដែលអន្តរាគមន៍អប់រំផ្តោតទៅលើគ្រួសារដែលមានប្រាក់ចំណូលទាបនិងសាលារៀន ស្ថិតនៅក្នុងសហគមន៍ដែលមានប្រាក់ចំណូលទាប។ ជាក់ស្តែង ដើម្បីធ្វើឱ្យមានកម្រិតអប្បបរមាដល់អថេរខាងបរិស្ថាន វារឿងសំខាន់ផងដែរ ដើម្បីធ្វើឱ្យមានសុទិដ្ឋិនិយមនូវទិដ្ឋភាពផ្សេងទៀតនៃកុមារភាព និងលក្ខខណ្ឌបរិស្ថានមនុស្សចាស់ ដូចជាការមានប្រកប ដោយសុខភាព ការស្នាក់នៅក៏ល្អ ដោយសុវត្ថិភាព និងការថែទាំខាងវេជ្ជសាស្ត្រ។

## ៨-ការធានារ៉ាប់រងសុខភាព (Health Insurance)

តាមលក្ខណៈពិសេសបរិស្ថានកុមារភាព ការថែទាំខាងវេជ្ជសាស្ត្រសម្រាប់កុមារ ទទួលបាននូវការយកចិត្តទុក ដូចជាអន្តរាគមន៍អប់រំដែរ។ គេត្រូវមានផែនការការធានារ៉ាប់រងខាងសុខភាព ដែលត្រូវបានទាក់ទាញតាមការយកចិត្តទុកដាក់នៅជុំវិញសុខភាពកុមារ។ វាច្បាស់លាស់ណាស់ ដែលថាគ្រួសារដោយមានគំរូការអប់រំតិចតួច ខ្វះការធានារ៉ាប់រងខាងសុខភាព និងការឈឺចាប់មកពីប្រាក់ចំណូលតិចតួច មានភស្តុតាងកំណត់ ដែលបង្ហាញថា ការរ៉ាប់រងសុខភាពត្រូវបានផ្សារភ្ជាប់ទៅនឹងស្ថានភាពសុខភាព

ដែលបានកែលំអ។ ក្នុងចំណោមអ្នកដែលមានអាយុ១៨-៦៤ឆ្នាំ មនុស្ស៧.៣ភាគរយ ដែលមានសញ្ញាបត្របរិញ្ញាបត្រ មានកង្វះការធានារ៉ាប់រងសុខភាព បើប្រៀបធៀបទៅនឹងមនុស្ស២៧.៦% ដែលឥតមានសញ្ញាបត្រសិក្សាជាន់ខ្ពស់។ អត្រាទាបនៃការធានារ៉ាប់រងក្នុងចំណោមអ្នកទាំងឡាយ ដែលមានការអប់រំតិច បានសន្មតទៅនឹងកត្តាដែលថា មនុស្សដែលមានការអប់រំតិចតួច ទំនងជាមានការងារដែលមានគុណភាពទាប ដែលជាទូទៅមិនបានផ្តល់ការធានារ៉ាប់រងខាងសុខភាព។ ការទទួលបានការថែទាំខាងវេជ្ជសាស្ត្រ ជួយបង្កើនឱ្យមានការទទួលបានខាងការប្រើឱសថ និងការព្យាបាល ត្រូវបានគេស្គាល់ដើម្បីកាត់បន្ថយរោគប្បមាណ និងមរណភាព។ នៅក្នុងចំណោមជំងឺជាក់ស្តែង នៅក្នុងភាពល្បឿននៃការអប់រំ ការប្រើឱសថដែលជួយកាត់បន្ថយជាតិកូលេស្តេរ៉ុលសម្ពាធឈាមនិងជំងឺទឹកនោមផ្អែមអាចជារឿងសំខាន់។ ភាពប្រសើរបំផុតនៃប្រសិទ្ធភាពនៃការធានារ៉ាប់រងសុខភាពមកដល់បច្ចុប្បន្ន ផ្តល់យោបល់ថាការធានារ៉ាប់រងធ្វើឱ្យប្រសើរនូវសុខភាព តាមរយៈបែបបទទាំងនេះ។

ក្នុងពិសោធន៍ការធានារ៉ាប់រងសុខភាពឆ្នាំ១៩៨២ មនុស្ស៣,៩៥៨នាក់ ដែលមានសុខភាពល្អ តែគ្មានការធានារ៉ាប់រង ត្រូវបានចាត់តាំងដោយចៃដន្យ ដើម្បីទទួលបាននូវគោលនយោបាយធានារ៉ាប់ រងសុខភាព ឬគោលនយោបាយ ដែលត្រូវការការចូលរួមវិភាគទានផ្នែកហិរញ្ញវត្ថុរបស់អ្នកជំងឺមុនពេលពួកគេអាចទទួលបានការថែទាំ (Brook *et al.*,1983)។ មនុស្សទាំងនោះ ត្រូវបានចាត់ចែងក្នុងផែនការធានារ៉ាប់រងរបស់ពួកគេ រយៈពេល៣ឬ៥ឆ្នាំ ហើយបន្ទាប់មកវាយតម្លៃសម្រាប់លទ្ធផលសុខភាពរួមទាំងមរណភាពផងដែរ។ អ្នកនិពន្ធទាំងនេះ បានរកឃើញថា ការចូលរួមចំណែករបស់អ្នកជំងឺចាំបាច់ កាត់បន្ថយការប្រើប្រាស់សុខភាព ការថែទាំសុខភាព ទាក់ទងនឹងអ្នកដែលមិនមានតម្រូវការបែបនេះ ប៉ុន្តែឧបសគ្គ ចំពោះការថែទាំបានបង្កើតបានតែ១០% នៃហានិភ័យនៃការស្លាប់ក្នុងចំណោមអ្នកដែលមានហានិភ័យខ្ពស់ ដែលមានជំងឺលើសឈាម។ មិនមានការផ្លាស់ប្តូរ ត្រូវបានគេរកឃើញនៅក្នុងវិធានការសុខភាពផ្សេងទៀត ក្រៅពីភាពប្រសើរឡើងនៃចក្ខុវិស័យតាមរយៈកញ្ចក់ត្រឹមត្រូវ។ ការស្រាវជ្រាវនេះ ត្រូវបានចុះកាលបរិច្ឆេទមួយចំនួន ហើយក្នុងរយៈពេល២៤ឆ្នាំកន្លងមកនេះ ថ្នាំជាច្រើនប្រភេទដែលការពារជំងឺបេះដូង ការឆ្លង និងជំងឺមហារីក បានកើតមាន (ឧទាហរណ៍ថ្នាំ Statins វ៉ាក់សាំង និងបច្ចេកវិទ្យាបញ្ឈប់ការជក់បារីរៀងៗខ្លួន)។ ថ្នាំទាំងនេះ ថ្លៃណាស់ស្ទើរតែ

ត្រូវបានប្រើប្រាស់ដោយអ្នកដែលមានជានារ៉ាប់រងសុខភាព។ ការវិភាគដែលទាក់ទងគ្នាថ្មីៗ បង្ហាញពីការកាត់បន្ថយ២៥-៦៧% នៃអត្រាមរណភាពក្នុងចំណោមអ្នក ដែលមិនបានជានារ៉ាប់រង (Muennig *et al*, ២០០៥)។ ទោះយ៉ាងណា ការកាត់បន្ថយអត្រាមរណភាពនេះ អាចត្រូវបានពន្យល់ដោយភាពជាគំរូឬកត្តាដទៃទៀត ដែលទាក់ទងនឹងការជានារ៉ាប់រងដូចជាការការពារសេដ្ឋកិច្ច និងការគិតដែលជានារ៉ាប់រងសុខភាពជាជាងការទាក់ទងនឹងការទទួលបានការយកចិត្តទុកដាក់ខាងវេជ្ជសាស្ត្រ។

ដោយផ្តល់នូវបែបបទបង្ការ ដូចជាថ្នាំប្រឆាំងនឹងជំងឺទឹកនោមផ្អែម មើលទៅហាក់ដូចជាមានបញ្ហាបំផុត ហើយថាបែបបទទាំងនេះ ជួយកាត់បន្ថយអត្រាកើតជំងឺនៅក្នុងជម្រែអប់រំ។ ការជានារ៉ាប់រងសុខភាពហាក់ដូចជាការបូកសរុបជាកលាក់ សម្រាប់អថេរពន្យល់នៅក្នុងជម្រកសុខភាព។ បើមានភាពត្រឹមត្រូវ ការថយចុះ២៥-៦៦% នៃអត្រាមរណភាពនេះ អាចមានរយៈពេលពី៣-៩ ខែនៃអាយុខុសគ្នារវាងអាយុ៦-៩ ឆ្នាំរវាងអាយុដែលមាន និងគ្មានសញ្ញាបត្រមធ្យមសិក្សា។ ទោះយ៉ាងណា គួរកត់សម្គាល់ថាផលប៉ះពាល់នៃការទទួលបានការអប់រំលើការយល់ដឹង គួរតែរួមបញ្ចូលគ្នាជាមួយនឹងផលការជានារ៉ាប់រងសុខភាព បន្ថែមពីលើការធ្វើឱ្យប្រសើរឡើងនូវការទទួលបានថ្នាំ មនុស្សដែលមានចំណេះដឹងកាន់តែច្រើន ក៏ទំនងជាគោរពតាមកម្រិតដែលបានកំណត់ និងចន្លោះពេល។

សរុបសេចក្តីមក នៅតាមបណ្តាប្រទេសឧស្សាហកម្ម ការថែទាំសុខភាពហាក់ដូចជាដើរតួតិចតួចតែគួរឱ្យកត់សម្គាល់នៅក្នុងការកាត់បន្ថយភាពខុសគ្នានៃសុខភាពដោយស្ថានភាពសេដ្ឋកិច្ចសង្គម(SES)។ ខណៈពេលដែលវិសមភាពសុខភាពដោយការទទួលបានការអប់រំ មានទំហំតូចជាងនៅក្នុងប្រទេសដែលផ្តល់ការជានារ៉ាប់រងសុខភាព ប្រទេសទាំងនេះ ក៏មានទំនោរ ផ្តល់សេវាកម្មសង្គមបន្ថែមទៀត ដូចជាការមើលថែទាំកូន និងការឈប់សម្រាករបស់មាតាបិតា ដែលធ្វើឱ្យពិបាកក្នុងការបញ្ឈប់ឥទ្ធិពលនៃការជានារ៉ាប់រងសុខភាព ពីផលប៉ះពាល់នៃកម្មវិធីសង្គមដទៃទៀត លើការកាត់បន្ថយភាពខុសគ្នានៃបញ្ហាសុខភាព។ លើសពីនេះ ទៅទៀតការបង្កើនការជានារ៉ាប់រងសុខភាព នឹងត្រូវចំណាយច្រើន គួរឱ្យកត់សម្គាល់ជាងការអនុវត្តនូវអន្តរាគមន៍អប់រំប្រកបដោយ

ប្រសិទ្ធភាពដូចជាទំហំថ្នាក់តូច (Muennig and Woolf, 2007)។

ទោះជាយ៉ាងណាក៏ដោយ ការធានារ៉ាប់រងសុខភាពជាសកល អាចជាវិធីសាស្ត្រគោលនយោបាយដ៏មានសក្តានុពលមួយក្នុងការដោះស្រាយជម្រាលអប់រំសុខភាព។ របកគំហើញនៃការពិសោធធានារ៉ាប់រងសុខភាព ការថែរក្សាសុខភាពសកល អាចបង្ហាញថាជាអន្តរាគមន៍អប់រំប្រកបដោយប្រសិទ្ធភាព។ យ៉ាងណាមិញ វាពិបាកសម្រាប់កុមារក្នុងការរៀនប្រសិនបើពួកគេឈឺ។ លើសពីនេះទៅទៀត នៅពេលដែលសុខភាព អាចធ្វើឱ្យប្រសើរឡើង ដល់ការសម្រេចបានការអប់រំការទទួលបានការអប់រំកាន់តែប្រសើរឡើង អាចធ្វើឱ្យការប្រើប្រាស់សុខភាពប្រសើរឡើងក្នុងចំណោមអ្នក ដែលត្រូវបានធានារ៉ាប់រងរួចហើយ។ សមត្ថភាពយល់ដឹងកាន់តែប្រសើរឡើង សូម្បីតែក្នុងចំណោមអ្នកដែលមានការថែទាំសុខភាពក៏ដោយចំណេះដឹងអំពីភាព អាចរកបាននៃការធ្វើតេស្តគឺអាចព្យាករណ៍ពីការប្រើប្រាស់នៃការធ្វើតេស្តបែបនេះ។ អ្នកដែលមានការអប់រំច្រើនក៏ទំនងជាត្រូវនឹងថ្នាំរបស់ពួកគេដែរហើយអ្នកផ្សេងទៀតគ្រប់គ្រងជំងឺរបស់ពួកគេបានល្អជាងអ្នកដែលមានការអប់រំទាប។ បន្ថែមពីលើការបង្កើនការប្រើ និងការប្រើប្រាស់បច្ចេកវិទ្យាសុខភាពឱ្យបានត្រឹមត្រូវ ការយល់ដឹងកាន់តែប្រសើរឡើង ក៏អាចជួយកាត់បន្ថយរាល់ថ្ងៃនូវកំហុស ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចររថយន្ត ឬគ្រួសារ។ បន្ថែមពីលើការបង្កើនការទទួលបានព័ត៌មានសុខភាព និងការកែលម្អការយល់ដឹងរបស់មនុស្សម្នាក់ ព័ត៌មានសមត្ថភាពយល់ដឹងក៏អាចជះឥទ្ធិពលដល់អ្វីដែលគេហៅថាអត្រាបញ្ចុះតម្លៃ នាពេលអនាគតផងដែរ ដែលជាតម្លៃដែលត្រូវបានកំណត់ចំពោះផលវិបាក និងព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតរបស់មនុស្សម្នាក់ ដូចជាមូលនិធិចូលនិវត្តឬមហារីកសួតដែលបណ្តាលមកពីការជក់បារី។

## សេចក្តីសន្និដ្ឋាន

ការសម្រេចបានការអប់រំទាប ទំនងជាប៉ះពាល់ដល់សុខភាព ទាំងតាមរបៀបរស់នៅស្ត្រេសខ្ពស់ និងតាមការខ្វះខាតសម្ភារៈ។ ស្ត្រេសសង្គមទាំងផ្នែកខ្វះ មានប្រភព និងត្រូវបានផ្សំដោយលទ្ធភាពខ្ពស់នៃការប៉ះពាល់នឹងរោគសង្គម បណ្តាញគាំទ្រសង្គមខ្សោយ និងជំហរសង្គមទាប។ ដូចគ្នានេះ អត្រាទាបនៃការធានារ៉ាប់រងសុខភាព យន្តការ

ដោះស្រាយខ្សោយ គុណភាពការងារទាប និងអសមត្ថភាពក្នុងការយល់ដឹងអំពីការព្យាបាល ឬការព្យាបាលទាំងអស់ហាក់ដូចជាដើរតួនា ទីយ៉ាងសំខាន់។

គេបានរកឃើញផលប៉ះពាល់នៃជតានិយមកំហឹង និងអរិភាពនៅក្នុងចំណោមអ្នកដែលបានទទួលការអប់រំទាប។ រចនាបថចិត្តរំភើបអវិជ្ជមានទាំងនេះ អាចរួមចំណែកដល់អត្រាខ្ពស់នៃការជក់បារីការផឹក និងការបរិភោគមិនល្អក្នុងចំណោមអ្នក ដែលមានការអប់រំទាប។ ភស្តុតាងថ្មីៗបង្ហាញថាឥទ្ធិពលពីមិត្តភក្តិដែលមានចំណេះដឹង និងសមាជិកគ្រួសារ ក៏មានតួនាទីធំ នៅក្នុងកត្តាហានិភ័យនៃអាកប្បកិរិយា។

សរុបមក កត្តាចិត្តសាស្ត្រទាក់ទងនឹងការទទួលបានការអប់រំក៏ជាកត្តាហានិភ័យផ្នែកវេជ្ជសាស្ត្រដ៏សំខាន់សម្រាប់ជំងឺបេះដូងជំងឺមហារីក ការឆ្លងមេរោគ ការរងរបួស ជំងឺសួត និងទឹកនោមផ្អែម ដែលជាជំងឺ បានរួមចំណែកភាគច្រើនបំផុតដល់អាយុសង្ឃឹមរស់ពី៦-៩ឆ្នាំ ដើយឡែកពីអ្នកដែលមាន និងដោយគ្មានសញ្ញាបត្រវិទ្យាល័យ។

## ឯកសារយោង


1- Steve Bradley and Colin Green, *The Economics of Education*, Academic Press, UK, 2020.

2- D. J. Brewer and P.J. MacEwan, *The Economics of Education*, USA, 2010.

3- Elchanan Cohn et al., *The Economics of Education*, USA, 1990.

ទ្រឹស្ដីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ